សហភាពសូវៀតសព្វថ្ងៃនេះដែរ ។ ចក្រភពនេះបានត្រូវបង្កើតឡើងដោយទឹកដីនៃបុព្វបុរសរុស្ស៊ីផង និងដោយទឹកដីរបស់ប្រទេសដែលទើបទន្ទ្រានយកបាននៅអឺរ៉ុបនិងអាស៊ីផង ។

** ប្រទេសនៃជនរុស្ស៊ីមានបួនមណ្ឌលគឺ*

—*«រុស្ស៊ីធំ»* ជាប្រភពនៃចក្រភពរុស្ស៊ី ហើយនិងជាទីតាំងនៃរាជធានីម៉ូស្គូទៀតផង ។ ប្រជារាស្ត្រនៃមណ្ឌលនេះស្ទើរតែទាំងអស់ កាន់សាសនាអរតូដុក (Orthodoxe) ។

—*«រុស្ស៊ីតូច»* ដែលមាន*អ៊ុយក្រែន* (Ukraine) ជាតំបន់កសិកម្មដ៏សំខាន់នោះ បានភ្ជាប់ទៅនឹងរុស្ស៊ីពីសតវត្សទី ១៧-១៨ ។ ក្រុង*គីយេវ* (Kiev) ដែលជាទីប្រជុំជនធំនៃមណ្ឌលនេះ ត្រូវបានជនរុស្ស៊ីចាត់ទុកជាសន្តបុរី ។ ប្រជាជនរុស្ស៊ីតូចមួយភាគជាអ្នកកាន់សាសនាកាតូលិច ។

—*«រុស្ស៊ីស»* ជាអាណាខេត្តដែលមានជនរុស្ស៊ីរស់នៅ ថ្វីត្បិតតែមុនឆ្នាំ ១៧៩៣ ជាទឹកដីរបស់រដ្ឋលីទុយអានី (Lithuanie) និងប៉ូឡូញ ។ នៅក្នុងមណ្ឌលនេះ មានអ្នកកាន់សាសនាកាតូលិចដែរ ។

— *រុស្ស៊ីខាងត្បូង* ជាមណ្ឌលដែលទើបតែទន្ទ្រានយកបានពីចក្រភពអូតូម៉ង់ (Ottoman) ។ ជនរុស្ស៊ីដែលរស់នៅក្នុងតំបន់នេះ ច្រើនតពូជពង្សពីជន*កូសាក់* (Cosaque) *(១)* មក ។

** ភូមិភាគអឺរ៉ុបដែលបានភ្ជាប់មកក្នុងចក្រភពរុស្ស៊ីមាន :*

—ប្រទេសដែលមាននៅប្រឹបសមុទ្របាល់ទិច គឺ *អេស្តូនី* (Estonie) *លីវ៉ូនី* (Livonie) *កួឡង់* (Courlande) ។ ប្រជាជនក្នុងតំបន់នេះបានតអំបូរពីជន *ភីណូវ៉ា* (Finnois) និងពីជន *លីទុយអានី* មក ។ អ្នកស្រុកអាយនេះរួមជាវណ្ណៈប្រជាកសិករដែលឋិតនៅក្រោមអំណាចក្រុមអភិជនមានដើមកំណើតជាជនអាឡឺម៉ង់ ។

—ប្រទេសប៉ូឡូញ

—ប្រទេសលីទុយអានី

—មហាឌូសេជាំងឡង់ (Grand Duché de Finlande)

---

*(១) កូសាក់ជាជនរុស្ស៊ីមួយដែលដើមឡើយជាកសិករអ្នកងារ ឬទាហានដែលបានភៀសខ្លួនរត់ពីការធ្វើបាបរបស់នាយចៅហ្វាយទៅរស់នៅឯភូមិភាគខាងត្បូង បង្កើតជានិគមជនជំនាញខាងចំបាំងសេះ ។*

— បេសារ៉ាប៊ី ‹Bessarabie› ជាតំបន់ដែលមានជនរូម៉ាំងនិងជនជ្វីបរស់នៅ ។

* *ភូមិភាគអាស៊ីរូស៊ី* ទើបតែត្រូវបានភ្ជាប់មកចក្រភពក្នុងពេលថ្មីៗនេះ ។ នៅភាគខាងត្បូង រាជាណាចក្រសេអរស៊ី ‹Géorgie› ត្រូវបានបញ្ចូលជាទឹកដីរូស៊ីក្នុងឆ្នាំ ១៨០១ ។ នៅភាគឦសាន ចក្រភពរូស៊ីបានវាតទីលើតំបន់ស៊ីបេរីទាំងមូល ។ ក្នុងឆ្នាំ ១៨៦០ គេបានសង់កំពង់ផែវ៉្លាឌីវ៉ូស្តុក (Vladivostock) ដើម្បីបើកតំបន់ស៊ីបេរីឲ្យមានទំនាក់ទំនងទៅមហាសមុទ្រប៉ាស៊ីភិច ។

១. សង្គមរូស៊ី

សង្គមរូស៊ីនៅពាក់កណ្តាលសតវត្សទី ១៩ ចែកជាវណ្ណៈ *អភិជន គហបតី* និង *អ្នកងារ* ។

* *វណ្ណៈអភិជន*

អភិជនរូស៊ីខ្លះមានដើមកំណើតជាក្សត្រនៃក្សត្របុរាណនានាក្នុងចក្រភព និងខ្លះទៀតជាម្ចាស់ដីធំៗ ដែលតែងតាំងឡើងដោយព្រះចៅអធិរាជ ។ អភិជនម្ចាស់ដីធំៗនៅតាមជនបទត្រូវបានតែងតាំងជាស្តេចត្រាញ់ ដែលប្រកបដោយអំណាចខ្លាំងក្លាគ្រប់វិស័យ មានរដ្ឋបាលនិងតុលាការជាដើម ។

នៅសតវត្សទី ១៩ ក្នុងផ្ទៃចក្រភពរូស៊ីទាំងមូល មានអភិជនចំនួនប្រហែលមួយពាន់ក្រុមគ្រួសារ ។ វណ្ណៈនេះមានបុព្វសិទ្ធិគ្រប់បែបយ៉ាងទាំងអស់ ដូចជាហួងហែងអគ្គការធំៗក្នុងរដ្ឋសំរាប់តែពួកគេ មានក្រុមចំណូលទាហាននិងមន្ត្រីជាន់ខ្ពស់ជាដើម ។

**វណ្ណៈគហបតី.*— វណ្ណៈនេះកំពុងតែរីកចំរើននៅតាមទីក្រុងដែលសិប្បកម្មនិងជំនួញមានការលូតលាស់ ។ សិប្បករ ឬឈ្មួញបានរួមបង្កើតជាសាជីវកម្មផ្សេងៗ ។ សាជីវកម្មទាំងនេះជាអគ្គការសេដ្ឋកិច្ចផង និងជាអគ្គការរដ្ឋបាលក្រុងផង ។

តាមក្រុងនានានៅប៉ែកខាងលិចនៃប្រទេស គេឃើញមានជនជ្វីបប្រកបជីវភាពជាច្រើន ។ តែជននេះ ទោះជាសិប្បករ ឬជាឈ្មួញធំដុំយ៉ាងណាក៏ដោយ នៅតែគ្មានសិទ្ធិចូលក្នុងសាជីវកម្មគហបតីក្រុងបានឡើយ ហើយគេត្រូវរស់នៅក្នុងសង្កាត់ដោយឡែកពីជនរូស៊ីថែមទៀតផង ។

*វណ្ណៈអ្នកងារ* .— កៅសិបភាគរយនៃប្រជាពលរដ្ឋរុស្ស៊ីជាអ្នកងារ ។ វណ្ណៈនេះមានពីរពួក គឺអ្នកងាររបស់រដ្ឋ និងអ្នកងាររបស់អភិជនម្ចាស់ដី ។ អ្នកងារជាប្រជាកសិករឥតមានសិទ្ធិសេរីភាព ហើយរស់ដោយលំបាកតោកយ៉ាក ក្រោមការជិះជាន់ ការជំរិតគ្រប់បែបយ៉ាងនៃអភិជនម្ចាស់ដីស្រែចំការ ។ ក្រៅពីជាប់កំណែនបីថ្ងៃក្នុងមួយអាទិត្យសំរាប់ធ្វើស្រែចំការផ្ទាល់របស់ម្ចាស់ដី ពួកអ្នកងារត្រូវបង់អាករខ្លួន ត្រូវគេហៅយកទៅធ្វើជាបាវបំរើក្នុងផ្ទះ ឬធ្វើជាកម្មករ ជាប្រយោជន៍អភិជន ។ ម្យ៉ាងទៀត ប្រជាកសិករទន់ខ្សោយទាំងនេះតែងបានទទួលការវាយធ្វើបាបពីសំណាក់វណ្ណៈម្ចាស់ដី តាមអំពើចិត្តទៀតផង ។

ប្រជារាស្ត្ររុស្ស៊ីភាគច្រើននៅល្ងីល្ងង់ ហើយតែងនាំគ្នាជឿឥតសមហេតុផលគ្រប់បែបយ៉ាង ។ ក្នុងវិស័យសាសនា គេពុំបានរៀបចំឲ្យមានការសិក្សាតាមច្បាប់ក្បួនទេ ។

ប៉ុន្តែ គួរកត់សំគាល់ថា បញ្ញវន្តក៏មានចំនួនច្រើនណាស់ដែរ ។ តាំងពីរជ្ជកាលព្រះចៅ*ពៀរឡឺក្រង់*មក ( សតវត្សទី ១៨ ) មានអភិជនរុស្ស៊ីមួយចំនួនបានជាប់ចិត្តសិក្សាវប្បធម៌បស្ចិមលោកណាស់ មានអក្សរសិល្បិ៍និងទស្សនវិជ្ជាបារាំងឬអាឡឺម៉ង់ជាដើម ។

ក្រោយពីគេបើកសិទ្ធិឲ្យយុវជនគ្រប់ស្រទាប់ចូលសិក្សាក្នុងសកលវិទ្យាល័យបាន ក្រុមបញ្ញវន្តរុស្ស៊ីក៏កើនចំនួនជាច្រើនទៀត ពិសេស បន្ទាប់ពីរាជ្យព្រះចៅ*នីកូឡាទី ១* មក ( ១៨២៥-១៨៥៥ ) ។

បញ្ញវន្តទាំងនេះតែងដៀលត្មះរបបនយោបាយ និងសង្គមរុស្ស៊ីចាស់ ហើយទាមទារសិទ្ធិសេរីភាពឯកជនទៀតផង ។ ទំនាស់ក្នុងសង្គមរុស្ស៊ីក៏កាន់តែធ្ងន់ឡើងៗជាលំដាប់ រហូតដល់ផ្ទុះចលនាបដិវត្តជាបន្តបន្ទាប់ លុះត្រាតែរលំរបបរាជានិយមនៅឆ្នាំ ១៩១៧ តែម្តង ។

### គ. របៀបគ្រប់គ្រងរដ្ឋ

ព្រះចៅអធិរាជ ឬសា ( tsar ) កាន់អំណាចផ្តាច់ការ ។ ព្រះអង្គជាកំពូលលើអង្គការគ្រប់គ្រងទាំងអស់ក្នុងចក្រភព ។ ព្រះចៅជាអ្នកបង្កើតច្បាប់សំរាប់រដ្ឋ ដោយព្រះអង្គឯង ។

នាម៉ឺនមន្ត្រី និងនាយទាហានទាំងឡាយក៏ត្រូវព្រះចៅតែងតាំង ឬបណ្តេញចោលតាម

ព្រះទ័យព្រះអង្គដែរ ។ ម្យ៉ាងទៀត ព្រះចៅអធិរាជទ្រង់ប្រើលទ្ធិផ្ដាច់ការក្នុងវិស័យសាសនាទៀតផង ។ រាជរដ្ឋាភិបាលរុស្ស៊ីពុំអនុញ្ញាតប្រជារាស្ត្រឲ្យគោរពសាសនាអ្វីក្រៅពីអរតូដុកឡើយ ។ បន្ទាប់ពីព្រះចៅអធិរាជមក គេឃើញមានក្រុមជំនុំជាច្រើនជាន់ថ្នាក់(១)កាន់កាប់កិច្ចគ្រប់គ្រងប្រទេស ។ សភាជាន់ខ្ពស់នៃអភិជនជាអង្គការត្រួតត្រាធំបំផុត ដែលបានប្រមូលយកនាទីគ្រប់បែបយ៉ាងទាំងអស់មកកាន់ ។ សភាជាន់ខ្ពស់នេះជាអង្គការនីតិបញ្ញត្តិផង ជានីតិប្រតិបត្តិផង និងតុលាការផង ហើយពិសេសទៅទៀត ត្រូវត្រួតពិនិត្យលើអ្វីៗទាំងអស់ក្នុងអង្គការរដ្ឋ ។ ក្នុងការបែងចែកខាងរដ្ឋបាល ខេត្តដែលសំខាន់ជាងគេ ហើយដែលមាននាទីធំខាងផ្តល់ទ័ព គឺខេត្តដែលហៅថាគូវែណឺម៉ង់ ។ គួរកត់សំគាល់ថា ក្នុងរបៀបរដ្ឋបាល តំបន់ខ្វះក្នុងចក្រភព ជាពិសេសភូមិភាគខាងលិច និងខាងត្បូង ដែលបានភ្ជាប់មកក្នុងទឹកដីរុស្ស៊ីនោះជាតំបន់ស្វយ័ត ។

## ២. ប្រទេសរុស្ស៊ីក្នុងរជ្ជកាលព្រះចៅអាឡិចសង់ទី២ (១៨៥៥-១៨៨១)

### ក. ព្រះចៅអាឡិចសង់ ទី ២



*ព្រះចៅអាឡិចសង់ ទី ២*

*ព្រះចៅអាឡិចសង់ ទី ២* ជាបុត្រច្បងនៃព្រះចៅអធិរាជ *នីកូឡាទី ១* (Nicolas 1er) ។ ព្រះចៅអាឡិចសង់ទី ២ បានធ្វើដំណើរសិក្សាជាញឹកញាប់ហើយ ទ្រង់មានព្រះទ័យទូលាយ ក្នុងការទទួលគំនិតថ្មីនានា ។ ព្រះអង្គទ្រង់ជាអធិរាជដ៏ល្បីល្បាញក្នុងប្រវត្តិសាស្ត្ររុស្ស៊ី ដោយព្រះចៅបានទុកស្នាព្រះហស្តជាច្រើន ក្នុងវិស័យកំណែទំរង់ វិស័យនយោបាយពង្រីកទឹកដី និងវិស័យរុស្ស៊ីកម្ម ។

---

*(១) ក្នុងវិស័យគ្រប់គ្រងប្រទេស គេឃើញមានទីស្ដីការក្រសួងរដ្ឋមន្ត្រីគ្រប់ផ្នែកផង ក្រៅពីទាំងក្រុមជំនុំដោយឡែក សំរាប់គ្រប់ផ្នែកទាំងនោះទៀតផង ។*

ព្រះចៅអាឡិចសង់ទី ២ ត្រូវបានគេលបធ្វើគុតនៅថ្ងៃទី ១ មីនា ១៨៨១ នៅឱកាសដែលព្រះអង្គវិលមកពីឡាយព្រះហស្តលេខាសំរេចឲ្យរៀបចំរដ្ឋធម្មនុញ្ញសំរាប់ប្រទេសជាតិ ។

ខ. កំណែទំរង់ផ្សេងៗ

* *ការលុបបំបាត់របបអ្នកងារ .—* ស្របគ្នានឹងគំនិតរបស់ទីប្រឹក្សា ព្រះចៅអាឡិចសង់ទី ២ ឈ្វេងយល់ថា របបអ្នកងារពុំអាចធ្វើឲ្យសេដ្ឋកិច្ចរីកចំរើនបានឡើយ ។ ដូចនេះ ព្រះអង្គក៏សំរេចបំបាត់របបនេះចោល ដោយរំដោះអ្នកងាររបស់រដ្ឋជាដំបូង ។ បន្ទាប់មកនៅខែកុម្ភៈ ១៨៦១ ព្រះចៅបានបង្កើតច្បាប់រំដោះអ្នកងារទូទៅទាំងប្រទេស ដោយតំរូវឲ្យផ្តល់ដល់អតីតអ្នកងារទាំងនោះ នូវដីស្រែចំការមួយភាគតូចទៀតផង ។

* *កំណែទំរង់ផ្នែករដ្ឋបាល តុលាការ សិក្សាធិការ កងទ័ព .—* ក្នុងវិស័យរដ្ឋបាល គោលការណ៍ស្វយ័តនៃកិច្ចចាត់ចែងត្រូវបានយកមកប្រើប្រាស់នៅគ្រប់ឃុំស្រុកនិងខេត្ត ។ ម្យ៉ាងទៀត គេបានបង្កើតសភាតំបន់ឲ្យត្រួតត្រាមើលការខុសត្រូវ សាលារៀន ផ្ទះពេទ្យ និងសម្បត្តិសាធារណៈទូទៅ ។

ចំពោះផ្នែកតុលាការ គេបានរៀបចំឲ្យទៅជាអង្គការអចិន្ត្រៃយ ដែលមានគ្រប់ឯកទេសភាពទាំងអស់ ។

ព្រះចៅអាឡិចសង់ ទី ២ បានប្រកាសសេរីភាពក្នុងការសិក្សា តាំងពីបឋមសិក្សារហូតដល់ឧត្តមសិក្សា ។

ក្នុងវិស័យទ័ព ព្រះអង្គបានបង្កើតសាលាយោធា ដែលសិក្សាក្បួនយុទ្ធសាស្ត្រជាក់លាក់ដើម្បីសាងកងទ័ពជាតិយ៉ាងទំនើបមួយ ។

គ. នយោបាយរូស៊ីកម្ម

ជាការរៀបជើងព្រួល ដើម្បីការពារកុំឲ្យកើតមានចលនារំដោះជាតិ ព្រះចៅអាឡិចសង់ទី ២ បានចាត់គំរោងការរំលាយជាតិផ្សេងៗក្នុងចក្រភព ឲ្យទៅជាជាតិរូស៊ីទាំងអស់ ។ ដើម្បីសំរេចគោលបំណងនេះ ព្រះចៅបានប្រើមធ្យោបាយបំបែកបំបាក់ផ្ទៃក្នុងនៃជាតិនីមួយៗដែលរស់នៅក្នុងប្រទេស ។ ក្នុងករណីនេះ ព្រះអង្គបានធ្វើច្បាប់មួយ នៅឆ្នាំ ១៨៦៤ រឹបអូសដីស្រែចំការរបស់អភិជនប៉ូឡូញ ហើយយកមួយភាគប្រគល់ផ្តាច់ឲ្យទៅកសិករអ្នក

ប្រវាស់ដី និងមួយភាគទៀតទុកជាសម្បត្តិរដ្ឋរុស្ស៊ី ។ បន្ទាប់មក ព្រះចៅក៏បញ្ជូនជនរុស្ស៊ីឲ្យទៅតាំងនិគមជន នៅលើដីដែលរឹបអូសយកនោះ ។ ក្រៅពីនេះ ព្រះអង្គបានបង្ខំឲ្យប្រើភាសារុស្ស៊ីជាផ្លូវការក្នុងសាលា និងគ្រប់កន្លែងសាធារណៈទាំងឡាយ បំបិទសេរីភាពខាងជំនឿសាសនា ហើយបង្ខិតបង្ខំអ្នកស្រុកឲ្យកាន់សាសនាអរត្តូដុកទាំងអស់គ្នា ។ សម្បត្តិទ្រព្យ ដីធ្លីរបស់វត្តអារាម ដែលពុំមែនអរត្តូដុក ក៏ត្រូវបានរឹបអូសដាក់ជាសម្បត្តិរដ្ឋទាំងអស់ដែរ ។ នយោបាយរុស្ស៊ីកម្មនេះក៏បានធ្លាក់ទៅលើគ្រប់ជាតិសាសន៍ទាំងអស់ ដែលទឹកដីត្រូវបានភ្ជាប់មកក្នុងចក្រភពរុស្ស៊ី ។

ឃ. ភាពថ្មីនៃបញ្ញវន្តរុស្ស៊ី

កំណែទំរង់ទាំងប៉ុន្មាននេះបានបណ្ដាលឲ្យកើតមានវណ្ណៈថ្មីមួយទៀត គឺក្រុមអ្នកប្រកបវិជ្ជាជីវៈសេរី មានសាស្ត្រាចារ្យ គ្រូពេទ្យ មេធាវីជាដើម ។ វណ្ណៈថ្មីនេះជាបញ្ញវន្តដែលលេចចេញមកពីមជ្ឈដ្ឋានរាស្ត្រសាមញ្ញ ពេញចិត្តនឹងវប្បធម៌ជាតិ ខុសពីអភិជនរុស្ស៊ីដែលនិយមតែវប្បធម៌បារាំង ។ បញ្ញវន្តនេះស្រេកឃ្លានសិទ្ធិសេរីភាព លទ្ធិប្រជាធិបតេយ្យ និងពោរពេញទៅដោយទឹកចិត្តបដិវត្ត ។ អាស្រ័យហេតុនេះហើយ បានជាគេឃើញកើតមានក្រុមនិស្សិតបដិវត្តជាច្រើន ។ នៅពេលជាមួយគ្នានោះ ស្នាដៃទស្សនវិទូធំៗក៏ត្រូវបានប្រែជាភាសារុស្ស៊ី មានសៀវភៅកាពីតាល់ (Capital) របស់លោក *កាលម៉ាក* (Karl Marx) ជាដើម ។

គំនិតបដិវត្តបានត្រូវយកទៅសាបព្រោះតាមភូមិ តាមរោងជាង តាមការដ្ឋាននានា តាមរយៈនិស្សិតដែលក្លែងបន្លំជាកសិករ ឬជាកម្មករ ។ តែបន្តិចក្រោយមក សកម្មភាពនៃក្រុមបដិវត្តនេះត្រូវនគរបាលរកឃើញ ហើយចាត់ការវាយបំបែកចលនានេះ ដោយប្រើគុក ច្រវាក់ និងបាញ់សំលាប់ ។ ចាប់ពីពេលនោះមក ក្រុមអ្នកបដិវត្តក៏សំរេចប្រើមធ្យោបាយក្ដៅតបទៅវិញ គឺលបលួចធ្វើឃាតអ្នកកាន់អំណាចរដ្ឋ និងប៉ុនប៉ងធ្វើគុតព្រះចៅអធិរាជទៀតផង ។

អំពើភេរវកម្មនេះបណ្ដាលឲ្យក្រុមអភិជនប្រតិកិរិយាយកជាលេសបន្ថយចំណើរកំណែទំរង់ដោយបំភ័យព្រះចៅថា គ្រោះថ្នាក់នេះជាផលវិបាកនៃសេរីភាពក្នុងការសិក្សា ក្នុងការ

សរសេរ ។ ម្ល៉ោះហើយ ព្រះចៅអធិរាជរាវែក ស្ទាក់ស្ទើរព្រះទ័យក្នុងដំណោះស្រាយវិបត្តិសង្គមនេះតទៅទៀត ។

នៅឱកាសអាក់ដំណើរនៃកំណែទំរង់នេះ ពួកអ្នកបដិវត្តដែលបានរួមគ្នាជាសមាគមឈ្មោះ « *ដីនិងសេរីភាព* » កាន់តែចំបង្កើនសកម្មភាពភេរវកម្មច្រើនឡើងទៀត ។ នៅថ្ងៃទី ១ មីនា ១៨៨១ ព្រះចៅអាឡិចសង់ទី ២ ក៏ចូលទិវង្គត ដោយគេលួចគប់គ្រាប់បែកទៅលើព្រះអង្គទៅ ។ ទិវង្គតនៃព្រះអង្គបានបញ្ចប់វិវឌ្ឍនាការឆ្ពោះទៅរករបបសេរីនៅប្រទេសរូស៊ី ។

# ៣. ប្រទេសរូស៊ីក្រោយរជ្ជកាលព្រះចៅអាឡិចសង់ ទី ២

ក្រោយព្រះចៅ*អាឡិចសង់ ទី ២* ចូលទិវង្គតទៅ ព្រះចៅ*អាឡិចសង់ ទី ៣* និងព្រះចៅ *នីកូឡា ទី ២* បានឡើងគ្រងរាជ្យជាបន្តបន្ទាប់ ។

ក្នុងរាជ្យទាំងពីរនេះ ប្រទេសរូស៊ីបានជួបប្រទះវិបត្តិកាន់តែធ្ងន់ឡើងៗជាលំដាប់ រហូតដល់បានផ្លាស់របបគ្រប់គ្រងទៅជាសង្គមនិយម នៅឆ្នាំ ១៩១៧ ។

## ក. វិបត្តិនយោបាយនិងសង្គម

ព្រះទិវង្គតនៃព្រះចៅ អាឡិចសង់ ទី២ បានបើកឱកាសឲ្យពួកអភិជនប្រតិកិរិយាផ្អាកដំណើរកំណែទំរង់ទាំងអស់ ហើយប្រទាញប្រទេសរូស៊ីទៅរកទំលាប់ចាស់វិញ ។ អ្នកបដិវត្តជាពិសេស អ្នកដឹកនាំល្បីៗត្រូវនគរបាលដេញព្យាបាទ ចាប់ដាក់គុកឬបញ្ជូនទៅស៊ីបេរីបង្ខំឲ្យធ្វើការជាទំងន់ បណ្ដាលឲ្យអ្នកខ្លះរត់ភៀសខ្លួនទៅនៅឯអឺរ៉ុបខាងលិច ។

រីឯនយោបាយរូស៊ី ក៏មានកំរិតកាន់តែខ្លាំងឡើងដែរ ។ នៅពេលជាមួយនោះ ប្រទេសរូស៊ីកំពុងតែប៉ងវាតអំណាចចក្រពត្តិរបស់ខ្លួននៅចុងបូព៌ា បណ្ដាលឲ្យកើតមានចំបាំងជាមួយនឹងចក្រពត្តិជប៉ុនពីឆ្នាំ ១៩០៤ ដល់ ១៩០៥ ។ ក្នុងសង្គ្រាមនេះ ប្រទេសរូស៊ីបានទទួលបរាជ័យយ៉ាងអាម៉ាស់បំផុត ។

## ខ. ការលូតលាស់ខាងសេដ្ឋកិច្ច

វិបត្តិនយោបាយនិងសង្គមពុំបានធ្វើឲ្យសេដ្ឋកិច្ចរូស៊ីចុះអន់ថយទេ ។ ផ្ទុយទៅវិញ នៅចុងសតវត្សទី ១៩ និងដើមសតវត្សទី ២០ នេះ សេដ្ឋកិច្ចរូស៊ីបានចំរើនយ៉ាងខ្លាំង ។

អាស្រ័យមូលធននិងអ្នកបច្ចេកទេសបារាំង រុស្ស៊ីបានស្ថាបនាផ្លូវរថភ្លើងរាប់ពាន់គីឡូម៉ែតកាត់ខ្វាត់ខ្វែងពីក្រុងមួយទៅមួយ ហើយជាពិសេសផ្លូវដែកកាត់ស៊ីបេរីដែលភ្ជាប់អឺរ៉ុបទៅចុងបូព៌ា ។ ដោយមូលធនបរទេសនេះ ឧស្សាហកម្មអណ្ដូងរ៉ែក៏ត្រូវបានរៀបចំឡើង ដើម្បីផលិតដែក ធ្យូងថ្ម និងប្រេងកាត ។ ជាមួយគ្នានោះ រោងចក្រក៏ត្រូវបានស្ថាបនាឡើងនៅគ្រប់មណ្ឌលដែលមានវត្ថុធាតុដើម និងជាពិសេសនៅក្រុង ម៉ូស្គូ និងក្រុងសាំងពេទែរស្បួ ។

នយោបាយឧស្សាហូបនីយកម្មនេះបានបង្កើតឲ្យមានវណ្ណៈកម្មករក្រីក្រ ខ្វះព្រឹក ខ្វះល្ងាច ដែលជាកត្តាមួយធ្វើឲ្យងាយសាបព្រោះគំនិតបដិវត្ត ។

**គ. វិបត្តិរដ្ឋធម្មនុញ្ញ**

ទោះជារាជរដ្ឋាភិបាលខិតខំបង្ក្រាបយ៉ាងខ្លាំងក្លាបែបណាក៏ដោយ វិបត្តិសង្គមពុំអន់ថយសោះឡើយ ។ ចំពោះស្ថានការណ៍នេះ ព្រះចៅ នីកូឡា ទី ២ បានសំរេចព្រះទ័យសន្យាជាឧឡារិកថានឹងកែទំរង់នយោបាយ ព្រមទាំងអនុញ្ញាតឲ្យមានអង្គការត្រួតពិនិត្យរដ្ឋាភិបាលថែមទៀតផង ។



ព្រះចៅនីកូឡា ទី ២

សេចក្ដីសំរេចព្រះទ័យនេះ បានធ្វើឲ្យក្រុមអភិជនប្រតិកិរិយាពុំសប្បាយចិត្ត ហើយរិះរកមធ្យោបាយ បំផ្លាញកិច្ចសន្យានេះចោលទៀតផង ។ ដើម្បីបំរើគោលគំនិតនេះ នាយនគរបាលសំងាត់ម្នាក់ក៏បានបន្លំចូលទៅគ្រប់រោងចក្រទាក់ទាញកម្មករឲ្យនាំគ្នាធ្វើបាតុកម្មសំដែងទឹកចិត្តគោរពចំពោះព្រះចៅអធិរាជ គ្រាន់បានជាលេសចោទថា មហាជននៅតែធ្វើឲ្យមានការជ្រួលច្របល់ដដែល ។ នៅថ្ងៃ ២២ មករា ១៩០៥ លុះក្បួនបាតុកម្មទៅដល់មុខ **«វាំងសិសិររដូវ»** ក្នុងក្រុងសាំងពេទែរស្បួ ក្រោមការមូលកាច់នៃពួកអភិរក្សនិយម ព្រះចៅ

នីកូឡាទី ២ ដែលនឹកស្មានថាជាបាតុកម្មប្រទូសនឹងព្រះអង្គនោះ ក៏បានបញ្ជាទាហានឱ្យបាញ់ប្រហារបាតុកម្មបែកបាក់ខ្ចាត់ខ្ចាយអស់ទៅ ។

អំពើនេះបានធ្វើឱ្យប្រជារាស្ត្រកាន់តែចងកំហឹង និងបះបោរកាន់តែខ្លាំងឡើងទៀត ។ នៅពេលនោះ កងទ័ពជើងគោកនិងជើងទឹកក៏បះបោរឡើងដែរ ។ ចំពោះស្ថានការណ៍បែបនេះ ព្រះចៅនីកូឡាទី ២ ក៏ប្រញាប់ប្រញាល់សំរេចថានឹងប្រទានរដ្ឋធម្មនុញ្ញដល់ប្រទេស ។ ប៉ុន្តែ បាតុកម្មនិងកូដកម្មក៏នៅតែមានតទៅទៀតពេញមួយខែតុលាឆ្នាំ ១៩០៥ ហើយចាប់ពីពេលនោះមក អង្គការសូវៀតជាច្រើនក៏បានត្រូវបង្កើតនៅក្នុងរាជធានីម៉ូស្គូ និងសាំងពេទែស្បួ ។ ដើម្បីបន្ធូរបន្ថយបរិយាកាសដ៏តឹងតែងនេះ ព្រះចៅនីកូឡាទី២ ក៏ប្រកាសឱ្យរៀបចំបង្កើតរដ្ឋាភិបាលមួយ ដែលមានសភាពីរអមផង ។

របបថ្មីនេះនៅតែថ្វាយអំណាចខ្លាំងក្លាដល់ព្រះចៅអធិរាជដដែល ថ្វីត្បិតតែមានសភាជាន់ខ្ពស់និងរដ្ឋសភាឬសភាឌូម៉ាជាអង្គការនីតិបញ្ញត្តិក៏ដោយ ។ ម្ល៉ោះហើយ ទំនាស់រវាងអង្គការនីតិប្រតិបត្តិនិងនីតិបញ្ញត្តិក៏ចេះតែមានជានិច្ច បណ្តាលឱ្យសភាឌូម៉ាត្រូវរលាយជាញឹកញយរកពេលធ្វើអ្វីពុំកើតឡើយ ។

វិបត្តិសង្គមក៏ចេះតែបន្តដំណើរទៅទៀត កាលបើអំពើពុករលួយ អំពើក្បត់ជាតិបានត្រូវបង្ហាញឱ្យកាន់តែឃើញច្បាស់ឡើងៗ ។ នៅទីបំផុត មហាបាតុកម្មក៏បានផ្ទុះឡើងនៅក្រុងពេត្រូក្រាត *(១)* និងក្រុងម៉ូស្គូ ក្នុង ខែកុម្ភៈ ឆ្នាំ ១៩១៧ បន្ទាប់ពីមានទុរ្ភិក្សក្នុងមជ្ឈដ្ឋានកម្មកររោងចក្រទូទៅ ។ នៅពេលនោះ កងទ័ពពុំគ្រាន់តែប្រកែកពុំព្រមទៅបង្ក្រាបបាតុករដូចមុនៗទៀតប៉ុណ្ណោះទេ ថែមទាំងក្រោយមក បានទៅរួមកំលាំងជាមួយនិងអ្នកបដិវត្តទាំងនោះទៀតផង ។

ចំពោះស្ថានការណ៍ដ៏ពិបាកនេះ ព្រះចៅ នីកូឡា ទី២ ក៏ប្រកាសលាលែងពីរាជសម្បត្តិ ។ ក្នុងឱកាសនោះ គណៈកម្មាធិការមួយដែលមានតំណាងរាស្ត្រក្នុងសភាឌូម៉ាជាសមាជិក បានកាន់អំណាចជាបណ្តោះអាសន្ន រង់ចាំពេលនឹងរៀបចំសំរេចយកបន្ទាត់នយោបាយថ្មី ។ រដ្ឋាភិបាលបណ្តោះអាសន្ននេះពុំបានជាធ្វើអ្វីសំរាប់ប្រទេសជាតិឱ្យប្លែក

---

*(១) ក្រុងពេត្រូក្រាតនិងក្រុងសាំងពេទែស្បួជាក្រុងតែមួយទេ សព្វថ្ងៃហៅលេនីនក្រាត ។*

ពីមុនឡើយ មកពីម្យ៉ាងដោយជាប់ដៃបន្តចំបាំងជាមួយនឹងអាឡឺម៉ង់ និងម្យ៉ាងទៀត ដោយរវល់តែភ័យនឹងការគំរាមកំហែងនៃពួកឧត្តមសេនីយរាជានិយម ។

ការគាំងដំណើរស្ថាបនាប្រទេសជាតិនេះជាឱកាសហុចឲ្យគណបក្ស*បុលសេវិច* (១) ឃោសនាប្រមូលយកប្រជាប្រិយភាពបន្តិចម្តងៗ ហើយក៏សំរេចធ្វើ *បដិវត្តន៍ម៉ាកនិយម* ដណ្តើមយកអំណាចបាននៅខែតុលាឆ្នាំ ១៩១៧ ។

## សំណួរ

១. ទឹកដីនៅតំបន់ណាខ្លះ ដែលរួមបានជាចក្រភពរូស៊ីក្នុងសតវត្សទី ១៩ ?

២. នៅសតវត្សទី ១៩ សង្គមរូស៊ីមានចែកជាវណ្ណៈអ្វីខ្លះ ? និយាយដោយសង្ខេបអំពីជីវភាពរបស់វណ្ណៈនីមួយៗ ។

៣. រៀបរាប់ពីកំណើតនៃបញ្ញវន្តរូស៊ី ។ ក្រុមនេះមានឧត្តមគតិដូចម្តេចខ្លះដែរ ?

៤. អធិប្បាយដោយសង្ខេបអំពីរបៀបគ្រប់គ្រងនៅរូស៊ី មុនរាជ្យព្រះចៅអាឡិចសង់ទី ២ ។

៥. ហេតុអ្វីបានជាព្រះចៅអាឡិចសង់ ទី ២ ជាអធិរាជល្បីល្បាញក្នុងប្រវត្តិសាស្ត្ររូស៊ី ? អធិប្បាយដោយត្រួសៗអំពីស្នាព្រះហស្តខាងកិច្ចការកែទំរង់ទាំងអស់ ។

៦. នយោបាយរូស៊ីកម្មរបស់ព្រះចៅអាឡិចសង់ទី ២ មានដំណើរដូចម្តេចខ្លះ ?

៧. សកម្មភាពនៃក្រុមបញ្ញវន្តរូស៊ី ក្នុងការផ្សព្វផ្សាយគំនិតបដិវត្ត ។

៨. ប្រតិកម្មនៃក្រុមអភិជនអភិរក្សនិយមចំពោះកំណែទំរង់ទូទៅ ។

៩. សេដ្ឋកិច្ចរូស៊ីនៅសតវត្សទី ១៩ មានការរីកចំរើនឬទេ ? បើគ្មាន តើដោយហេតុអ្វី ? បើមានវិញ តើដោយសារអ្វី ហើយក្នុងវិស័យណាខ្លះ ?

១០. នយោបាយឧស្សាហូបនីយកម្មមានផលវិបាកអាក្រក់ទៅលើរបបគ្រប់គ្រងចាស់ ដូចម្តេចខ្លះ ?

---

*(១) បុលសេវិច ជាគណបក្សកុម្មុយនិស្តរូស៊ីជំនាន់បដិវត្ត ដែលមានលោកលេនីន និងលោកត្រុតស្គីជាអ្នកដឹកនាំ ។*

១១. បរិយាយដោយសង្ខេបអំពីវិបត្តិសង្គមរុស្ស៊ី ក្រោយការសំលាប់រង្គាលនៅថ្ងៃ ២២ មករា ១៩០៥ ។

១២. ព្រឹត្តិការណ៍ដែលកើតមាននៅប្រទេសរុស្ស៊ី នៅសិសិររដូវនៃឆ្នាំ ១៩១៧ ។

## លំហាត់

គូរផែនទីប្រាប់ពីទឹកដីដែលត្រូវបញ្ចូលមកក្នុងចក្រភពរុស្ស៊ី ។

# ៨. ប្រទេសចិននិងប្រទេសជប៉ុន ពីឆ្នាំ ១៨៤០ ដល់ ១៩១៤

នៅសម័យមុនសង្គ្រាមលោកលើកទី ១ ប្រទេសទាំងឡាយស្ទើរតែទាំងអស់នៃទ្វីបអាស៊ី បានទទួលរងគ្រោះពីនយោបាយអាណានិគមនៃមហាអំណាចទាំងឡាយនៅបស្ចិមទិស ។ យើងនឹងសិក្សាអំពី *ប្រទេសចិន* និង *ប្រទេសជប៉ុន* ដើម្បីជាឧទាហរណ៍បង្ហាញនយោបាយអាណានិគមនៃមហាអំណាចទាំងនោះ មកលើប្រទេសនានានៅអាស៊ី ។

ទំនាក់ទំនងរវាងអឺរ៉ុបនិងប្រទេសទាំងពីរបានធ្វើឲ្យមានបំលាស់ប្ដូរជាខ្លាំង នៅក្នុងប្រទេសទាំងពីរ ជាពិសេស នៅក្នុងប្រទេសជប៉ុន ។

## ក. ប្រទេសចិន

### ១. ប្រទេសចិនមុនអន្តរាគមន៍របស់អឺរ៉ុប

ជាយូរយារណាស់មកហើយ ប្រទេសចិនជាចក្រភពមួយមានទំហំធំណាស់ ។ ក្រៅពីប្រទេសចិនមែនទែននោះ នៅមានទឹកដីជាច្រើនទៀត ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងប្រទេសចិនដែរ ហើយទទួលឥទ្ធិពលពីចិននិងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងចិន ដូចជា *កូរេ* (Corée) *ម៉ាន់ជូរី* ( Mandchourie ) *ម៉ុងហ្គោលី* (Mongolie) *ទីបេ* (Tibet) *ភូមា* និង *ឥណ្ឌូចិន* ជាដើម ។

ក៏ប៉ុន្តែ ចក្រភពចិនដ៏ធំធេងនេះមិនដែលមានឯកភាពទេ ទាំងខាងភូមិសាស្ត្រក៏ដូចជាខាងនយោបាយដែរ ។ តំបន់នានានៃប្រទេសចិនមានសភាពខុសៗគ្នា តាំងពីអាកាសធាតុផលិតផលកសិកម្ម រហូតដល់ប្រជាជននិងភាសា ជាហេតុនាំឲ្យតំបន់ទាំងនោះហាក់ដូចជាពុំមែននៅក្នុងប្រទេសចិនជាមួយគ្នា ។

ចំណែកខាងនយោបាយវិញក៏ដូចនោះដែរ ព្រះចៅអធិរាជពុំដែលមានអំណាចគ្រប់

គ្រងគ្រប់តំបន់ទាំងអស់នៃប្រទេសចិនទាំងមូលឡើយ ។ មានតែអក្សរនិងទំនៀមទំលាប់ទេ ដែលធ្វើឲ្យប្រជាជនចិនគ្រប់តំបន់មានឯកភាព ។

ចិនធ្លាប់មានឈ្មោះល្បីជាយូរមកហើយ ថាជាអ្នកឧស្សាហ៍ធ្វើការ មានប្រាជ្ញាឈ្លាសវៃ ចេះគួរសម ហើយចូលចិត្តគោរពអ្នកប្រាជ្ញបណ្ឌិត ។ អរិយធម៌ចិនជាអរិយធម៌បរមបុរាណមួយជំនាន់គ្នានឹងអរិយធម៌អេស៊ីប ( Egypte ) បុរាណដែរ ។ គេធ្លាប់បានកោតសរសើរចិនពីតំបាញសូត្រ ពីប៉ាក់គ្រឿប ( broderie ) និងពីគ្រឿងក្អមឆ្នាំង ។ ពួកអឺរ៉ុបបានរៀនពីចិននូវវិធីធ្វើក្រដាស ធ្វើរំសេវ និងត្រីវិស័យ ។

ក៏ប៉ុន្តែ អរិយធម៌ចិនបុរាណច្រើននិយមអតីតកាល ហើយមិនសូវគិតពីការចំរើនទៅអនាគតឡើយ ពីព្រោះចិនជាអ្នកនិយមទំនៀមទំលាប់យ៉ាងខ្ជាប់ខ្ជួន ហើយមិនចូលចិត្តគំនិតថ្មី ជាពិសេសគំនិតរបស់ពួកបរទេស ។

## ២. ប្រទេសចិនក្រោយអន្តរាគមន៍របស់អឺរ៉ុប

មិនមែនដោយសេចក្ដីរីករាយទេ ដែលចិនបានបើកទ្វារទទួលឥទ្ធិពលពីបរទេស ។ ជនជាតិអឺរ៉ុបបានប្រើមធ្យោបាយផ្សេងៗ ជាពិសេសបានប្រើកំលាំងទ័ព ដើម្បីធ្វើអន្តរាគមន៍ទៅក្នុងប្រទេសចិន ។

ក. ចំបាំងអាភៀន ( Guerre de l'Opium )

ប្រទេសអង់គ្លេសបានយករឿងអាភៀនទៅធ្វើជាលេស ដើម្បីបង្កបង្កើតសង្គ្រាមជាមួយនឹងចិន ក្នុងគោលបំណងដណ្ដើមយកទឹកដីចិន ។

ដោយដឹងថា រដ្ឋាភិបាលចិនបានហាមឃាត់មិនឲ្យដឹកអាភៀនចូលក្នុងប្រទេសរបស់គេ រដ្ឋាភិបាលអង់គ្លេសបានរំលោភនាំអាភៀនចំនួន ២០ ០០០ ហឹប ពីប្រទេសឥណ្ឌាចូលទៅក្នុងប្រទេសចិននៅឆ្នាំ ១៨៤០ ។ រដ្ឋាភិបាលចិនបានបញ្ជាឲ្យចាប់យកអាភៀនទាំងនោះទៅបំផ្លាញចោលក្នុងសមុទ្រ ។

ឆ្លៀតឱកាសនោះ ប្រទេសអង់គ្លេសបានប្រកាសសង្គ្រាមជាមួយចិន ហើយបានបង្ខំចិនឲ្យចុះ *សន្ធិសញ្ញាណានគីន* ( Nankin ) នៅឆ្នាំ ១៨៤២ ។ តាមសន្ធិសញ្ញានេះ ប្រទេសចិនត្រូវប្រគល់ឲ្យអង់គ្លេសនូវក្រុង *ហុងកុង* ព្រមទាំងសិទ្ធិធ្វើជំនួញនៅកំពង់ផែចិន ៥ ទៀត ដូចជា *ក្វាន់ទុង* ( Canton ) និង *សាំងហាយ* ( Changhaï ) ជាដើម ។

ដោយសារវៀតអាកៀននេះ មហាអំណាចអឺរ៉ុបដទៃទៀតក៏បានទទួលផលប្រយោជន៍ពីចិនច្រើនដែរ ដូចជាប្រទេសបារាំងដែលមានសិទ្ធិផ្សាយសាសនាកាតូលិច ក្នុងប្រទេសចិនទាំងមូលជាដើម ។

៣. ចលនាថៃភិញ (Taï Ping)

បរាជ័យចិនក្នុងចំបាំងអាភៀនបណ្ដាលឲ្យប្រជាពលរដ្ឋមានចិត្តក្ដៅក្រហាយយ៉ាងខ្លាំងៗ ក្រោមដំណឹកនាំនៃ *សមាគមសំងាត់ ថៃភិញ* ប្រជារាស្ត្រចិនបាននាំគ្នាបះបោរប្រឆាំងនឹងអ្នកកាន់អំណាចជាតិចិនផង នឹងពួកបរទេសផង ។

គោលដៅសំខាន់បំផុតរបស់សមាគមនេះ គឺការបោសសំអាតវប្បធម៌និងអរិយធម៌ចិន ដើម្បីញាំងសង្គមជាតិចិន ដែលបានទទួលឥទ្ធិពលពីទស្សនៈនិងពីសាសនាបរទេស ឲ្យបានស្អាតបរិសុទ្ធឡើងវិញ ។

ក្នុងរបះបោរនេះ ពួកអ្នកផ្សាយសាសនាជាតិបារាំងម្នាក់បានទទួលទារុណកម្ម ហើយពួកពាណិជ្ជករជាតិអង់គ្លេសជាច្រើននាក់បានជាប់ឃុំឃាំង ។

ប្រទេសបារាំងនិងប្រទេសអង់គ្លេសបានធ្វៀតយកលេសនេះ បញ្ជូនកងទ័ពរួមគ្នាមកវាយប្រហារប្រទេសចិនពីឆ្នាំ១៨៥៨ ដល់ឆ្នាំ១៨៦០ ។ ចិនត្រូវទទួលបរាជ័យទៀត ជាហេតុនាំឲ្យបារាំងនិងអង់គ្លេសបានទទួលសិទ្ធិធ្វើជំនួញនៅកំពង់ផែចិនចំនួន ៧ ថែមទៀត ព្រមទាំងសិទ្ធិតាំងអគ្គទូតនៅក្រុងប៉េកាំងផង ដើម្បីការពារអាណិកជនជាតិគេ ។

ក្រៅពីនេះ បារាំងនិងអង់គ្លេសបានទទួលអំណាចដ៏សំខាន់ពីរយ៉ាងទៀតគឺ

១. ច្បាប់អនុញ្ញាតពួកបរទេសដែលទៅតាំងនៅក្នុងប្រទេសចិន ឲ្យមានតុលាការសំរាប់ជំនុំជំរះវិនិច្ឆ័យរឿងរ៉ាវរបស់គេ ដោយឡែកពីក្រសួងយុត្តិធម៌របស់ចិន ។

២. ច្បាប់អនុញ្ញាតជនជាតិអឺរ៉ុបឲ្យត្រួតត្រាលើសង្កាត់ទាំងឡាយណាក្នុងទីក្រុង ដែលមានពួកអឺរ៉ុបតាំងនៅ ។

ម្យ៉ាងទៀត ចិនត្រូវបាត់បង់ឥទ្ធិពលរបស់ខ្លួនទៅលើប្រទេស *ភូមា តុងកឹង* និង *អាណាម* ដែលបានធ្លាក់ចូលក្នុងរង្វង់ឥទ្ធិពលនៃប្រទេសអង់គ្លេស និងបារាំងវិញ ។ ហើយនៅពេលដែលចិនច្បាំងចាញ់ជប៉ុននៅឆ្នាំ ១៨៩៥ មហាអំណាចទាំងឡាយបានគិតគ្នាថា ឱកាសដែលត្រូវយកទឹកដីចិនមកពុះចែកគ្នា បានមកដល់ហើយ ។

ដូចនេះ ប្រទេសអង់គ្លេសនិងប្រទេសអាឡឺម៉ង់បានយកកំពង់ផែពីរដែលឋិតនៅតំបន់សានទុង មកចែកគ្នាម្នាក់ៗ បារាំងបានយកកំពង់ផែមួយនៅប៉ែកខាងត្បូង ចំណែករូស៊ីវិញ ដណ្ដើមយកតំបន់លាវទុង (Liao Toung) ដើម្បីកសាងកំពង់ផែអាធួ (Port Arthur) ។ល។

គ. ចលនានៃពួកបុកស័រ

ការដណ្ដើមយកទឹកដីមកចែកគ្នាបែបនេះបណ្ដាលឲ្យមានបះបោរជាខ្លាំង ពីសំណាក់អ្នកជាតិនិយម ។ ពួកអ្នកបះបោរឋិតនៅក្រោមដំណឹកនាំនៃសមាគមសំងាត់របស់ពួក *បុកស័រ* (Boxeurs) ដែលបានទទួលការឧបត្ថម្ភពីព្រះចៅអធិរាជិនី*ឈីហ៊ី*(Tseu-Hi)ផង ។ ពួកជនជាតិអឺរ៉ុបជាច្រើននាក់ ព្រមទាំងពួកអ្នកការទូតបរទេសបានត្រូវពួកអ្នកបះបោរជាតិចិនឡោមព័ទ្ធ ។ ដើម្បីរំដោះអ្នកទាំងនោះ មហាអំណាចអឺរ៉ុបបានបញ្ជូនកងទ័ពអន្តរជាតិមកទីក្រុងប៉េកាំង នៅឆ្នាំ ១៩០០ ។



*លោក ស៊ុន យ៉ាត សេន (១៨៦៦-១៩២៥)*

សង្គ្រាមក៏បានកើតឡើងជាថ្មីទៀត ហើយប្រទេសចិនក៏ត្រូវបរាជ័យដែរ ជាហេតុនាំឲ្យចិនត្រូវបាត់បង់ទឹកដីនិងសេរីភាព កាន់តែខ្លាំងឡើងទៀត ។

## ៣. ប្រទេសចិននៅដើមសតវត្សទី ២០

បរាជ័យចិនក្នុងសង្គ្រាមជាមួយនឹងជប៉ុន នៅឆ្នាំ ១៨៩៥ ហើយនិងបរាជ័យរបស់សមាគមនៃពួកបុកស័រនៅឆ្នាំ ១៩០០ បានធ្វើឲ្យពួកអ្នកជាតិនិយមអាម៉ាស់មុខយ៉ាងខ្លាំង ។ ហេតុការណ៍ទាំងនេះបានបង្ហាញឲ្យពួកបញ្ញវន្តចិនឃើញច្បាស់ នូវការចាំបាច់នៃការរៀបចំប្រទេសចិនឡើងវិញ ដើម្បីរំដោះប្រទេសឲ្យចាកផុតពីអនាធិបតេយ្យដ៏ធ្ងន់ធ្ងរ និងកំចាត់ពួក

អាណានិគមបរទេសចេញពីប្រទេសផង ៗ

ចលនារំដោះជាតិក៏បានកើតឡើងក្នុងប្រទេសចិន ៗ ប៉ុន្តែ ចលនានេះមានបែកជាច្រើនក្រុម មានកម្មវិធីនិងឧត្តមគតិផ្សេងៗគ្នា ៗ ពួកនិន្នាការកណ្តាលចង់រក្សារបបរាជានិយម ៗ ឯពួកបដិវត្តចង់ឲ្យចិនក្លាយទៅជាសាធារណរដ្ឋ ៗ មេដឹកនាំពួកបដិវត្តគឺលោកវេជ្ជបណ្ឌិត *ស៊ុន យ៉ាត សេន* (Sun Yat Sen) ៗ នៅឆ្នាំ ១៩០៥ លោកបានបង្កើតគណបក្សនយោបាយមួយឈ្មោះ *ក្វូមីងតាង*(Kuo Min Tang = គណបក្សប្រជាធិបតេយ្យជាតិនិយម) ៗ កម្មវិធីនៃគណបក្សនេះគឺរៀបចំធ្វើបដិវត្តន៍បីយ៉ាងនៅប្រទេសចិន គឺ *បដិវត្តន៍ជាតិនិយម បដិវត្តន៍នយោបាយ* និង *បដិវត្តន៍សង្គមកិច្ច* ៗ

ដើម្បីរារាំងកុំឲ្យបដិវត្តន៍មានដំណើរលឿនខ្លាំងពេក ព្រះចៅអធិរាជិនីឈីហ៊ុ បានសន្យានៅឆ្នាំ ១៩០៦ ថានឹងតាំងឲ្យមានរដ្ឋាភិបាលថ្មីតាមលក្ខណៈរដ្ឋធម្មនុញ្ញ ៗ ប៉ុន្តែព្រះចៅអធិរាជិនីបានចូលទិវង្គតទៅនៅឆ្នាំ ១៩០៨ ៗ ដោយព្រះអង្គម្ចាស់រជ្ជទាយាទមានព្រះជន្មតិចពេក គេក៏បានតាំងក្រុមរាជានុសិទ្ធិឲ្យគ្រប់គ្រងប្រទេសជំនួស ៗ ក្រុមរាជានុសិទ្ធិបានធ្វើនយោបាយខ្លាំងក្លាជាច្រើន ជាហេតុនាំឲ្យអនាធិបតេយ្យនិងចលនាបដិវត្តកាន់តែរីកធំឡើងទៀតយ៉ាងឆាប់រហ័ស ៗ

នៅឆ្នាំ ១៩១១ បដិវត្តន៍បានរាលដាលដល់ភូមិភាគកណ្តាលនិងខាងត្បូងនៃប្រទេសចិនរហូតដល់ *ទីបេ តួកេស្តាន* (Turkestan) និង *ម៉ុងគោល* ៗ ប្រទេសម៉ុងគោលបានឆ្លៀតឱកាសនេះដើម្បីទាមទារស្វ័យភាពរបស់ខ្លួន ៗ

ពួកសាធារណរដ្ឋបានតាំងរដ្ឋាភិបាលមួយនៅក្រុង *សាំងហាយ* ដែលមានលោក *ស៊ុនយ៉ាតសេន* ជានាយក ៗ ក្រុមរាជានុសិទ្ធិបានបញ្ជូនឧត្តមសេនីយ *យន់សីខាយ* (Yuan Che Kai) ឲ្យទៅបង្ក្រាបពួកបដិវត្ត តែឧត្តមសេនីយនេះត្រលប់ទៅចូលដៃជាមួយនឹងពួកបដិវត្តទៅវិញ ៗ ក្រោយមកទៀត លោកយនសីខាយបានដណ្តើមយកអំណាចពីលោកស៊ុនយ៉ាតសេន ដោយបង្ខំលោកឲ្យលាពីមុខតំណែង រួចក៏ប្រកាសតាំងខ្លួនធ្វើជាប្រធានាធិបតី ៗ នៅថ្ងៃទី ១ ឧសភា ១៩១៤ លោកយន់សីខាយបានប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញមួយ ដែលធ្វើឲ្យលោកក្លាយទៅជាអ្នកកាន់អំណាចផ្តាច់ការតែម្នាក់ឯង ៗ

អាណាខេត្តទាំងឡាយដែលឋិតនៅឆ្ងាយៗ ហើយដែលធ្លាប់ទទួលស្គាល់តែអំណាច

របស់ព្រះចៅអធិរាជ បាននាំគ្នាបះបោរប្រឆាំងនឹងអំណាចសាធារណរដ្ឋផ្ដាច់ការ ។ រុស្ស៊ី និងជប៉ុនបានឆ្លៀតឱកាសនេះ ដណ្ដើមយកប្រទេសម៉ុងហ្គោលចែកគ្នា ។ ចំណែកឯអង់គ្លេសវិញ គេបានដណ្ដើមយកទីបេប៉ែកខាងត្បូងដែរ ។

ដូចនេះ នៅពេលដែលសង្គ្រាមលោកលើកទី ១ បានកើតឡើង ប្រទេសចិនកំពុងតែឋិតនៅក្នុងអនាធិបតេយ្យដ៏ធ្ងន់ ។ ជប៉ុនបានឆ្លៀតឱកាសនេះ (ឱកាសដែលចិនកំពុងធ្លាក់ទៅក្នុងអនាធិបតេយ្យ និងឱកាសដែលមហាអំណាចនៅអឺរ៉ុបកំពុងតែជាប់ក្នុងសង្គ្រាមលោកលើកទី ១) ដើម្បីពង្រីកឥទ្ធិពលរបស់ខ្លួនទៅលើប្រទេសចិន ឲ្យកាន់តែខ្លាំងឡើងមួយកំរិតថែមទៀត ។

## ខ. ប្រទេសជប៉ុន

### ១. ប្រទេសជប៉ុនមុនអន្តរាគមន៍របស់អឺរ៉ុប

បើប្រៀបធៀបទៅនឹងប្រវត្តិសាស្ត្រចិន ប្រវត្តិសាស្ត្រជប៉ុនជាប្រវត្តិសាស្ត្រថ្មីថ្មោង ហើយអរិយធម៌ជប៉ុនបានទទួលឥទ្ធិពលជាច្រើនពីអរិយធម៌ចិន ។ របបគ្រប់គ្រងជប៉ុនបុរាណមានលំនាំបែបរបបសក្តិភូមិនៅអឺរ៉ុបនាមជ្ឈិមសម័យ ។

កាលពីដំនាន់ដើម ប្រទេសជប៉ុនឋិតនៅក្រោមអំណាចរបស់ *មីកាដូ* (Mikado) គឺព្រះចៅអធិរាជ ដែលជនជាតិជប៉ុនចាត់ទុកដូចជាតំណាងអាទិទេពនៅលើផែនដីនេះ ។ ប៉ុន្តែ ជំនាន់ក្រោយមកទៀត អភិជនជប៉ុនម្នាក់បានទទួលឋានន្តរសក្តិជា *ស្យូហ្គុន*(១) (Chogoun) គឺមេទ័ព ហើយបានដណ្ដើមយកអំណាចទាំងអស់ពីព្រះចៅអធិរាជមកកាន់កាប់ ដោយទុកអំណាចតែមួយគត់ថ្វាយព្រះចៅអធិរាជ គឺអំណាចខាងសាសនា ។

បន្ទាប់ពីស្យូហ្គុន មានពួក *ដៃមីយ៉ូ* (Daimïos) ជាស្ដេចត្រាញ់ ដែលមានអំណាចត្រួតត្រាលើតំបន់នានាក្នុងប្រទេសជប៉ុន ដោយប្រើប្រាស់ពួក*សាមូរ៉ៃ* (Samouraïs) ជាអ្នកការពារ ។ ពួកសាមូរ៉ៃជាទាហានមានសេចក្ដីក្លាហានអង់អាច ស្ទាត់ជំនាញខាង

---

(១) *ពួកនេះអ្នកខ្លះហៅ «តៃគុន»*



*សូគុន យ៉ូស៊ីណូប៊ូតូគូកាវ៉ា (១៨៧៦)*

យុទ្ធសាស្ត្រ ដូចពួកស៊ីវ៉ាល្យេ (Chevalier) នៅអឺរ៉ុបនាមជ្ឈិមសម័យដូចនោះដែរ ។

ដូចនេះ ផ្ទុយពីជនជាតិចិនដែលមិនចូលចិត្តធ្វើទាហាន ជនជាតិជប៉ុនបានលើកតំកើងវិជ្ជាជីវៈនេះណាស់ ។ ម្យាងទៀត ជប៉ុនមានរបបគ្រប់គ្រងប្រកបដោយឯកភាព និងមានរបៀបរៀបរយ តឹងរ៉ឹងទៀតផង ។

## ២. ប្រទេសជប៉ុនក្រោយអន្តរាគមន៍របស់អឺរ៉ុប

ដូចជនជាតិចិនដែរ ជនជាតិជប៉ុនបានប្រឆាំងនឹងការមកតាំងនៅរបស់ពួកបរទេសក្នុងទឹកដីរបស់ខ្លួន ។

មុនដំបូងមានតែជនជាតិ *ហូឡង់* (Hollandais) ទេ ដែលមានសិទ្ធិខ្លះដើម្បីផ្ទុកទំនិញនៅកំពង់ផែណាហ្គាសាគី (Nagasaki) ។ ក្រោយមក *សហរដ្ឋអាមេរិច*បានបង្ខំជប៉ុនឲ្យបើកទ្វារទទួលឥទ្ធិពលពីបរទេស ហើយនៅឆ្នាំ១៨៥៤ ស.រ.អ. បានចូលទៅធ្វើជំនួញនៅតាមកំពង់ផែខ្លះនៃប្រទេសជប៉ុន ។



*ព្រះចៅអធិរាជ មូជីហ៊ីតុ (១៨៥២-១៩១២)*

ការអនុញ្ញាតពួកបរទេសឲ្យចូលទៅក្នុងប្រទេសយ៉ាងនេះ បណ្ដាលឲ្យមានចលាចលជាខ្លាំងហើយស្ហូគុនក៏ត្រូវបានគេសំលាប់ក្នុងពេលនោះ ។ ឆ្លៀតឱកាសនេះ ព្រះចៅអធិរាជ *មូស៊ីហ៊ីតុ* (Mutsu Hito) បានយកអំណាចទាំងអស់ ដែលត្រូវបាត់បង់ជាយូរមកហើយនោះ មកកាន់កាប់វិញ នៅឆ្នាំ ១៨៦៨ ។

ចាប់តាំងពីពេលនោះមក ប្រទេសជប៉ុនបានចំហទ្វារយ៉ាងធំទទួលឥទ្ធិពលពីអឺរ៉ុប ។ ព្រះចៅអធិរាជមូស៊ីហ៊ីតុបានប្រកាសលុបរបបសក្ដិភូមិចោល ហើយបានរៀបចំគ្រប់គ្រងប្រទេស តាមបែបអឺរ៉ុប ដោយ :

— បញ្ចូលលទ្ធិប្រជាធិបតេយ្យ
— បង្កើតច្បាប់រដ្ឋធម្មនុញ្ញតាមបែបប្រទេសព្រុស (Prusse) *(១)*
— ប្រកាសសមភាពដល់ប្រជាពលរដ្ឋ
— បញ្ចូលកាតព្វកិច្ចសិក្សាក្នុងបឋមភូមិ
— រៀបចំកងទ័ពជើងទឹក ជើងគោក
— រៀបចំតុលាការ
— រៀបចំសេដ្ឋកិច្ច មានឧស្សាហកម្មជាដើម ។ល។

ក្នុងរយៈកាលដ៏ខ្លី ប្រទេសជប៉ុនបានក្លាយទៅជាមហាអំណាច មានការរីកចំរើនលូតលាស់ទាន់ប្រទេសទាំងឡាយនៅអឺរ៉ុប ។ ព្រះចៅអធិរាជ មូស៊ីហ៊ីតុ បានធ្វើឲ្យប្រទេសជប៉ុនស្គាល់នូវសម័យកាលមួយថ្មី ប្រកបទៅដោយពន្លឺរស្មីត្រចះត្រចង់ឈ្មោះ *សម័យមុំអ៊ីយិ* (Ere du Meiji) គឺសម័យកាលចំរុងចំរើន ។

លុះបានចំរើនយ៉ាងនេះហើយ ជប៉ុនក៏បានអនុវត្តនយោបាយអាណានិគម ដូចជាមហាអំណាចទាំងឡាយនៅអឺរ៉ុបដែរ ។ ជប៉ុនបានច្បាំងនឹងចិននៅឆ្នាំ ១៨៩៤ ដើម្បីដណ្ដើមយកប្រទេសកូរ៉េ ។ ជ័យជំនះក្នុងសង្គ្រាមនេះបានអនុញ្ញាតជប៉ុនឲ្យដណ្ដើមយកកោះថាយវ៉ាន់ (Formose) ពីចិនថែមទៀត ។

---

*(១) ក្នុងរដ្ឋធម្មនុញ្ញបែបនេះ រដ្ឋសភាពុំមានអំណាចត្រួតពិនិត្យលើគណៈរដ្ឋមន្ត្រីទេ តែគ្រាន់តែជាអង្គការមួយសំរាប់ជួយផ្ដល់យោបល់ដល់គណៈរដ្ឋមន្ត្រីប៉ុណ្ណោះ ។*

នៅឆ្នាំ ១៩០៤ - ១៩០៥ ជប៉ុនបានធ្វើសង្គ្រាមជាមួយនឹងរូស៊ីប្រកបដោយជោគជ័យទៀត ។ សន្ធិសញ្ញាសន្តិភាពរវាងជប៉ុននិងរូស៊ីបានត្រូវចុះហត្ថលេខានៅក្រុងជតស្មៅ (Portsmouth) ដោយមានលោកប្រធានាធិបតី រូស្វែល (Roosevelt) ធ្វើជាអាជ្ញាកណ្តាល ។ តាមសន្ធិសញ្ញានេះ រូស៊ីត្រូវថយចេញពីម៉ាន់ជូរី ហើយជប៉ុនត្រូវបានតំបន់លាវទុង ដោយមានកំពង់ផែអាថួរផង ព្រមទាំងបានតំបន់សាខាលីន (Sakhaline) ភាគខាងត្បូងថែមទៀត ។



*សភាឌៀតនៅឆ្នាំ ១៨៩០*

## ៣. ប្រទេសជប៉ុននៅដើមសតវត្សទី ២០

នៅដើមសតវត្សទី ២០ ប្រទេសជប៉ុនបានក្លាយទៅជាមហាអំណាចមួយ ដូចជា

ប្រទេសទាំងឡាយនៅអឺរ៉ុបដែរ ។ ប៉ុន្តែ ស្របជាមួយនឹងការចំរើន ប្រទេសនេះក៏បានជួបប្រទះនឹងបញ្ហាជាច្រើនដែរ ។

ប្រទេសជប៉ុនជាកោះប្រកបទៅដោយភ្នំជាច្រើន គ្មានលទ្ធភាពនឹងបង្កើតផលិតផលកសិកម្មឲ្យបានគ្រប់គ្រាន់ដើម្បីចិញ្ចឹមប្រជាជន ដែលចេះតែកើនចំនួនជាលំដាប់រៀងរាល់ឆ្នាំ ។ រីឯការចំរើនខាងឧស្សាហកម្មវិញ បានបណ្តាលឲ្យមានកង្វះខាតវត្ថុធាតុដើមជាច្រើន ព្រមទាំងត្រូវរកផ្សារសំរាប់លក់ទំនិញ ដែលផលិតចេញពីរោងចក្ររបស់គេ ។

បញ្ហាកំណើនប្រជាជនឆាប់ហួសហេតុពុំថ្លឹងនឹងទំហំទឹកដីនៃប្រទេស ជាហេតុញុាំងជនជាតិជប៉ុនជាច្រើន ឲ្យចាកចេញពីប្រទេសរបស់ខ្លួនទៅតាំងនៅឯបរទេស ។ ប៉ុន្តែ



ភាពប្រយុទ្ធក្នុងសមុទ្រលឿងរវាងចិននិងជប៉ុន (កញ្ញា ១៨៩៤)

ប្រទេសទាំងឡាយដែលជនជាតិជប៉ុនធ្លាប់បានទៅតាំងនៅ ដូចជាឥណ្ឌូនេស៊ី អូស្ត្រាលី សហរដ្ឋអាមេរិច និងកាណាដា បានបិទទ្វារលែងអនុញ្ញាតជនជាតិនេះឲ្យចូលទៅតាំងនៅតទៅទៀត ។ ម៉្លោះហើយ ជប៉ុនក៏ងាកមករកប្រទេសចិនជាអ្នកជិតខាងវិញ ដែលមានទឹកដីធំទូលាយ សំបូរទៅដោយវត្ថុធាតុដើម ហើយដែលអាចទៅជាផ្សារមួយយ៉ាងធំសំរាប់សេដ្ឋកិច្ចរបស់គេ ។ ប៉ុន្តែ ការវាតទីរបស់ជប៉ុនទៅលើប្រទេសនេះបានប៉ះទង្គិចជាមួយនឹង ស.រ.អ. ជាហេតុនាំឲ្យមានទំនាស់រវាងប្រទេសទាំងពីរនេះ រហូតដល់ក្លាយទៅជាមានសង្គ្រាមរវាងគ្នា ។

ប្រទេសចិននិងប្រទេសជប៉ុន កាលដើមឡើយ មានអរិយធម៌ ប្រហាក់ប្រហែលគ្នា ក្រោយមក បានក្លាយទៅជាប្រទេសពីរខុសគ្នាយ៉ាងខ្លាំង តែក្នុងរយៈកាល ប្រហែលជាងកន្លះសតវត្សប៉ុណ្ណោះ ។ មិនតែប៉ុណ្ណោះ ជប៉ុនបានទាំងពង្រីកអាណានិគមរបស់ខ្លួនទៅលើប្រទេសចិនថែមទៀត ថ្វីត្បិតតែប្រទេសចិនមានទឹកដីធំទូលាយ និងមានប្រជាជនច្រើនលើសលុបជាងប្រទេសជប៉ុនក៏ដោយ ។

## សំណួរ

១. ប្រៀបធៀបប្រទេសចិន និងជប៉ុន :

ក. នៅសម័យមុនអន្តរាគមន៍របស់អឺរ៉ុប

ខ. នៅសម័យក្រោយអន្តរាគមន៍របស់អឺរ៉ុប ។

២. ការប្រៀបធៀបខាងលើនេះបានបង្ហាញឲ្យឃើញថា ប្រទេសចិននិងជប៉ុនបានក្លាយទៅជាប្រទេសពីរខុសគ្នាយ៉ាងខ្លាំង ។ រកបុព្វហេតុមកពន្យល់បំលាស់ប្តូរនេះ ។



ប្រទេសចិននិងប្រទេសជប៉ុននៅឆ្នាំ ១៩១៤

## កំណត់សំគាល់

| | | | |
|---|---|---|---|
| ( ជ. ) | ជប៉ុន | ( ប. ) | បារាំង |
| ( អ. ) | អង់គ្លេស | ( ស.រ.អ. ) | សហរដ្ឋអាមេរិច |
| ( អា. ) | អាឡឺម៉ង់ | ( រ.ស. ) | រូស៊ី |

# ៩. ការប្រកួតប្រជែងខាងសេដ្ឋកិច្ច និងខាងអាណានិគម

ឆ្នាំ ១៩០៤-១៩០៥ ជាឆ្នាំដែលប្រទេស*បារាំង* និងចក្រភព*អង់គ្លេស* បានវិតចូលជិតគ្នា ជាឆ្នាំដែលប្រទេស*រុស្ស៊ី* ត្រូវទទួលបរាជ័យមួយយ៉ាងធ្ងន់ ក្នុងចំបាំងជប៉ុន-រុស្ស៊ី នៅម៉ាន់ជូរី ជាឆ្នាំដែលធ្វើឲ្យនយោបាយនៅ*ទ្វីបអឺរ៉ុប*ឈានចូលក្នុងទំព័រប្រវត្តិសាស្ត្រថ្មីមួយទៀត ជាឆ្នាំដែលប្រកបទៅដោយវិបត្តិផ្សេងៗនិងទៅដោយស្ថានការណ៍តានតឹងជាលំដាប់ៗ

## ១. មហាអំណាចទ្វីបអឺរ៉ុប

មកដល់ឆ្នាំ ១៩១៤ នៅទ្វីបអឺរ៉ុប មានរដ្ឋតែ ៥ ទេ ដែលជាមហាអំណាចធំជាងគេ ហើយជាអ្នកដឹកនាំនយោបាយពិភពលោកទាំងមូលទៀតផង ។ ប៉ុន្តែ មហាអំណាចទាំងនេះមានការលូតលាស់មិនស្មើគ្នាឡើយ ។

### ក. ប្រទេសរុស្ស៊ី និងប្រទេសអូទ្រីស - ហុងគ្រី

ប្រទេសទាំងពីរនេះទើបតែចាប់ផ្ដើមរៀបចំសេដ្ឋកិច្ចរបស់ខ្លួនឲ្យទាន់សម័យ ឲ្យមានលក្ខណៈជាសេដ្ឋកិច្ចរបៀបទំនើប ។ ឧស្សាហកម្មមានសភាពអន់ថយនៅឡើយ ។ តាមក្រុងទាំងឡាយ រោងចក្រមានតិចតួចស្ទួចស្ដើង ។ ផ្លូវថេភ្លើងពុំសូវលូតលាស់ ហើយភាគច្រើនៃប្រជាជនជាអ្នកស្រែចំការ ប្រកបមុខរបរកសិកម្ម ។

### ខ. សាធារណរដ្ឋបារាំង

សាធារណរដ្ឋបារាំងជាប្រទេសប្រកបដោយ*ឧស្សាហកម្មទំនើប* ហើយមានមធ្យោបាយដឹកនាំលូតលាស់ទាន់សម័យ ។ កសិកម្មមានវិវត្តន៍យឺតយ៉ាវ ។ កសិកម្មរបៀបទំនើបក៏ពុំសូវមានដែរ ។ តែសាធារណរដ្ឋបារាំងជាមហាអំណាចអាណានិគមមួយខ្លាំង

ពូកែ មានទឹកដីឯនាយសមុទ្រច្រើននៅគ្រប់ទ្វីប ។ ប្រាក់បារាំងទៀតសោតមានជំហររឹងប៉ឹង ទុកជារូបិយប័ណ្ណអន្តរជាតិដូចប្រាក់ដូឡាសព្វថ្ងៃនេះដែរ ។

គ. ចក្រភពអង់គ្លេស

ចក្រភពអង់គ្លេសជាមហាអំណាចអាណានិគមមួយ មានឫទ្ធានុភាពខ្លាំងក្លាណាស់ ។ មកទល់នឹងដើមសតវត្សទី ២០ ចក្រភពអង់គ្លេសជា*មហាអំណាចលេខ ១ ខាងសេដ្ឋកិច្ច* នៅក្នុងទ្វីបអឺរ៉ុប ។ បដិវត្តន៍ខាងសេដ្ឋកិច្ចបានប្រព្រឹត្តនៅចក្រភពអង់គ្លេសមុនគេបង្អស់ គឺចាប់តាំងពីដើមសតវត្សទី ១៩ មកម៉្លេះ ។ ម៉្លោះហើយ ចក្រភពអង់គ្លេសមានឧស្សាហកម្មល្អលើសគេ (មានឧស្សាហកម្មធ្ងន់ច្រើន-ត្បូងថ្ម ដែកថែប លេខ ១ ក្នុងលោក) ។

ម្យ៉ាងទៀត ចក្រភពអង់គ្លេសមានទឹកដីរណបធំជាងគេ (៣១ លានគីឡូម៉ែត្រក្រឡា ៣០០ លាននាក់) គឺ ១ ភាគ ៤ នៃមនុស្សក្នុងលោកយើងទាំងមូល ។ ប៉ុន្តែ មកទល់នឹងឆ្នាំ ១៩១៤ មហាចក្រភពអង់គ្លេសត្រូវគេគំរាមកំហែង គឺចក្រភពអាល្លឺម៉ង់ ។

ឃ. ចក្រភពអាល្លឺម៉ង់

ក្នុងដើមសតវត្សទី ២០ ចក្រភពអាល្លឺម៉ង់ជាប្រទេសមួយដែលមានប្រជាជនច្រើនជាងគេនៅអឺរ៉ុបប៉ែកខាងលិច ជាប្រទេសប្រកបដោយ *ភោគទ្រព្យធនធានច្រើន* ។ ឧស្សាហកម្មអាល្លឺម៉ង់ល្អលើសយ៉ាងចាប់ក្រៃលែង ។ ពាណិជ្ជកម្ម និងឧស្សាហកម្មអាល្លឺម៉ង់តែងតែប្រកួតប្រជែងនឹងឧស្សាហកម្មនិងពាណិជ្ជកម្មអង់គ្លេស ហើយច្រើនតែទទួលជោគជ័យទៀតផង ។ ប្រទេសអាល្លឺម៉ង់ជាប្រទេសមានកងទ័ពច្រើនជាងគេ ប្រកបដោយអាវុធយុទ្ធភណ្ឌយ៉ាងទំនើប ហើយមានអ្នកដឹកនាំនិងវិន័យយ៉ាងម៉ត់ចត់ ។ ប្រទេសអាល្លឺម៉ង់មានបំណងត្រួតត្រាលើសមុទ្រនានាថែមទៀត ។ នាវាអាល្លឺម៉ង់មានឋានៈលេខ ២ ក្នុងលោក បន្ទាប់ពីចក្រភពអង់គ្លេស ជាហេតុធ្វើឲ្យចក្រភពអង់គ្លេសមានសេចក្តីព្រួយបារម្ភយ៉ាងខ្លាំង ។

## ២. ការប្រណាំងប្រជែងខាងសេដ្ឋកិច្ច

ដូចយើងបានឃើញគ្រួសៗមកពីខាងលើហើយថា មហាអំណាចទាំង ៥ ទំពាំងរីក

ឧស្សាហកម្មតែរៀងៗខ្លួន ៗ ទាំងអស់គ្នា គេធ្វើឧស្សាហកម្មឲ្យលូតលាស់ឆាប់រហ័សទាន់សម័យ ដើម្បីយកឈ្មោះតែសព្វខ្លួន ៗ នៅប្រទេសអាល្លឺម៉ង់ ការលូតលាស់មានសន្ទុះលឿនណាស់ ជាហេតុនាំឲ្យមហាអំណាចឯទៀតៗព្រួយបារម្ភជានិច្ច ៗ ការប្រណាំងប្រជែងរវាងមហាអំណាចទាំងនេះមានសភាពរឹតតែស្វិតស្វាញឡើងៗ ៗ ក្នុងពិភពលោកយើងទាំងមូល គេប្រកួតប្រណាំងដណ្តើមផ្សារគ្នា ដណ្តើមសម្បទានអណ្តូងរ៉ែ ឬផ្លូវរទេះភ្លើង ៗ គេដណ្តើមគ្នាទទួលធ្វើការសាធារណៈនៅបរទេសនិងលក់អាវុធយុទ្ធភណ្ឌទៅឲ្យប្រទេសនានា ។ល។

ជួនកាល រដ្ឋាភិបាលជួយការពារផលប្រយោជន៍ជនជាតិរបស់គេ ក្នុងការប្រកួតប្រណាំងដណ្តើមគ្នានេះ ជាហេតុនាំឲ្យការប្រណាំងប្រជែងខាងសេដ្ឋកិច្ចប្រែក្លាយទៅជាការប្រណាំងប្រជែងខាងនយោបាយទៀតផង ។

## ៣. ការប្រណាំងប្រជែងខាងអាណានិគម

នៅជំណាច់សតវត្ស ទី ១៩ ពិភពលោកទាំងមូលត្រូវបានបែងចែកជាស្រេចរវាងមហាអំណាចអង់គ្លេស បារាំង រុស្ស៊ី អាល្លឺម៉ង់ អ៊ីតាលី និងសហរដ្ឋអាមេរិច ៗ ប្រទេសអាល្លឺម៉ង់បានចំណែកតិចជាងគេ គឺតិចជាងចក្រភពអង់គ្លេស និងសាធារណរដ្ឋបារាំង ៗ ចក្រភពអង់គ្លេសត្រូវបានទទួលចំណែកធំជាងគេខាងអាណានិគម ៗ ប្រទេសអង់គ្លេសជាប្រទេសលេខ ១ ក្នុងលោក ខាងវិស័យពាណិជ្ជកម្ម ហើយនិងការដឹកមូលធនចេញទៅរកស៊ីនៅបរទេស ៗ ក្នុងករណីនេះ ប្រទេសអាល្លឺម៉ង់មានគំនិតចង់សើរើបែងចែកពិភពលោកម្តងទៀត ដែលជាឧបសគ្គមួយយ៉ាងសំបើមចំពោះចក្រភពអង់គ្លេស ៗ

នៅដើមសតវត្សទី ២០ ទំនាស់រវាងមហាអំណាចអាណានិគមទាំងឡាយ មានសភាពរឹតតែខ្លាំងឡើងៗ ៗ យ៉ាងណាមិញ ការលូតលាស់យ៉ាងឆាប់រហ័សនៃឧស្សាហកម្មបានបង្កើតឲ្យមានចក្រពត្តិនិយម ពោលគឺនយោបាយរុករានយកប្រទេសដទៃមកធ្វើជាអាណានិគមរបស់ខ្លួន ៗ

ក្នុងករណីនេះ ប្រទេសអង់គ្លេសដែលបានស្គាល់អរិយធម៌ខាងឧស្សាហកម្មមុនគេ បានដណ្តើមយកប្រទេសអាណានិគមច្រើនជាងគេដែរ ហើយចក្រភពអង់គ្លេសត្រូវតែយាម

ល្បាតអាណានិគមរបស់ខ្លួន ដោយប្រកាន់ខ្ជាប់នូវគោលការណ៍នយោបាយពីរយ៉ាងគឺម្យ៉ាង រក្សានូវឧត្តមភាពលើសមុទ្រ និងមហាសមុទ្រទាំងឡាយ ម្យ៉ាងទៀត គឺពិនិត្យត្រួតត្រាផ្លូវ ឆ្ពោះទៅកាន់ប្រទេសឥណ្ឌា ។

ចំណែកប្រទេសបារាំង គេចង់បង្ហើយការស្ថាបនាអាណានិគមរបស់គេ នៅទ្វីបអាព្រិច ដោយភ្ជាប់ប្រទេសម៉ារ៉ុកឲ្យចូលមកក្នុងអំណាចរបស់គេ ។ ប្រទេសអ៊ីតាលីដែលត្រូវគេ ទាត់ចេញពីប្រទេសទុយនីស៊ី និងប្រទេសអេត្យូពី (Ethiopie) បានវាតយកតំបន់ទ្រីប៉ូលីតែន (Tripolitaine) ហើយបានគ្រប់គ្រងលើផ្លូវសមុទ្រអាឌ្រីយ៉ាទិច (Adriatique) ឆ្នេរសមុទ្រ ប៉ែកបស្ចិមនៃតំបន់បាល់កង់ ។

ម្យ៉ាងទៀត ឧបទ្វីបបាល់កង់ (Balkans) ជាតំបន់មួយគ្មានស្ថិរភាពបន្តិចណាឡើយ ហើយជាតំបន់ដែលប្រទេសរូស៊ី និងប្រទេសអូទ្រិស វាតឥទ្ធិពលរបស់ខ្លួន ។

ប្រទេសរូស៊ី ដែលបានទទួលបរាជ័យយ៉ាងជូរចត់នៅចុងបូព៌ាប្រទេស ក្នុងចំបាំងរូស៊ី ជប៉ុន (១៩០៥) បានត្រឡប់មករកគោលដៅចាស់របស់ខ្លួនវិញ គឺវាតយកក្រុងកុងស្តង់ ទីណូប (Constantinople) និងច្រកសមុទ្រ បូស្វរ (Bosphore) និង ដាដាណែល (Dardanelles) ។

ប្រទេសអូទ្រិសចង់ដណ្តើមយកដែសាឡូនិច (Salonique) ហើយនិងគ្រប់គ្រងលើ ប្រទេសស៊ែប៊ី (Serbie) ដែលរាំងផ្លូវខ្លួន ។ នេះជាបញ្ហាស្មុគស្មាញមួយ ពីព្រោះនៅ ក្នុងប្រទេសអូទ្រិសមានជនជាតិស្លាវរាប់លាននាក់ ដែលនិយមប្រទេសស៊ែប៊ី ដែលជា រដ្ឋសេរី ។

ចំណែកប្រទេសអាឡឺម៉ង់វិញ មិនត្រឹមតែជាមហាអំណាចលើទ្វីបប៉ុណ្ណោះទេ គឺចង់ បានជាមហាអំណាចលើសមុទ្រ និងលើពិភពលោកយើងទាំងមូលថែមទៀត ។ ដោយ គ្មានដីសេសសល់នឹងត្រួតត្រា មហាអំណាចអាឡឺម៉ង់បានសំលឹងមើលគ្រប់ទិសទី គឺសំ លឹងមើលប្រទេសតួកីភាគអាស៊ី តែក្នុងតំបន់នោះ ឧបសគ្គបានរង់ចាំខ្លួនជាស្រេច គឺ ចក្រភពអង់គ្លេសនិងប្រទេសរូស៊ីសំលឹងលើប្រទេសម៉ារ៉ុក តែត្រូវពាររលើសាធារណរដ្ឋបារាំង

សំលឹងលើប្រទេសអាព្រិចប៉ែកអេក្វាទ័រ តែត្រូវបណ្ដេញអ្នកត្រួតត្រានៅទីនោះជាបឋម គឺប្រទេសបែលស៊ិចនិងប្រទេសពរទុយគេ ។

ចក្រពត្តិនិយមអាឡឺម៉ង់ជាចក្រពត្តិមួយដែលមានកម្មវិធីសាំញាំពុំច្បាស់លាស់ឡើយ តែមានមូលដ្ឋានសេដ្ឋកិច្ចខ្លាំងជាងគេ ហើយមានកងទ័ពក្លាហានទៀតផង ។

ដូចនេះហើយ បានជាតាំងពីឆ្នាំ១៩០៤ ដល់ឆ្នាំ១៩០៥ ទ្វីបអឺរ៉ុបទាំងមូលបានឋិតនៅក្រោមការគំរាមកំហែងនៃចំបាំងជានិរន្តរ៍ ។ វិបត្តិមួយហើយមួយទៀតបានកើតឡើងដោយ *បញ្ហាម៉ារ៉ុក* និង *បញ្ហាបាល់កង់* បានធ្វើឲ្យសង្គ្រាមលោកហៀបនឹងផ្ទុះសឹងជាច្រើនលើក ។

ព្រឹត្តិការណ៍សំខាន់ៗក្នុងសម័យនោះមានដូចតទៅ ៖ ទស្សនកិច្ចនៃព្រះចៅអធិរាជគីយ៉ូមទី២ (Guillaume II) នៅក្រុងតង់សេក្នុងឆ្នាំ១៩០៥ បានបង្កើតឲ្យមានវិបត្តិ ជាលើកដំបូងមួយ រវាងបារាំងនិងអាឡឺម៉ង់ ។ សន្និសីទនៅទីក្រុង *អាល់សេស៊ីរ៉ា* នាឆ្នាំ១៩០៥ បានដោះស្រាយឲ្យចាកផុតពីវិបត្តិនេះ ជាហេតុនាំឲ្យមានសេចក្ដីព្រមព្រៀងរវាងប្រទេសអង់គ្លេស និងប្រទេសរូស៊ី (១៩០៧) ហើយនិងការស្ថាបនាសម្ព័ន្ធត្រីភាគីមួយ ។

ក្រោយមក វិបត្តិមួយទៀតបានកើតឡើងនៅឧបទ្វីបបាល់កង់ ដោយប្រទេសអូទ្រីសបញ្ចូលក្នុងប្រទេសខ្លួននូវខេត្ត បូសនី-អ៊ែរសេហ្គូវីន (Bosnie-Herzégovine) ក្នុងឆ្នាំ១៩០៨ ។

នៅឆ្នាំ ១៩១១ កងទ័ពបារាំងបានលុកចូលក្នុងក្រុង *ហ្វេ* (Fez) ជាហេតុនាំឲ្យប្រទេសអាឡឺម៉ង់បញ្ជូននាវាចំបាំងរបស់ខ្លួនមកចតចំមុខផែ *អាកាឌៀ* ដើម្បីកំហែងគំរាមបារាំង ។ វិបត្តិទី២ អំពីបញ្ហាម៉ារ៉ុកនេះ ត្រូវបានដោះស្រាយដោយការព្រមព្រៀងរវាងប្រទេសបារាំងនិងអាឡឺម៉ង់ ស្ដីពីបញ្ហាម៉ារ៉ុក និងបញ្ហាកុងគោ ។

ក្រោយមកទៀត មិនយូរប៉ុន្មាន មានការស្មុគស្មាញមួយបានកើតឡើងនៅ *ភូមិភាគមជ្ឈិម* ៖

— ប្រទេសអ៊ីតាលីបានចូលត្រួតត្រាលើតំបន់ទ្រីប៉ូលីតែន (១៩១១)

— ចំបាំងរវាងប្រទេសអ៊ីតាលីនិងប្រទេសតួគី (១៩១១-១៩១២)

— សម្ព័ន្ធនៃប្រទេសបាល់កង់ច្បាំងនឹងប្រទេសតួគី (១៩១២-១៩១៣) ។

ការពង្រីកទឹកដីនៃប្រទេសស៊ែប៊ី ប្រទេសក្រិច ប្រទេសរូម៉ានីជាហេតុការណ៍មួយដែលប្រទេសអូទ្រីសមិនអាចអត់ឱនបានឡើយ ។

ក្រៅពីវិបត្តិនៅបាល់កង់និងនៅប្រទេសម៉ារ៉ុក នៅចុងបូព៌ាប្រទេស ក៏មានកើតវិបត្តិមួយធំដែរ គឺវិបត្តិដែលកើតមកពីប្រទេសរូស៊ី និងប្រទេសជប៉ុន ដណ្ដើមយកដែនដី *ម៉ាន់ជូរី* ។ សង្គ្រាម *រូស៊ី-ជប៉ុន* ក៏ផ្ទុះក្នុងឆ្នាំ១៩០៤ ។ ដោយត្រូវទទួលបរាជ័យក្នុងចំបាំងនេះ ប្រទេសរូស៊ីត្រូវដកខ្លួនថយចេញពីអាណាខេត្តម៉ាន់ជូរី ប្រគល់ឱ្យប្រទេសជប៉ុននូវផែអាថូរនិងលាវទុង ព្រមទាំងភូមិភាគខាងត្បូងនៃកោះសាខាលីន ។ ម្យ៉ាងទៀត គេត្រូវទទួលស្គាល់របបអាណាព្យាបាលជប៉ុនលើប្រទេសកូរេថែមទៀត ។

ដូចនេះ ការប្រកួតប្រណាំងនៃមហាអំណាចទាំងនេះបានធ្វើឱ្យស្ថានការណ៍ពិភពលោកតានតឹងជាទីបំផុត ហើយសង្គ្រាមហៀបតែនឹងផ្ទុះជាច្រើនលើកច្រើនគ្រាផង ។

## សំណួរ

១. ពណ៌នាដោយសង្ខេបអំពីមហាអំណាចទ្វីបអឺរ៉ុប នៅឆ្នាំ១៩១៤ ។

២. អធិប្បាយអំពីការប្រកួតប្រណាំងខាងសេដ្ឋកិច្ច រវាងមហាអំណាចអឺរ៉ុប ។ ហេតុអ្វីបានជាការប្រកួតប្រណាំងនេះអាចបង្កើតឱ្យមានគ្រោះថ្នាក់ ?

៣. រៀបរាប់អំពីការប្រកួតប្រណាំងខាងអាណានិគម ។ ការប្រកួតប្រណាំងនេះបានប្រព្រឹត្តរវាងមហាអំណាចណាខ្លះ ? ក្នុងតំបន់ណាខ្លះ ?

៤. ទំនាស់រវាងមហាអំណាចអាណានិគមបង្កើតឱ្យមានស្ថានភាពដូចម្ដេច ?

# ១០. សង្គ្រាមលោកលើកទី ១
# ពីឆ្នាំ ១៩១៤ ដល់ ១៩១៨

តាំងពីឆ្នាំ ១៩០៧ ទំនាស់និងការប្រកួតប្រណាំងរវាងមហាអំណាចចក្រពត្តិនិយមទាំងឡាយបានបង្កើតឲ្យមាន «*ប្លុកសឹក*» ពីរ ។ ប្លុកទាំងពីរនេះជាសត្រូវនឹងគ្នា ហើយតែងតែកំហែងគំរាមគ្នាទៅវិញទៅមក ធ្វើឲ្យសន្តិសុខនៅទ្វីបអឺរ៉ុប ឆ្លងកាត់គ្រោះថ្នាក់ជាច្រើនលើកច្រើនគ្រា ។

*ប្លុកទី ១* ដែលគេហៅថា «*សម្ព័ន្ធត្រីភាគី*» មានប្រទេសអាល្លឺម៉ង់ ប្រទេសអូទ្រីស-ហុងគ្រី ប្រទេសអ៊ីតាលីជាសមាជិក ។

*ប្លុកទី ២* ដែលគេហៅថា «*អនុសញ្ញាត្រីភាគី*» មានប្រទេសបារាំង ប្រទេសអង់គ្លេសនិងប្រទេសរូស៊ីជាសមាជិក ។

## ១. បុព្វហេតុនៃចំបាំង

ការប្រយុទ្ធរវាងមហាអំណាចចក្រពត្តិនិយមនៃប្លុកទាំងពីរបានបង្កើតឲ្យមានមហាសង្គ្រាមលោកលើកទី ១ ។ សង្គ្រាមនេះជាសង្គ្រាមរាតត្បាតប្រកបដោយ *អយុត្តិធម៌ទាំងសងខាង* ។

ពេលនោះ ប្រទេស*អាល្លឺម៉ង់* ប្រយុទ្ធដើម្បីបែងចែកពិភពលោកជាថ្មីម្ដងទៀត ដើម្បីគ្រប់គ្រងមួយផ្នែកធំនៃទ្វីបអឺរ៉ុប និងដើម្បីស្ថាបនាឧត្តមភាពរបស់ខ្លួន លើពិភពលោកទៀតផង ។

ប្រទេស *អូទ្រីស-ហុងគ្រី* ប្រយុទ្ធដើម្បីត្រួតត្រាលើប្រជាជនឆេកូ-ប៉ូឡូញ ។ល។ ពោលគឺតំបន់បាល់កង់ទាំងមូល ។

*ចក្រភពអង់គ្លេស* ប្រយុទ្ធដើម្បីថែរក្សា និងពង្រីកអាណានិគមរបស់ខ្លួនថែមទៀត

ដើម្បីធ្វើឲ្យប្រទេសអាឡឺម៉ង់ទន់ខ្សោយ ដោយប៉ងប្រាថ្នាកំទេចនាវាចំបាំង បំបាត់ការប្រកួតប្រណាំងខាងពាណិជ្ជកម្ម ឧស្សាហកម្ម ហិរញ្ញវត្ថុនៃប្រទេសអាឡឺម៉ង់ ។

ប្រទេស *បារាំង* ប្រយុទ្ធដើម្បីភ្ជាប់តំបន់អាល់សាស-ឡូរ៉ែនមកក្នុងប្រទេសខ្លួន និងដើម្បីដណ្ដើមយកតំបន់សា ( Sarre ) ។

ចំណែកឯប្រទេស *រូស៊ី* វិញ គេប្រយុទ្ធដើម្បីកំចាត់ប្រទេស អាឡឺម៉ង់ និងប្រទេសអូទ្រីស-ហុងគ្រីចេញពីតំបន់បាល់កង់ ហើយនិងដើម្បីវាតអំណាចរបស់ខ្លួនក្នុងមជ្ឈមណ្ឌលនេះ ។

## ២. លេសនៃសង្គ្រាមលោកលើកទី ១

ការរៀបរាប់យ៉ាងសង្ខេបខាងលើនេះបានបង្ហាញឲ្យឃើញយ៉ាងច្បាស់ នូវបុព្វហេតុនៃសង្គ្រាម ។ បក្សសម្ព័ន្ធទាំងពីរមិនអាចចៀសវាងការប៉ះទង្គិចគ្នាបានឡើយ ។ បក្សនីមួយៗ ចាំរកឱកាសដើម្បីវាយគូសត្រូវរបស់ខ្លួន ។ ឱកាសល្អនេះបានហុចឲ្យគេ នៅថ្ងៃទី *២៨ មិថុនា ១៩១៤* ។ នៅថ្ងៃនេះព្រះអង្គម្ចាស់ *ប្រង់ស្វាហ្វែឌីណង់* ដែលជា



*ព្រះអង្គម្ចាស់ប្រង់ស្វាហ្វែឌីណង់ និងព្រះជាយានៅក្រុងសេរ៉ាសេវ៉ូ ប៉ុន្មានម៉ោងមុនសុគត*

អនុរាជនៃប្រទេស អូទ្រិស-ហុងគ្រី ត្រូវនិស្សិតសញ្ជាតិ ស៊ែប៊ី ធ្វើគុតនៅក្រុង *សេរ៉ាស៊ីវ៉ូ* (Serajevo) ។

ធ្លៀតយកលេសនេះ ប្រទេសអូទ្រិស-ហុងគ្រីបានប្រកាសសង្គ្រាមជាមួយនឹងប្រទេសស៊ែប៊ីភ្លាមនៅថ្ងៃទី *២៨ កក្កដា ១៩១៤* ។ ប្រទេសរូស៊ីមិនអាចនៅស្ងៀមបានឡើយ ហើយប្រកាសថាខ្លួននឹងការពារប្រទេសស៊ែប៊ី មិនបណ្ដោយឲ្យប្រទេសអូទ្រិស-ហុងគ្រីសំលាប់មិត្តរបស់ខ្លួនបានឡើយ ។

ថ្ងៃទី ១ សីហា ១៩១៤ អាឡឺម៉ង់បានប្រកាសចំបាំងនឹងប្រទេសរូស៊ី លុះដល់ថ្ងៃទី ៣ សីហាក៏ប្រកាសសង្គ្រាមនឹងប្រទេសបារាំងទៀត ។

ចក្រភពអង់គ្លេសបានចូលរួមក្នុងចំបាំងខាងប្រទេសបារាំងនិងរូស៊ី នៅថ្ងៃទី ៤ សីហា ១៩១៤ ក្រោយពីអាឡឺម៉ង់បានវាយលុកចូលកាត់បែលស៊ិច ។ មហាសង្គ្រាមដែលគេចំទៀសវាងបានតាំងពីដើមសតវត្សយើងនេះ បានចាប់ផ្ដើមផ្ទុះឡើងក្នុងពេលនោះ ។

ទាំងអស់គ្នា គេស្មានថា មហាសង្គ្រាមនេះនឹងមានរយៈវេលាខ្លីទេ ដោយមធ្យោបាយដែលគេយកទៅប្រើ មានអានុភាពខ្លាំងណាស់ តែផ្ទុយទៅវិញ សង្គ្រាមបានបន្តរហូតដល់ *បួនឆ្នាំ* គឺពីខែ *សីហា ១៩១៤* ដល់ខែ *វិច្ឆិកា ១៩១៨* ។

## ៣. ប្រទេសរួមចំបាំង

ដំបូង មហាសង្គ្រាមមានលក្ខណៈជាចំបាំងនៅទ្វីបអឺរ៉ុបប៉ុណ្ណោះទេ ក្រោយមកចំបាំងនេះបានរាលដាលពេញពិភពលោកទាំងមូល ដោយមានប្រទេសឯទៀតៗបានចូលរួមបន្តៗគ្នាក្នុងប្លុកទាំងពីរ ជាហេតុនាំឲ្យចំបាំងនេះប្រែក្លាយទៅជា*សង្គ្រាមលោក* ។

កំលាំងឈមមុខគ្នាទៅវិញទៅមកគ្នាមាន :

— *សម្ព័ន្ធត្រីភាគី* គឺអាឡឺម៉ង់ អូទ្រិស-ហុងគ្រី អ៊ីតាលី ។ ក្រោយមក មានប្រទេសឯទៀតចូលក្នុងសម្ព័ន្ធនេះដែរ គឺ តួកគី ប៊ុលការី (តុលា ១៩១៥) ។

— *អនុសញ្ញាត្រីភាគី* មាន បារាំង អង់គ្លេស រូស៊ី ។ ក្រោយមកទៀត មានជប៉ុន ពរទុយកេ សហរដ្ឋអាមេរិច ប្រេស៊ីល ចូលរួមក្នុងប្លុកនេះដែរ ។

## ៤. ការវាយប្រយុទ្ធគ្នា

គេអាចចែកចំបាំងនេះជាបីរយៈកាលសំខាន់ៗដូចតទៅ :

### ក. រយៈកាលទី ១ : ការវាយលុករបស់អាឡឺម៉ង់

ការវាយលុករបស់អាឡឺម៉ង់បានប្រព្រឹត្តអស់រយៈពេល ៤ ខែ ( សីហា ដល់ វិច្ឆិកា ១៩១៤ ) ។ អាឡឺម៉ង់ទុកចិត្តលើឧត្តមភាពនៃកងទ័ព លើគ្រឿងអាវុធយុទ្ធភណ្ឌ និងលើល្បិចកលរបស់ខ្លួន បានសង្ឃឹមទុកជាមុនថា ខ្លួននឹងយកជ័យជំនះបានយ៉ាងឆាប់រហ័សក្នុងសមរភូមិនៃរណសិរ្សខាងលិច *(១)* ដើម្បីលើកកងទ័ពរបស់ខ្លួនទៅរណសិរ្សខាងកើតវិញ *(២)* ។ តែការប៉ាន់ស្មាននៃសេនាធិការអាឡឺម៉ង់មិនបានសំរេចដូចកាលដែលគេបានគ្រោងទុកនោះឡើយ ។ កងទ័ពអាឡឺម៉ង់បានត្រូវកងទ័ពបារាំងវាយបញ្ឈប់ក្នុងសមរភូមិ *ម៉ាន* (Marne) នៅថ្ងៃទី *១៧ វិច្ឆិកា ១៩១៤* ។ ក្នុងដំណាច់ឆ្នាំ ១៩១៤ លទ្ធផលសឹកនៅរណសិរ្សខាងលិចមានដូចតទៅ : អាឡឺម៉ង់វាយយកប្រទេសបែលហ្ស៊ិចទាំងមូលប្រទេសបារាំងមួយផ្នែក ហើយនៅរណសិរ្សខាងកើត វាយយកបានតំបន់ប៉ូឡូញ *(៣)* មួយផ្នែកដែរ ។

នៅរណសិរ្សខាងកើត ប្រទេសរូស៊ីដែលជាសម្ព័ន្ធមិត្របារាំង វាយបានជាបន្តបន្ទាប់គ្នា នូវប្រទេសអូទ្រីស និងមួយផ្នែកនៃប្រទេសព្រុស ។

ដូចនេះ ឆ្នាំ ១៩១៤ បានកន្លងផុតទៅ ដោយពុំបានហុចលទ្ធផលជាសំរេចឡើយ ជាពិសេសចំពោះប្រទេសអាឡឺម៉ង់ដែលប៉ុនប៉ងកំទេចប្រទេសបារាំង តែក្នុងប៉ុន្មានសប្តាហ៍ប៉ុណ្ណោះ ។

### ខ. រយៈកាលទី ២ : ចំបាំងក្នុងលេណដ្ឋាន

ក្រោយពីការវាយយ៉ាងសាហាវរបស់កងទ័ពអាឡឺម៉ង់ឆ្នាំ ១៩១៤ មក រយៈកាលទី២

---

*(១) នៅរណសិរ្សខាងលិចមានប្រទេសបារាំងនិងបែលហ្ស៊ិច ដែលតទល់នឹងប្រទេសអាឡឺម៉ង់ ។*

*(២) នៅរណសិរ្សខាងកើតមានប្រទេសរូស៊ី និង រូម៉ានី ។*

*(៣) គេប្រើពាក្យតំបន់ប៉ូឡូញ ព្រោះពេលនោះ ពុំទាន់ជារដ្ឋពេញទីនៅឡើយ ។*

នៃចំបាំងបានត្រូវចាប់ផ្ដើមឡើង គឺ *«ចំបាំងជំហរ»* ។ កងទ័ពទាំងសងខាង ដោយហត់នឿយតែសព្វខ្លួន បានជីករណ្ដៅទល់មុខគ្នាប្រវែង ៧៨០ គ.ម. (ពីសមុទ្រខាងជើងមកទល់នឹងប្រទេសស្វិស) ហើយបានត្រៀមខ្លួននៅទីនោះរហូតដល់ឆ្នាំ ១៩១៧ ។



*លេណដ្ឋានមួយនៅក្រុងវែរដង់*

នៅឆ្នាំ ១៩១៥-១៩១៦-១៩១៧ ការប្រយុទ្ធគ្នាមានសភាពសាហាវឃោរឃៅឥតឧបមាៗ

គ្រប់មធ្យោបាយថ្មីត្រូវបានយកមកប្រើទាំងសងខាង ដូចជាកាំភ្លើងធំ កប៉ាល់ហោះ ផ្សែងឈ្មក់ រថក្រោះ ។ ក្នុងសមុទ្រ គេប្រើនាវាមុជទឹក ។

ការប្រយុទ្ធធំជាងគេក្នុងរយៈកាលខាងលើ គឺការប្រយុទ្ធនៅ *វែរដាំ* (Verdun) *ក្នុងឆ្នាំ ១៩១៦* ហើយដែលគូសត្រូវទាំងពីរបានបាញ់គ្នាទាំងយប់ទាំងថ្ងៃ អស់រយៈពេល ៥ ខែ ពុំមានឈប់ឈរឡើយ ។ ការប្រយុទ្ធនេះបានចប់នៅ*ខែកក្កដា ១៩១៦* ដោយកងទ័ពអាល្លឺម៉ង់ត្រូវទទួលបរាជ័យយ៉ាងធ្ងន់ (៧០០ ០០០ នាក់ត្រូវស្លាប់ក្នុងការប្រយុទ្ធនេះទាំងខាងអាល្លឺម៉ង់ទាំងខាងបារាំងរួមគ្នា) ។ ឆ្នាំ ១៩១៧ ត្រូវកន្លងផុតទៅ រីឯគូសត្រូវទាំងសងខាងពុំអាចទាញយកលទ្ធផលជាស្ថាពរបានឡើយ ។

**គ. រយៈកាលទី៣ : ចំបាំងចលនាឬការវាយលុកនៃបក្សសម្ព័ន្ធមិត្រ**

ការប្រឹងប្រែងយ៉ាងសំបើមនៃកងទ័ពអាល្លឺម៉ង់ នៅដើមឆ្នាំ ១៩១៨ ក៏ពុំអាចហុចលទ្ធផលអ្វីបានស្ដុកស្ដម្ភឡើយ ។ ទ័ពអាល្លឺម៉ង់បានទំលុះកងទ័ពសម្ព័ន្ធមិត្របីលើក (មីនា ឧសភា ១៩១៨) នៅភូមិភាគ ពីកាឌី-ផ្លង់ (Picardie-Flandre) និង អែស (Aisne) ។ ប៉ុន្តែ ឧត្តមសេនីយ *ផុក* (Foch) បានស្រង់ស្ថានភាពនេះរួច ដោយវាយកំចាត់កងទ័ពអាល្លឺម៉ង់ ក្នុងការប្រយុទ្ធជាលើកទី២នៅម៉ាន (១៥-១៨ កក្កដា ១៩១៨) ។



*រថក្រោះបារាំងគុនស្រាល (១៩១៨)*

តាំងពីពេលនោះមក ការវាយលុកសំរុកលើកដំបូងពអាល្លឺម៉ង់បានប្រព្រឹត្តទៅនៅគ្រប់ទីសមរភូមិទាំងអស់ ។ នៅថ្ងៃទី ៨ សីហា ១៩១៨ ឧត្តមសេនីយ *ផុក* ត្រូវបានតែងតាំងជាមេបញ្ជាការលើកដំបូងសម្ព័ន្ធមិត្តទាំងអស់ (មានបារាំង អង់គ្លេស អាមេរិកាំង ជាដើម) ហើយបានវាយកំចាត់កងទ័ពអាល្លឺម៉ង់នៅគ្រប់ទិសទី ។ ដោយពុំអាចនឹងទប់ទល់តទៅទៀតបាន អាល្លឺម៉ង់ត្រូវទទួលចុះហត្ថលេខាលើយុទ្ធសន្តិភាពមួយ នៅថ្ងៃទី *១១ វិច្ឆិកា ១៩១៨* ។ ចំបាំងលោកលើកទី ១ ក៏បានចប់ដែរ ។

## ៥. វិបាកនៃចំបាំងលោកលើកទី ១

ចំបាំងលោកលើកទី ១ (១៩១៤-១៩១៨) មានបច្ច័យទៅលើសង្គម ទៅលើសេដ្ឋកិច្ច និងទៅលើនយោបាយយ៉ាងច្រើនមហិមា ។

### ក. ខាងសង្គម

មនុស្សប្រហែល ១៣ លាននាក់ត្រូវបាត់បង់ជីវិត ។ ១៩ លាននាក់ត្រូវរបួស ហើយ ៣ លានកន្លះត្រូវពិការធ្វើការពុំកើត ។

### ខ. ខាងសេដ្ឋកិច្ច

ចំបាំងបានធ្វើឱ្យខូចខាតសំភារៈយ៉ាងសំបើម ។ ក្រុងជាច្រើនបានក្លាយទៅជាផេះ ។ ស្ពានផ្លូវថភ្លើង រោងចក្រច្រើនឥតគណនាត្រូវបំផ្លាញអស់ ។ ចំបាំងបានធ្វើឱ្យឧស្សាហកម្ម កសិកម្ម និងហិរញ្ញវត្ថុនៃបណ្ដាប្រទេសទ្វីបអឺរ៉ុបរង្គោះរង្គើខូចខាតអស់ ជាហេតុនាំឱ្យប្រទេសទាំងនោះចុះក្រយ៉ាងឆាប់រហ័ស ។

### គ. ខាងនយោបាយ

ចំបាំងឆ្នាំ ១៩១៤-១៩១៨ ហើយនិងបដិវត្តន៍សង្គមនិយម ខែតុលា ឆ្នាំ ១៩១៧ បានធ្វើឱ្យរង្គោះរង្គើរបបមូលធននិយមពិភពលោក ។

## សំណួរ

១. រៀបរាប់ដោយសង្ខេបអំពីកំណើត «ប្លុក» ទាំងពីរនៅអឺរ៉ុបមុនឆ្នាំ ១៩១៤ ។

២. បុព្វហេតុនៃសង្គ្រាមលោកលើកទី ១ ។

៣. ផលវិបាកនៃសង្គ្រាមលោកលើកទី ១ ។

# ១១. សន្ធិសញ្ញាសន្តិភាព និង សង្គមប្រជាជាតិ

ក្រោយពីយុទ្ធសន្តិភាព សន្និសីទមួយបានបើកសម័យប្រជុំនៅក្រុង *ប៉ារី* (ថ្ងៃទី ១៨ មករា ១៩១៩) ដើម្បីរៀបចំសន្ធិសញ្ញាសន្តិភាពមួយ ដែលមានប្រទេស ២៧ បានចូលរួមផង ។ នៅថ្ងៃទី *២៨ មិថុនា ១៩១៩ សន្ធិសញ្ញាសន្តិភាពវែរសៃ* ត្រូវបានទទួលហត្ថលេខា រវាងប្រទេសបារាំងនិងសម្ព័ន្ធមិត្តរបស់ខ្លួន និងអាឡឺម៉ង់ ។ តាមសន្ធិសញ្ញានោះ អាឡឺម៉ង់ត្រូវទទួលខុសត្រូវក្នុងការបង្កសង្គ្រាម ត្រូវលះបង់ចោលដែនដីអាណានិគមរបស់ខ្លួនទាំងអស់ ត្រូវប្រគល់មកប្រទេសបារាំងវិញនូវតំបន់អាល់សាស-ឡរ៉ែន ប្រគល់ដល់ប្រទេស ប៉ូឡូញ នូវរដ្ឋប៉ូសណានី និងសងស្យាជួសជុលគ្រប់ការអន្តរាយទាំងឡាយ ដែលបណ្ដាលមកពីសង្គ្រាម ពិសេសគឺចំពោះប្រជាជនស៊ីវិល ។

*សន្ធិសញ្ញាវែរសៃ* ត្រូវបានបង្គ្រប់ដោយ *សន្ធិសញ្ញា សាំងហ្សែម៉ាំង* (Saint-Germain) ជាមួយនឹងប្រទេសអូទ្រីស (កញ្ញា ១៩១៩) *សន្ធិសញ្ញា ណឺយី* (Neuilly) ជាមួយនឹងប៊ុលការី (វិច្ឆិកា ១៩១៩) *សន្ធិសញ្ញា ទ្រីយ៉ាណុង* (Trianon) ជាមួយនឹងហុងគ្រី (មិថុនា ១៩២០) *សន្ធិសញ្ញានៅក្រុងសែវ* (Sèvres) ជាមួយនឹងប្រទេសតួគី (សីហា ១៩២០) ។ សន្ធិសញ្ញាសន្តិភាពទាំងប៉ុន្មានខាងលើនេះបានបែងចែកប្រទេសអូទ្រីស ប្រទេសហុងគ្រី និងប្រទេសតួគី ។ មហាសង្គ្រាមឆ្នាំ ១៩១៤-១៩១៨ បានបណ្ដាលឲ្យអន្តរាយយ៉ាងសំបើម ទាំងខាងមនុស្ស ទាំងខាងសំភារៈនិងទាំងខាងសេដ្ឋកិច្ច ។ ដើម្បីចៀសវាងកុំឲ្យមានចំបាំងទៀតនោះ ចលនាសន្តិភាព ក្រោមការខ្នះខ្នែងនៃលោក *វិលសុន* ប្រធានាធិបតីអាមេរិកាំងបានផ្ដើមគំនិតបង្កើត*សង្គមប្រជាជាតិ*មួយ ។

អត្ថបទជាគោលការណ៍នៃសង្គមប្រជាជាតិបានត្រូវយល់ព្រមទទួលយកជាផ្លូវការ នៅថ្ងៃទី ២៩ មេសា ១៩១៩ ។ ក្នុងបទបញ្ញត្តិនៃគោលការណ៍សង្គមប្រជាជាតិនេះ រដ្ឋ

ទាំងឡាយសន្យាថា នឹងត្រូវបន្ថយសញ្ញាវុធ ត្រូវបញ្ជូនការវិវាទរបស់ខ្លួនឲ្យតុលាការអន្តរជាតិជំនុំជំរះ ហើយមិនត្រូវប្រើកំលាំងដើម្បីដោះស្រាយការវិវាទរបស់ខ្លួន មុនរយៈពេល ៣ ខែ ក្រោយពីតុលាការបានវិនិច្ឆ័យឡើយ ។

សង្គមប្រជាជាតិមានអង្គការផ្សេងៗជាច្រើន :

— មហាសន្និបាតដែលនៅក្នុងនោះ គ្រប់ប្រទេសជាសមាជិក មិនថាធំឬតូច ត្រូវមានមួយសំលេងដូចគ្នាក្នុងការពិភាក្សាដោះស្រាយបញ្ហាផ្សេងៗ ។ សង្គមប្រជាជាតិមានទីស្នាក់ការនៅក្រុង *ស៊ីណែវ* ។

— ក្រុមអភិបាលមួយដែលមានសមាជិក ៩ រូប : សមាជិកអចិន្ត្រៃយ៍ ៥ រូប ជាតំណាងមហាអំណាចទាំង៥ សមាជិក ៤ រូបទៀតត្រូវជ្រើសរើសរៀងរាល់ឆ្នាំដោយមហាសន្និបាត ។

— ការិយាល័យអចិន្ត្រៃយ៍មួយ

— តុលាការអន្តរជាតិមួយសំរាប់ជំនុំជំរះអធិករណ៍រវាងប្រជាជាតិនៅ *ឡាអេ* ។



*វែរសៃ ២៨ មិថុនា ១៩១៩*

*ខាងឆ្វេង លោកក្លឹម៉ង់សូ កណ្ដាល លោកវិលសុន ខាងស្ដាំ លោកឡយសក*



ប្រទេស ណរវែស
ប្រទេស ស៊ុយអែត
ក្រុងសាំងពេ
ចក្រភព រុស្ស៊ី
ចក្រភព អាល្លឺម៉ង់
ប៉ូឡូញ
ប្រទេស បែលហ្ស៊ិច
ប្រទេស បារាំង
ប្រទេស ស្វីស
ចក្រភព អូទ្រីស ហុងគ្រី
ប្រទេស អ៊ីតាលី
បូស្នី
ប្រទេស ម៉ុងតេ ណេក្រូ
ប្រទេស សែប៊ី
ប្រទេស រូម៉ានី
ប្រទេស ប៊ុលហ្គារី
សមុទ្រ ខ្មៅ
ប្រទេស អាល់បានី
ប្រទេស ក្រិច
ចក្រភព តួកគី
សមុទ្រ មេ ឌី ទែ រ៉ា ណេ


ប្រទេស ណរវែស
ប្រទេស ស៊ុយអែត
ប្រទេសហ្វាំងឡង់
លេនីនក្រាត
ប្រទេស អេស្តូនី
ប្រទេសឡេតូនី
ប្រទេស លីទុយអានី
ប្រ៊ុស ខាងកើត
សហភាព
សូវៀត
ប្រទេស ប៉ូឡូញ
ប្រទេស អាល្លឺម៉ង់
ប្រទេស បែលហ្ស៊ិច
ប្រទេស បារាំង
ប្រទេស ឆេកូស្លូវ៉ាគី
ប្រទេស ស្វ៊ីស
ប្រទេស អូទ្រីស
ប្រទេស ហុងគ្រី
ប្រទេស រូម៉ានី
ប្រទេស អ៊ីតាលី
ប្រទេស យូកូស្លាវី
សមុទ្រ ខ្មៅ
ប្រទេស ប៊ុលការី
ប្រទេស អាល់បានី
ប្រទេស ក្រិច
ប្រទេស តួកគី
ស៊ីស៊ីល
សមុទ្រ មេ ឌី ទែ រ៉ា ណេ

— ការិយាល័យអន្តរជាតិគ្រប់ជំពូក ដែលនៅក្រោមអំណាចសង្គមប្រជាជាតិ ។

សង្គមប្រជាជាតិគ្មានមធ្យោបាយអ្វីដើម្បីធានាអះអាង និងការពារសន្តិសុខអន្តរជាតិឡើយ គឺមានតែកំលាំងខាងផ្លូវចិត្តប៉ុណ្ណោះ ។ ក្នុងករណីនេះ សង្គមប្រជាជាតិមិនអាចរាំងផ្លូវចំបាំងបានឡើយ ហើយដល់ឆ្នាំ១៩៣៩ ជាស៊ីសនិយមអាឡឺម៉ង់បានបង្កសង្គ្រាមលោកលើកទី២ម្តងទៀត ។

## សំណួរ

១. មាត្រាសំខាន់ៗនៃសន្ធិសញ្ញាសន្តិភាពវែរសៃ ?

២. ក្រៅពីសន្ធិសញ្ញាវែរសៃ មានសន្ធិសញ្ញាអ្វីទៀត ? សន្ធិសញ្ញាទាំងនោះចែងអំពីបញ្ហាអ្វីខ្លះ ?

៣. សង្គមប្រជាជាតិមានគោលដៅអ្វីខ្លះ ?

៤. សង្គមប្រជាជាតិមានអង្គការអ្វីខ្លះ ?

៥. សង្គមប្រជាជាតិបានបំពេញភារៈរបស់ខ្លួន ដោយប្រសិទ្ធិភាពឬទេ ? ពីព្រោះអ្វី ?

# ១២. ការបាត់តុល្យភាព
# នៅក្រោយសង្គ្រាមលោកលើកទី ១

## ១. ស្ថានភាពទូទៅនៃវិបត្តិ

មហាសង្គ្រាមលោកលើកទី ១ បានធ្វើឱ្យពិភពលោកយើងទាំងមូល ពិសេស ទ្វីបអឺរ៉ុប ធ្លាក់ចុះក្នុងស្ថានភាពមួយប្រកបទៅដោយវិបត្តិគ្រប់វិស័យ ។ ម្យ៉ាងទៀត តាំងពីពេលនោះមក ពិភពលោកគ្មានស្គាល់ស្ថិរភាពបន្តិចណាឡើយ ។ មហាសង្គ្រាមបានធ្វើឱ្យបាត់តុល្យភាពខាងវប្បធម៌ សេដ្ឋកិច្ច សង្គម និងនយោបាយ នៅស្ទើរតែគ្រប់ប្រទេស ។

### ក. ការបាត់តុល្យភាពសេដ្ឋកិច្ច

ការបាត់តុល្យភាពសេដ្ឋកិច្ចមានរូបភាពពិស្តារជាងវិស័យណាទាំងអស់ ។ យ៉ាងណាមិញ សង្គ្រាមបានធ្វើឱ្យអន្តរាយធនធានសេដ្ឋកិច្ចនៃប្រទេសជាច្រើន ជាពិសេស នៅទ្វីបអឺរ៉ុប មានប្រទេស *បារាំង* និងប្រទេស *អាឡឺម៉ង់* ជាដើម ។ រោងចក្រធំៗនិងក្រុងឧស្សាហកម្មជាច្រើនបានប្រែក្លាយទៅជាផេះ ។ ការចាយវាយយ៉ាងសំបើមក្នុងគ្រាចំបាំងបានធ្វើឱ្យប្រទេសទាំងនោះធ្លាក់ចុះក្រដុនជាបង្ហើបមុខស្ទើរតែពុំរួច ។ ក្រោយពីចំបាំង មហាអំណាចអឺរ៉ុបត្រូវបាត់បង់ផ្សារ បាត់បង់ឧស្សាហកម្មជាមូលដ្ឋានរបស់ខ្លួន ។

ក្នុងរយៈពេលជាមួយគ្នានោះ ប្រទេសខ្លះបានចំពង្រីកឧស្សាហកម្មរបស់ខ្លួន យ៉ាងសន្ធឹកសន្ធាប់ ដូចជាប្រទេស *ជប៉ុន* សហរដ្ឋ *អាមេរិច* និងប្រទេសថ្មីៗជាច្រើន មានប្រទេស *កាណាដា* ប្រទេស *អូស្ត្រាលី* ប្រទេស *ប្រេស៊ីល* ជាដើម ជាហេតុនាំឱ្យមហាអំណាចអឺរ៉ុបបាត់បង់ឧត្តមភាពសេដ្ឋកិច្ច និងនយោបាយ ដែលខ្លួនរក្សាបានគង់វង្សតាំងពីដើមរៀងមក ។ ធនធានយ៉ាងសំបើមចាកចេញពីទ្វីបអឺរ៉ុប ទៅចូលក្នុងទូដែកនៃសហរដ្ឋអាមេរិច ដែលបានប្រែក្លាយទៅជាមហាសេដ្ឋីមួយដាច់គេក្នុងលោកយើងនេះ តែ

ក្នុងរយៈពេលមួយដ៏ខ្លី ។

ចក្រភព*អង់គ្លេស* ប្រទេស*បារាំង*ដែលពីដើមធ្លាប់តែឲ្យប្រាក់គេខ្ចី បានធ្លាក់ខ្លួនប្រែក្លាយទៅជាកូនបំណុលរបស់សហរដ្ឋអាមេរិចទាំងអស់ ។

ម្យ៉ាងទៀត ប្រទេសទាំងនេះដែលទើបតែនឹងងើបរួចផុតពីសង្គ្រាម បានខំប្រឹងប្រែងស្ដាបនាមូលដ្ឋានសេដ្ឋកិច្ចឡើងវិញ ដើម្បីផ្ដល់ការងារដល់កម្មករផង ដើម្បីរស់ដោយខ្លួនឯងផង និងដើម្បីរៀបចំហិរញ្ញវត្ថុឲ្យមានរបៀបរៀបរយឡើងវិញផង ។ ដូចនេះរដ្ឋនីមួយៗបិទផ្សាររបស់ខ្លួនពុំឲ្យទំនិញពីក្រៅចូលមកប្រកួតប្រណាំងឡើយ ។ ប្រទេសខ្លះដូចជាប្រទេសអាល្លឺម៉ង់និងប្រទេសរូស៊ីដែលធ្លាក់ខ្លួនក្រខ្វាំងពេក ពុំអាចមានប្រាក់កាសទិញពីបរទេសបាន បង្ខំចិត្តរស់ដោយខ្លួនឯង ពុំមានទាក់ទងខាងពាណិជ្ជកម្មជាមួយនឹងប្រទេសណាឡើយ ។

អនុវត្តន៍របងគយនិងនយោបាយឧបត្ថម្ភនិយម ក្នុងវិស័យសេដ្ឋកិច្ច បានធ្វើឲ្យបាត់បង់សេរីភាពខាងបណ្ដូរដែលជាគោលនិយមមួយដ៏សំខាន់នៃមូលធននិយមក្នុងសតវត្សទី ១៩ ។

វិបាកផ្សេងៗដែលបណ្ដាលមកពីវិធានការខាងលើ និងការធ្លាក់ក្រនៃមនុស្សរាប់សិបលាននាក់ដែលពុំអាចទិញផលិតផលដ៏សំបូរបាន ។ល។ បានង្កើតវិបត្តិសេដ្ឋកិច្ចមួយដ៏ធំក្នុងឆ្នាំ ១៩២៩ គឺវិបត្តិបង្កើតផលលើស *(១)* ។ វិបត្តិនេះដែលប្រវត្តិសាស្រ្តពុំដែលបានជួបប្រទះសោះ បានផ្ទុះជាដំបូងនៅសហរដ្ឋអាមេរិច ហើយក៏បានរាលដាលដល់ទ្វីបអឺរ៉ុប រួចសាយភាយពាសពេញពិភពលោកទាំងមូល ។

វិបត្តិនេះបានធ្វើឲ្យថ្លៃទំនិញធ្លាក់ចុះយ៉ាងថោកបំផុត ឲ្យហាងទំនិញធំៗបិទទ្វារ ឲ្យផលិតកម្មនិងពាណិជ្ជកម្មអន្តរជាតិរួញមកនៅត្រឹមកំរិតមួយទាបបំផុត ។ ឯមនុស្សគ្មានការធ្វើនៅសហរដ្ឋអាមេរិចនិងអឺរ៉ុបមានចំនួនជាង ៣០ លាននាក់ ជាហេតុធ្វើឲ្យមានចលាចលខាងនយោបាយ ខាងសង្គម ហើយជាពិសេស បានបង្ខំរដ្ឋាភិបាលនានាឲ្យធ្វើអន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច ចាប់ពីពេលនោះមក ។

---

*(១) វិបត្តិបង្កើតផលលើស* ( crise de sur-production ) *ប្រសិនបើគេប្រៀបធៀបចំនួនទំនិញទៅនឹងចំនួនសេចក្ដីត្រូវការរបស់មនុស្ស គឺគ្មានវិបត្តិខាងលើនេះទេ ។ របបមូលធននិយម មិនគិតដូចនេះឡើយ ផ្ទុយទៅវិញ គេគិតចំនួនទំនិញទៅនឹងចំនួនមនុស្សដែលមានប្រាក់កាសទិញ ។*

ខ. វិបត្តិរូបិយវត្ថុ

បាតុភាពដ៏ជាក់ស្ដែងនៃការបាត់តុល្យភាពសេដ្ឋកិច្ច គឺស្ថិតនៅលើវិបត្តិ *រូបិយវត្ថុ* ដែលគ្រប់ប្រទេសបានពើបប្រទះជាញឹកញាប់ ។ យ៉ាងណាមិញ រដ្ឋនានា ដោយសេចក្ដីត្រូវការជាចាំបាច់ តែងតែបោះក្រដាសប្រាក់ហួសចំនួនលើសលុប ជាហេតុនាំឱ្យរូបិយវត្ថុទាំងនោះបាត់តំលៃរបស់ខ្លួន ហើយបណ្ដាលឱ្យការរស់នៅនៃអ្នកទិញទាល់ក្រីតែពិបាកឡើងៗ ។

ក្នុងប្រទេសបរាជ័យទាំងឡាយ វិបត្តិរូបិយវត្ថុនេះមានសភាពធ្ងន់ណាស់ ដូចជាប្រទេសអាឡឺម៉ង់ជាដើម ដែលនៅក្នុងឆ្នាំ ១៩២៣ បានបោះក្រដាសប្រាក់ដល់ទៅ ៤៩៦ ៤២៤ ០០០ ០០០ ០០០ ០០០ ម៉ាក់ ។ ឯក្រដាសប្រាក់ចាស់បាត់តំលៃរបស់ខ្លួនអស់លែងយកជាការបាន ។ នៅប្រទេសឯទៀតៗ គេក៏ជួបប្រទះបាតុភូតនេះដែរ ដូចជានៅឆ្នាំ ១៩២៨ ប្រាក់ប្រង់បារាំងនៅមានតំលៃតែត្រឹមមួយភាគប្រាំនៃប្រាក់ប្រង់មុនឆ្នាំ ១៩១៤ ហើយដល់ឆ្នាំ១៩៣៨ តំលៃនេះធ្លាក់ចុះមកនៅត្រឹមតែ ១ ភាគ ១០ ប៉ុណ្ណោះ ។ ប្រាក់អង់គ្លេសក៏ត្រូវចុះតំលៃរបស់ខ្លួនដែរក្នុងឆ្នាំ ១៩៣១ ។

*ឧទាហរណ៍* : ក្នុងខែ មករា ឆ្នាំ ១៩២៣ មួយម៉ាក់មាសអាឡឺម៉ង់មានតំលៃស្មើនឹង ៤ ២៨០ ម៉ាក់ក្រដាស ខែសីហា មួយម៉ាក់មាសដដែលស្មើនឹង ១ ១០០ ០០០ ម៉ាក់ក្រដាស ខែកញ្ញា មួយម៉ាក់មាសស្មើនឹង ២៣ ០០០ ០០០ ម៉ាក់ក្រដាស ហើយដល់ខែធ្នូ ១៩២៣ មួយម៉ាក់មាសស្មើនឹង ១០០ ០០០ ០០០ ០០០ ម៉ាក់ក្រដាស ។ ការចុះតំលៃនៃរូបិយវត្ថុដ៏ឆាប់រហ័សយ៉ាងនេះធ្វើឱ្យតំលៃទំនិញឡើងយ៉ាងឆាប់រហ័សដែរ ។ ដូចនេះហើយ បានជាគេសង្កេតឃើញរដ្ឋខ្លះ ដែលក្រដាសប្រាក់របស់ខ្លួនបាត់បង់តំលៃអស់រលីងនោះ បានប្ដូរទំនិញនឹងទំនិញរវាងរដ្ឋនិងរដ្ឋ ឯក្រដាសទាំងនោះ ក៏មិនអាចយកទៅប្រើការអ្វីបានឡើយ ដោយគេពុំព្រមទទួលស្គាល់ ។ ទាំងនេះជាឧបសគ្គមួយយ៉ាងធំ ដល់បណ្ដូរទំនិញអន្តរជាតិ និងដល់ពាណិជ្ជកម្មអន្តរជាតិ ។

គ. បរាជ័យនៃសេដ្ឋកិច្ចសេរី

វិបត្តិសេដ្ឋកិច្ច និងវិបត្តិរូបិយវត្ថុបានធ្វើឱ្យគ្រប់មូលដ្ឋាននៃសេដ្ឋកិច្ចសេរីរង្គោះរង្គើដល់ឫសកែវ ។ យ៉ាងណាមិញ គេមិនអាចអនុវត្តមូលភាពនៃសេដ្ឋកិច្ចរបៀបមូលធននិយម

ទៀតបានឡើយ ដូចជាការប្រកួតប្រណាំងដោយសេរី និងការលក់តាមថ្លៃសេរី ។ ពីដើមរៀងមក ឧស្សាហករក្តី ពាណិជ្ជករក្តី អាចប្រកួតប្រណាំងគ្នា អាចលក់ទំនិញរបស់ខ្លួនតាមថ្លៃណាក៏បាន គ្មានអ្វីមកឃាត់ឃាំងបានឡើយ ។ បរាជ័យនៃមូលភាពជាសារវន្តទាំងពីរខាងលើបង្កើតឲ្យមានចលនាប្រមូលផ្តុំសហគ្រាសធំៗ ដែលបានចាប់ផ្តើមតាំងពីសតវត្សទី ១៩ មកម្ល៉េះ ។ ផលិតករទាំងឡាយប្រមូលគ្នាជាក្រុមហ៊ុន ហើយបានកំណត់យ៉ាងតឹងរ៉ឹងដល់ម្នាក់ៗនូវ :

- ចំនួនទំនិញ ដែលសហគ្រាសរបស់ខ្លួនត្រូវផលិត
- តំបន់-ភូមិភាគ ដែលខ្លួនត្រូវលក់
- កំរិតតំលៃទំនិញ
- តំលៃដែលខ្លួនត្រូវអនុវត្ត (គឺមិនឲ្យចុះថោកហួសកំរិតដែលគេបានកំណត់ឡើយ)។

ទោះបីមានការព្រមព្រៀងរវាងសហគ្រាសធំៗ ដូចពោលមកខាងលើក៏ដោយ មូលធនិកទាំងនោះពុំអាចចៀសវាងវិបត្តិបានឡើយ ។ ការបាត់តុល្យភាពខាងសេដ្ឋកិច្ច ខាងរូបិយវត្ថុនៅតែមាន ហើយធ្ងន់ថែមទៀតផង ។ ដូចនេះ រដ្ឋត្រូវមានភារៈនឹងស្រោចស្រង់ស្ថានភាពនេះ ដោយបានធ្វើអន្តរាគមន៍ដើម្បីចាត់វិធានការសេដ្ឋកិច្ចដូចជាត្រួតពិនិត្យមន្ទីរប្តូរប្រាក់ បញ្ចុះតំលៃប្រាក់ កំណត់ទំនិញដែលត្រូវដឹកចេញឬនាំចូល ហាមប្រាមមិនឲ្យដាំមុខដំណាំខ្លះ បំផ្លាញចោលផលិតផលខាងកសិកម្មដែលសល់ច្រើនលើសលុប ហើយនិងជួយសហគ្រាសណា ដែលផ្តល់ផលប្រយោជន៍ដល់ជាតិក្នុងពេលវិបត្តិ ។ល។

*ឧទាហរណ៍* : ក្រោយឆ្នាំ ១៩៣១ រដ្ឋាភិបាលបារាំងហាមប្រាមមិនឲ្យដាំទំពាំងបាយជូរជាថ្មី បញ្ជាឲ្យដកទំពាំងបាយជូរចោល ។ នៅប្រទេសប្រេស៊ីល គេឲ្យដុតកាផែចោល ក្នុងរវាងប្រាំបួនឆ្នាំ គេបានបំផ្លាញកាផែចោលចំនួន ៣ ៥០០ ០០០ ០០០ គ.ក. ។ នៅប្រទេសហូឡង់ និងសហរដ្ឋអាមេរិច គេកាប់សំលាប់សត្វពាហនៈចោលរាប់លានក្បាល ដើម្បីធ្វើឲ្យសាច់ជ្រូក សាច់គោ ឡើងថ្លៃវិញ ។ល។

ក្រោយមកទៀត រដ្ឋបានស្ថាបនាផែនការសេដ្ឋកិច្ច ដើម្បីចៀសវាងវិបត្តិ ។ ឯផែនការសេដ្ឋកិច្ចដ៏ល្បីល្បាញជាងគេ គឺផែនការប្រាំឆ្នាំ ដែលសហភាពសូវៀតបានស្ថាបនាមុនគេ ។ តាំងពីពេលនោះមក រដ្ឋនានាបានដឹកនាំសេដ្ឋកិច្ចជាតិ លែងបណ្តោតបណ្តាយ

ឲ្យសេរីភាពដល់ឯកជនទៀតហើយ ។

សេរីភាពនិយមខាងសេដ្ឋកិច្ចដែលជាលក្ខណៈពិសេសនៃសេដ្ឋកិច្ចមូលធននិយមក្នុងឆ្នាំ ១៩១៤ បានបរាជ័យនៅពេលក្រោយសង្គ្រាម ហើយត្រូវបាត់បង់ដំហររបស់ខ្លួនតាំងពីពេលនោះមក ។

ឃ. ការបាត់តុល្យភាពខាងសង្គម

ការបាត់តុល្យភាពខាងសង្គមពុំសូវមានលក្ខណៈជាក់លាក់ពិស្ដារ ដូចជាការបាត់តុល្យភាពសេដ្ឋកិច្ចឡើយ លើកលែងតែនៅប្រទេសរុស្ស៊ីចេញដែលមានបំរែបំរួលយ៉ាងសំបើមដោយសារបដិវត្តន៍សង្គមនិយមនាឆ្នាំ ១៩១៧ ។

មនុស្សជាច្រើនលាននាក់ត្រូវធ្លាក់ខ្លួនចុះក្នុងស្ថានភាពក្រីក្រលំបាកវេទនាយ៉ាក រងទុក្ខវេទនាដោយសារសង្គ្រាមផង ដោយសារគ្មានការធ្វើផង (កម្មករជាង ៣០ លាននាក់ត្រូវបាត់បង់ការងាររបស់ខ្លួនក្នុងរោងចក្រ) ។

អ្នកដែលធ្លាក់ខ្លួនទាំងនោះ ច្រើនតែអ្នកមានបៀវត្សតិចតួចស្ដួចស្ដើង មិនអាចរស់នៅបាន ដោយទំនិញឡើងថ្លៃឆាប់រហ័សពេក ដូចជាភ្នាក់ងាររដ្ឋការ កវីនិពន្ធ សិល្បករ ឬម្ចាស់ដីធ្លីតូចតាច ។ល។ អ្នកខ្លះប្រែជាមានភោគទ្រព្យ ជាមហាសេដ្ឋី តែក្នុងមួយរយៈពេលដ៏ខ្លី ដូចជាថៅកែដែក ឧស្សាហករ ពាណិជ្ជករ ។ល។

វណ្ណៈកម្មករ ថ្វីបើបានទទួលរងគ្រោះធ្ងន់ជាងគេ ក៏បានធ្វើឲ្យស្ថានភាពខ្លួនចំរើនខ្លះដែរ ដូចជារដ្ឋាភិបាលទទួលស្គាល់របៀបបរិមាណនៃជីវភាពរបស់ខ្លួន ទទួលស្គាល់ចំនួនម៉ោងធ្វើការក្នុងមួយថ្ងៃ គឺ ៨ ម៉ោង ។ល។

ម្យ៉ាងទៀត សមភាពរវាងបុរសនិងស្ត្រីក្នុងការងារក្តី ក្នុងនយោបាយក្តី ត្រូវបានគេទទួលស្គាល់ស្ទើរតែនៅគ្រប់ប្រទេស ។

នៅប្រទេសឥណ្ឌា ប្រទេសចិន នៅមជ្ឈិមបូព៌ាប្រទេស ស្ត្រីៗលែងរស់នៅតែក្នុងមួយផ្ទះទៀតហើយ ។ ស្ត្រីៗបានរំដោះខ្លួនរួចចេញពីស្ថានភាព ដែលទំនៀមទំលាប់ប្រពៃណីបានចងជាប់ជាច្រើនសតវត្សមក ។ *ការរំដោះខ្លួននៃស្ត្រីភេទ* ជាលក្ខណៈពិសេសនៃសម័យបច្ចុប្បន្នយើងនេះ ។

### ង. ការបាត់តុល្យភាពខាងនយោបាយ

ក្នុងវិស័យនយោបាយ មហាសង្គ្រាមបានធ្វើឲ្យសាបសូន្យរបបរាជានិយមជាច្រើននៅទ្វីបអឺរ៉ុបដូចជារាជវង្ស *ហាប់ស្បួ* (Habsbourg) *ហូហេនស្សូលែន* (Hohenzollern) *រ៉ូម៉ាណូវ* (Romanov) ដែលសុទ្ធតែជាមហាវង្សក្សត្រដ៏មានអំណាចខ្លាំងពូកែអស្ចារ្យនៅទ្វីបអឺរ៉ុប ៗ របបសាធារណរដ្ឋត្រូវបានស្ថាបនាក្នុងប្រទេសជាច្រើននៅទ្វីបអឺរ៉ុប ៗ

គេចាត់ទុកជ័យជំនះនៃបក្សសម្ព័ន្ធជាជ័យជំនះនៃមូលភាពនៃសេរីភាព និងមូលភាពនៃប្រជាធិបតេយ្យ ៗ ប៉ុន្តែ ព្រឹត្តិការណ៍ផ្សេងៗក្រោយមកទៀតបានជំរុញរដ្ឋខ្លះ ដូចជាប្រទេសអ៊ីតាលី ប្រទេសអាល្លឺម៉ង់ ប្រទេសអេស្ប៉ាញ ប្រទេសពរទុយកាល់ ប្រទេសរូស៊ីឲ្យកាន់របបគ្រប់គ្រងផ្តាច់ការរៀងៗខ្លួន ៗ

របបផ្តាច់ការផាស៊ីសទាំងនោះមានលក្ខណៈដូចៗគ្នា គឺមានមេដឹកនាំម្នាក់ដណ្តើមយកអំណាច បំបាត់គណបក្សជំទាស់ ហើយដោយផ្អែកទៅលើប៉ូលិសរបស់ខ្លួន និងលើគ្រប់មធ្យោបាយឃោសនា (កាសែត វិទ្យុ ...) គេបានលុបសិទ្ធិសេរីភាពទាំងអស់របស់ពលរដ្ឋ ហើយគេបានទាំងខំតំរែតំរង់ដឹកនាំមតិមហាជន ដុសខាត់ស្មារតីមនុស្សដើម្បីអប់រំឲ្យត្រូវនិយាយស្តីយ៉ាងនេះ ត្រូវជឿយ៉ាងនោះ ៗលៗ

ក្នុងរបបផ្តាច់ការ គេមិនឲ្យមានសេរីភាពខាងកាសែត សេរីភាពខាងជំនឿ សេរីភាពខាងបោះឆ្នោត សេរីភាពជជែករកការពិតអ្វីឡើយ ៗ

ក្នុងរបបនេះ មានតែរដ្ឋមួយប៉ុណ្ណោះទេដែលមានសិទ្ធិ មានសេរីភាព អ្នកណាមួយហ៊ានក្អកហ៊ានគ្រហែម អ្នកនោះត្រូវបាត់បង់ជីវិត ៗ រដ្ឋមានឋានៈធំជាងអ្វីៗទាំងអស់ ៗ សុចរិត យុត្តិធម៌ ការពិត ចរិយាធម៌ គឺប្រលំនឹងផលប្រយោជន៍របស់រដ្ឋ ៗ គឺមានតែរដ្ឋទេដែលជាអ្នកកំណត់បុគ្គលម្នាក់ៗឲ្យនិយាយស្តីដូចនេះ គិតនិងជឿដូចនោះ ៗលៗ

ការស្ថាបនារបបផ្តាច់ការបានធ្វើឲ្យមនុស្សភៀសខ្លួនចេញពីរដ្ឋរបស់ខ្លួនជាច្រើន ដោយខ្លាចការកំហែងគំរាមពីអ្នកកាន់អំណាច ដូចជានៅប្រទេសអាល្លឺម៉ង់ អ៊ីតាលី អេស្ប៉ាញ ដោយយើងមិនរាប់ជនជាតិជ្វីបរាប់សែននាក់ ដែលត្រូវទទួលរងគ្រោះនៅប្រទេសអាល្លឺម៉ង់ផងទេ ៗ

# សំណួរ

១. ផលវិបាកបន្ទាន់នៃសង្គ្រាមបានធ្វើឲ្យប្រទេសអឺរ៉ុបប្រទះនឹងការលំបាកអ្វីខ្លះ ?

២. វិបត្តិសេដ្ឋកិច្ចនៃប្រទេសខ្លះ ក្រោយមហាសង្គ្រាម ។

៣. គេពោលថា សេដ្ឋកិច្ចសេរីបានទទួលបរាជ័យនៅពេលក្រោយសង្គ្រាម ។ តើអ្នកយល់ដូចម្តេច ?

៤. បុព្វហេតុនៃរបបផ្តាច់ការ ។ ប្រទេសណាខ្លះបានកាន់របបផ្តាច់ការ នៅមុនសង្គ្រាមលោកលើកទី ២ ?

# ១៣. សហភាពសូវៀត ពីឆ្នាំ ១៩១៧ ដល់ឆ្នាំ ១៩៣៩

## ១. ការស្ថាបនារបបរួមសំបាច់



*លោក លេនីន*

បណ្ដារដ្ឋនៅទ្វីបអឺរ៉ុបទាំងឡាយ ប្រទេសរុស្ស៊ីជាប្រទេសមួយដែលមានបំរែបំរួលយ៉ាងច្រើន ៗ មកទល់នឹងមហាសង្គ្រាមលោកលើកទី ១ ប្រទេសរុស្ស៊ីជា *រាជាធិបតេយ្យ* ហើយអំណាចរដ្ឋធ្លាក់មូលតែក្នុងព្រះហស្តមហាក្សត្រមួយអង្គ ទោះបីមានរដ្ឋធម្មនុញ្ញតាំងពីឆ្នាំ ១៩០៥ មកក៏ដោយ ។

ក្នុងមួយរយៈពេលដ៏ខ្លី គឺក្នុងពេលសង្គ្រាម ប្រទេសរុស្ស៊ីបានប្រែជា *សាធារណរដ្ឋរួមសំបាច់* ដែលមានលោក *លេនីន* និងបក្សរបស់លោកជាអ្នកផ្ដើមគំនិតធ្វើបដិវត្តន៍ក្នុងឆ្នាំ ១៩១៧ ។ លុះបានកាន់កាប់អំណាចភ្លាមលោក លេនីននិងបក្សលោកបានចាត់វិធានការជាច្រើនដើម្បីបំបាត់របបគ្រប់គ្រងចាស់ ទាំង

ក្នុងវិស័យនយោបាយ វិស័យសេដ្ឋកិច្ច និងវិស័យសង្គមកិច្ច ។ ប្រទេសរូស៊ីបានប្រែឈ្មោះហៅថា *សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត* ។

## ២. ឧបសគ្គដែលរដ្ឋសូវៀតបានពើបប្រទះ

ក្រោយពី «*បដិវត្តន៍ខែតុលា*» ១៩១៧ មក សហភាពសូវៀតបានពើបប្រទះនឹងឧបសគ្គនិងការពិបាកជាច្រើន ។ គេត្រូវប្រយុទ្ធតស៊ូគ្រប់បែបយ៉ាង ដើម្បីការពារបដិវត្តន៍ ។ គេប្រយុទ្ធទល់នឹងពួកប្រឆាំងបដិវត្តន៍ខាងក្នុងរដ្ឋនិងអន្តរាគមន៍ពីបរទេស ដោយពួកទាំងនោះមានគោលបំណងនឹងសំលាប់របបគ្រប់គ្រងថ្មី ។

### ក. ការប្រឆាំងនឹងបដិវត្តន៍ខាងក្នុងប្រទេស

ក្នុងរយៈពេលបីឆ្នាំ ( គឺពីឆ្នាំ ១៩១៨ ដល់ឆ្នាំ ១៩២១ ) សង្គ្រាមផ្ទៃក្នុងមួយបានកើតពាសពេញប្រទេស ។ សង្គ្រាមនេះគឺពួកប្រឆាំងនឹងបដិវត្តន៍ដែលគេហៅថា «*ទ័ពទស*» បានបង្កបង្កើតឡើង ហើយដែលបានទទួលជំនួយ និងការគាំទ្រយ៉ាងចំហពីពួកបក្សសម្ព័ន្ធចាស់របស់ សហភាពសូវៀត ។ ឈមមុខចំពោះមហន្តរាយដ៏ធំនេះ រដ្ឋាភិបាលកុម្មុយនិសសូវៀតបានចាត់វិធានការយ៉ាងតឹងរឹង ហើយបានប្រើគ្រប់មធ្យោបាយ សំរាប់ប្រយុទ្ធតទល់នឹងពួកបច្ចាមិត្រដ៏ឃោរឃៅនេះ ដើម្បីស្រោចស្រង់បដិវត្តន៍ ។

ជាអវសាន ពួកប្រឆាំងនឹងបដិវត្តន៍បានត្រូវកំទេចអស់ក្នុងរយៈពេល ៣ ឆ្នាំប្លាយ ។ តែរបបគ្រប់គ្រងថ្មីពុំទាន់ឆ្លងផុតគ្រោះថ្នាក់នៅឡើយ ព្រោះក្នុងពេលជាមួយគ្នានោះ គេត្រូវប្រយុទ្ធទប់ទល់នឹងសត្រូវក្រៅប្រទេសផងដែរ ។

### ខ. អន្តរាគមន៍បរទេស

សម្ព័ន្ធមិត្រចាស់របស់រូស៊ីមិនសប្បាយចិត្តនឹងការស្ថាបនារបបគ្រប់គ្រងកុម្មុយនិស នៅសហភាពសូវៀតឡើយ ហើយគេចាំឆ្លៀតរកគ្រប់ឱកាស ដែលគេអាចធ្វើអន្តរាគមន៍កំទេចបដិវត្តន៍ចោល ។ ចំបាំងផ្ទៃក្នុង ដែលពួក «*ទស*» ហៅ «*គូឡាក់*» បានបង្កបង្កើតឡើងនោះ បានអនុញ្ញាតពួកសត្រូវបរទេសឲ្យធ្វើអន្តរាគមន៍ចូលមកក្នុងកិច្ចការផ្ទៃក្នុងនៃសហភាពសូវៀត ។ យ៉ាងណាមិញ កងទ័ពឆេកូស្លូវ៉ាគីបានវាយលុកលុយតំបន់វ៉ុលកា ( Volga ) កងទ័ពអង់គ្លេសដណ្ដើមយកបានក្រុងអាកង់សែលស្គី ( Arkhangelsk ) ឯកងទ័ពបារាំងបានវាយលុកចូលក្រុងអូដេសា (Odessa) ហើយកងទ័ពជប៉ុនវាយយកតំបន់

វ្ល៉ាឌីវ៉ូស្តុក (Vladivostok) ។ ឯកង៏ទ័ពប៉ូឡូញយកបានក្រុងគីយេវ (Kiev) ។

ចំពោះគ្រោះថ្នាក់ដ៏ធំដែលកំហែងគំរាមបដិវត្តន៍នេះ រដ្ឋាភិបាលសូវៀតបានប្រើអស់សមត្ថភាពរបស់ខ្លួន ដើម្បីវាយកំចាត់សត្រូវគ្រប់ទិសទី ។ *«កងទ័ពក្រហម»* សូវៀតក្រោមការដឹកនាំរបស់លោកលេនីនផ្ទាល់ បានធ្វើឲ្យបច្ចាមិត្រគ្រប់សមរភូមិដកខ្លួនថយ ។ របបគ្រប់គ្រងកុម្មុយនិស្ត៍ក៏បានទទួលជោគជ័យយ៉ាងត្រចះត្រចង់ ក្រោយពីបានវាយកំទេចសត្រូវរបស់ខ្លួនចេញអស់ពីប្រទេស ។

## ៣. អំពើសំខាន់ៗទាំងឡាយដែលរបបគ្រប់គ្រងថ្មីបានធ្វើក្នុងឆ្នាំដំបូង

ក្រោយពីបានវាយកំទេចពួកប្រឆាំងបដិវត្តន៍ក្នុងប្រទេសនិងអន្តរាគមន៍ពីបរទេស របបគ្រប់គ្រងថ្មីបានចាប់ផ្ដើមចាត់វិធានការសំខាន់ៗទាំងឡាយ ដើម្បីកសាងសង្គមនិយមនៅក្នុងប្រទេសរុស្ស៊ី ដោយប្រកាន់ខ្ជាប់នូវមូលភាពទាំងឡាយដូចតទៅ :

ក. មូលភាពនៃរបបគ្រប់គ្រងថ្មី

* *ខាងក្នុងប្រទេស.—* នៅឆ្នាំ ១៩១៨ សហភាពនៃសាធារណរដ្ឋសង្គមនិយមសូវៀតបានប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញមួយថ្មី ។ ដល់ឆ្នាំ ១៩២៤ រដ្ឋធម្មនុញ្ញទី ១ ត្រូវបានកែប្រែហើយក្នុងឆ្នាំ ១៩៤៦ រដ្ឋធម្មនុញ្ញខាងលើពុំមានលក្ខណៈស្របនឹងកាលៈទេសៈនិងស្ថានភាពថ្មីនៃរដ្ឋសូវៀត ។ រដ្ឋធម្មនុញ្ញសូវៀតបានចែងក្នុងមាត្រាមួយថា *«សហភាពសាធារណរដ្ឋសង្គមនិយមសូវៀតជារដ្ឋសង្គមនិយមនៃកម្មករនិងកសិករ»* អង្គការផ្សេងៗរបស់រដ្ឋមាន :

— *សភាជាន់ខ្ពស់* (Soviet Suprême) ចែកជាសភានៃសហភាពនិងសភានៃសញ្ជាតិ ។ សភាទាំងពីរជាអង្គការនីតិបញ្ញត្តិ

— ក្រៅពីអង្គការជាន់ខ្ពស់ខាងលើ មានសភាផ្សេងៗ ដូចជាសភានៃតំណាងពលករនៅតាមរដ្ឋ រដ្ឋស្វ័យត តាមខ័ណ្ឌ តាមក្រុង ឬតាមរោងចក្រ

— អង្គការកាន់អំណាចនីតិប្រតិបត្តិ គឺក្រុមអភិបាលនៃស្នងការប្រជាជន (សព្វថ្ងៃគឺគណៈរដ្ឋមន្ត្រី) ។ម្យ៉ាងទៀត រដ្ឋធម្មនុញ្ញបានផ្តល់សមភាពដល់ប្រជាពលរដ្ឋទាំងអស់ ដោយពុំគិតដល់ភេទ ដល់សញ្ជាតិនិងសាសន៍ឡើយ ។

** មូលភាពនយោបាយក្រៅប្រទេសសំខាន់ៗ* នៃរបបគ្រប់គ្រងថ្មីក្នុងពេលនេះគឺ

— បញ្ឈប់ការធ្វើសង្គ្រាមតទៅទៀតជាមួយនឹងប្រទេសអាល្លឺម៉ង់

— ស្នើគ្រប់ប្រទេសដែលបានចូលរួមក្នុងសង្គ្រាមលោកលើកទី១ ឲ្យចរចាអំពីយុទ្ធសន្តិភាព ។ ប៉ុន្តែ សំណើនេះពុំបានទទួលការយល់ព្រមពីបក្សសម្ព័ន្ធឡើយ ហើយប្រទេសរុស្ស៊ីក៏បានចុះហត្ថលេខាលើយុទ្ធសន្តិភាពដោយឡែកមួយជាមួយនឹងអាល្លឺម៉ង់ នៅថ្ងៃទី *១៥ ធ្នូ ១៩១៧* ។ នៅថ្ងៃទី *៣ មីនា ១៩១៨* សន្ធិសញ្ញាសន្តិភាពមួយបានទទួលហត្ថលេខារវាងប្រទេសរុស្ស៊ី និងប្រទេសអាល្លឺម៉ង់ គឺសន្ធិសញ្ញា *ប្រេស លីតូវស្គី* ( Brest - Litovsk ) ។

ម្យ៉ាងទៀត ចំពោះនយោបាយក្រៅប្រទេសទូទៅ សហភាពសាធារណរដ្ឋសង្គមនិយមសូវៀតបានប្រកាន់មូលភាពនៃសហវិជ្ជមានដោយសន្តិភាព ទំនាក់ទំនងរវាងរដ្ឋនិងរដ្ឋ ដោយសមភាព ។ល។

ខ. មូលភាពខាងសេដ្ឋកិច្ច

ក្នុងវិស័យសេដ្ឋកិច្ច វិធានការសំខាន់ៗបានត្រូវយកមកអនុវត្ត ដើម្បីស្ថាបនាសង្គមថ្មីមួយប្រកបដោយគតិយុត្តិធម៌ ពោលគឺបំបាត់ *«ការជិះជាន់មនុស្សដោយមនុស្ស»* ។

គេអាចចែកអនុវត្តន៍កម្មវិធីសេដ្ឋកិច្ចថ្មីជាពីររយៈកាលគឺ

** រយៈកាលទី១ : ពីឆ្នាំ ១៩១៨ ដល់ឆ្នាំ ១៩២៤* គឺសម័យសហវិជ្ជមានរវាងរបបសេដ្ឋកិច្ចមូលធននិយមឯកជននិងរបបសេដ្ឋកិច្ចសង្គមនិយម ។

យ៉ាងណាមិញ អនុវត្តន៍លទ្ធិសេដ្ឋកិច្ចកុម្មុយនិសទាំងស្រុង ពោលគឺរដ្ឋកាន់កាប់ទាំងអស់នូវគ្រប់អគ្គការសេដ្ឋកិច្ច បានហុចលទ្ធផលផ្ទុយពីការគ្រោងទុកជាមុន ដោយស្ថានភាពប្រទេសរុស្ស៊ីក្រោយពីចំបាំងក្លាមមិនមានលក្ខណៈអនុគ្រោះឡើយ ។ លោកលេនីនដោយយល់ច្បាស់នូវបញ្ហានេះ ក៏សំរេចកែប្រែកម្មវិធីសេដ្ឋកិច្ចខាងលើខ្លះៗ ដើម្បីលើកស្ទួយស្ថានភាពសេដ្ឋកិច្ចរដ្ឋឡើងវិញ ។

លោកបានបញ្ចូលនយោបាយសេដ្ឋកិច្ចមួយថ្មីដែលមានឈ្មោះថា *« នយោបាយ*

*ខាងសេដ្ឋកិច្ច* » (Nouvelle Politique Economique = NPE) ។ តាមមូលភាពនយោបាយនេះ រដ្ឋអនុញ្ញាតមូលធននិយមឯកជនម្នាក់ៗឲ្យរកស៊ីបានខ្លះ ក្នុងផ្នែកសេដ្ឋកិច្ចណាដែលពុំសូវមានសារៈសំខាន់ ។ ចំពោះផ្នែកសំខាន់ៗ រដ្ឋត្រូវកាន់កាប់តទៅទៀតដដែល ដូចជាឧស្សាហកម្មធំៗ ពាណិជ្ជកម្មក្រៅប្រទេស និងដំណឹកនាំជាដើម ។



លោក ស្តាលីន

**រយៈកាលទី២: ពីឆ្នាំ១៩២៤ ដល់សម័យបច្ចុប្បន្ន* គឺជាសម័យអនុវត្តលទ្ធិសេដ្ឋកិច្ចកុម្មុយនិស ។ វិធានការដែលលោក លេនីនបានអនុវត្ត បានហុចលទ្ធផលយ៉ាងពិស្តារ ជាហេតុឲ្យគេចៀសវាងវិបត្តិបានក្នុងពេលនោះ ។ សកម្មភាពសេដ្ឋកិច្ចក៏មានដំណើររស់រវើកឡើងវិញ តែលោកលេនីនបានទទួលអនិច្ចកម្មទៅ នៅឆ្នាំ ១៩២៤ ដោយពុំទាន់បានឃើញយ៉ាងជាក់ច្បាស់ នូវការលូតលាស់យ៉ាងធាប់រហ័សនៃអនុវត្តន៍ផែនការរបស់លោក *ស្តាលីន* ដែលបានទទួលអំណាចពីលោកលេនីន ហើយដែលមានគោលបំណងធ្វើឲ្យប្រទេសរូស៊ី ដែលពីដើមរៀងមកផ្អែកតែទៅលើកសិកម្មនោះ ប្រែក្លាយទៅជាមហាប្រទេសឧស្សាហកម្មមួយដ៏ចំរើនសំបូរសប្បាយ ។ លោកបានចាប់ស្ថាបនាផែនការសេដ្ឋកិច្ចគ្រប់មែកធាង គ្រប់ផ្នែកទាំងអស់ ។ រដ្ឋបានកាន់កាប់គ្រប់សកម្មភាពសេដ្ឋកិច្ចឡើងវិញ ហើយបានលុបចោលមូលធននិយមឯកជនទាំងអស់ ។ ជំហានដំបូង ដើម្បីសំរេចគោលដៅខាងលើ គឺ

— *ការស្ថាបនាផែនការប្រាំឆ្នាំ* .— ផែនការប្រាំឆ្នាំទី ១(១៩២៨-១៩៣៣) បានហុចលទ្ធផលយ៉ាងសំបើម ។ ស្ថានភាពសេដ្ឋកិច្ចបានឡើងមួយកំរិតខ្ពស់ ដែលគេពុំ

ដែលបានជួបប្រទះនៅប្រទេសរុស្ស៊ីតាំងពីដើមរៀងមក ។ រដ្ឋសូវៀតក៏ប្រែទៅជាមហាអំណាចឧស្សាហកម្មមួយប្រៀបបានស្មើនឹងសហរដ្ឋអាមេរិច ។

នៅឆ្នាំ១៩៣៩ នៅពេលដែលរដ្ឋសូវៀតរៀបចំអនុវត្តផែនការប្រាំឆ្នាំទី ៣ មហាសង្គ្រាមលោកលើកទី ២ បានផ្ទុះឡើងម្តងទៀត ជាហេតុនាំឱ្យផែនការនោះពុំបានទទួលអនុវត្តន៍ ។

— *សមូហកម្មស្រែចំការ* .— ស្រែចំការទាំងឡាយត្រូវបានប្រមូលផ្តុំជា *កុលខូស* (Kolkhoze) ហើយរដ្ឋាភិបាលបានចែកឱ្យកសិករទាំងនោះ នូវឧបករណ៍ផ្សេងៗ ដូចជានង្គ័ល ត្រាក់ទ័រ ពូជដំណាំឬក៏ឱ្យខ្ចីប្រាក់កាសដើម្បីកសិ ។

ស្របជាមួយនឹងសមូហកម្មស្រែចំការនេះ រដ្ឋបានបង្កើតស្រែចំការរបស់ខ្លួនលើដីទាំងឡាយណា ដែលគេបោះបង់ចោលតាំងពីដើមរៀងមក ហើយដែលគេហៅថា *សូវខូស* (Sovkhoze) ។ លទ្ធផលនៃកំណែប្រែនេះបានធ្វើឱ្យផលិតផលខាងកសិកម្ម មានសន្ទុះលឿនយ៉ាងខ្លាំង ។ លទ្ធផលនៃអនុវត្តន៍មូលភាពសេដ្ឋកិច្ច បានទទួលជោគជ័យយ៉ាងសំបើម ។ ឯសក្ដិភាពនៃការចំរើននេះមានដូចតទៅ :

— ចាប់ពីឆ្នាំ១៩៣៣ មក ឧស្សាហកម្មបានកើនដល់ ២៣៨ %

— ពាណិជ្ជកម្មបានកើនពី ១២៥ ទៅ ២៧៨ %

ផលទុនជាតិ (revenu national) បានឡើងពី ៤៥ ៥០០ លាន ទៅ ១០៥ ០០០លានរូប ។ ក្នុងរវាង ១០ ឆ្នាំ (ពី ១៩២៨ ដល់ ១៩៣៩) ផលិតផលស្រូវសាលី ស្ករ ប្រេងកាតបានកើនទ្វេជាពីរ កប្បាសបានកើនទ្វេមួយជាបួន ។ល។

ក . មូលភាពវប្បធម៌និងសង្គម

* *ខាងវប្បធម៌*

មូលដ្ឋាននៃវប្បធម៌ឋិតនៅលើប្រាកដនិយម និងប្រលោមនិយមបដិវត្ត ។ លើមូលដ្ឋាននេះ វប្បធម៌ថ្មីរបស់សូវៀតសំដៅទៅរកការអប់រំសុទិដ្ឋិនិយមចំពោះអនាគតមនុស្សជាតិ ការអប់រំខាងការស្ថាបនានិងការអប់រំឱ្យមានចិត្តក្លៀវក្លា ស្រឡាញ់យុត្តិធម៌ ការពារផលប្រយោជន៍រួម ។ល។

* *ខាងសង្គម*

រដ្ឋសូវៀតបានបំបាត់ចោលអស់នូវវណ្ណៈផ្សេងៗក្នុងសង្គម ហើយបានលើកតំកើងវណ្ណៈពលករ (ពលករខាងបញ្ញានិងពលករខាងហត្ថកម្ម) ដែលបានទទួលការធានាផ្សេងៗពីក្រសួងសន្តិសុខសង្គមជាតិដូចតទៅ :

— មនុស្សម្នាក់ៗត្រូវមានការធ្វើ

— មនុស្សម្នាក់ៗត្រូវទទួលការធានាពីរដ្ឋចំពោះជរាភាព ឬចំពោះជំងឺ ។ល។

ម្យ៉ាងទៀត ការសិក្សាបានលូតលាស់រីកចំរើនយ៉ាងឆាប់រហ័សជាទីបំផុត ។ យ៉ាងណាមិញ ក្នុងឆ្នាំ ១៩១៧ មានប្រជាពលរដ្ឋចំនួន ១៣០ លាននាក់ ជាអនក្ខរជន ។ ដល់ឆ្នាំ ១៩៣៧ អនក្ខរភាពបានបាត់សាបសូន្យស្ទើរតែអស់រលីងពីរដ្ឋសូវៀត ។

## ៤. សហភាពសាធារណរដ្ឋសង្គមនិយមសូវៀតក្នុងឆ្នាំ ១៩៣៩

លទ្ធផលនៃបំលាស់ប្តូរខាងនយោបាយ សេដ្ឋកិច្ច និងសង្គម ដែលបានប្រែប្រួលរៀងរហូតមក តាំងពីបដិវត្តន៍ ខែតុលា ១៩១៧ បានធ្វើឱ្យសហភាពសាធារណរដ្ឋសង្គមនិយមសូវៀតប្រែក្លាយទៅជាមហាអំណាចមួយយ៉ាងធំ ទាំងខាងឧស្សាហកម្ម ទាំងខាងសឹក និងខាងផ្លូវចិត្តទៀតផង ។ គ្មាននរណាម្នាក់ ក្រៅពីរដ្ឋសូវៀតខ្លួនឯងឬរដ្ឋណាមួយ ទោះជាអាឡឺម៉ង់នេះឯងក៏ដោយ ពុំអាចស្មានឬប៉ាន់យ៉ាងត្រឹមត្រូវនូវកំលាំងពិតរបស់រដ្ឋសង្គមនិយមនេះបានឡើយ ។

## សំណួរ

១. សហភាពសូវៀតចាប់កំណើតពីឆ្នាំណា ? អ្នកណាជាអ្នកដឹកនាំបដិវត្តន៍ ?

២. ឧបសគ្គអ្វីខ្លះដែលរដ្ឋថ្មីបានជួបប្រទះ ?

៣. ដើម្បីដោះស្រាយការពិបាកនេះ អ្នកដឹកនាំបដិវត្តន៍បានធ្វើអ្វីខ្លះ ?

៤. នយោបាយថ្មីខាងសេដ្ឋកិច្ចបានលទ្ធផលអ្វីខ្លះ ?

# ១៤. ប្រទេសបារាំងនិងអង់គ្លេស ពីឆ្នាំ ១៩១៩ ដល់ ១៩៣៩

## ក. ប្រទេសបារាំង

ប្រទេសបារាំងបានទទួលការខូចខាតជាច្រើន ក្នុងមហាសង្គ្រាមលោកលើកទី១ ។ ប៉ុន្តែ ប្រទេសបារាំងមានភ័ព្វសំណាងថែរក្សាតុល្យភាពនយោបាយក្តី សេដ្ឋកិច្ចក្តី បានរហូតដល់ឆ្នាំ ១៩៣០ ។ ក្រោយឆ្នាំ១៩៣០ ប្រទេសបារាំងបានជួបប្រទះនឹងការពិបាកជាច្រើន ដូចជាការរស់នៅចង្អៀតចង្អល់ ការបាក់បែកជាច្រើនគណបក្សនយោបាយ ការរីកចំរើនលូតលាស់យ៉ាងឆាប់ខាំងមនោគមវិជ្ជាសង្គមនិយម ។ល។ ជាមួយនឹងការពិបាកទាំងនោះ រដ្ឋាភិបាលត្រូវដោះស្រាយបញ្ហា ដែលទាក់ទងវាំងវិហារនិងរដ្ឋថែមទៀត ។

### ១. វិបត្តិហិរញ្ញវត្ថុ (១៩២៣-១៩២៦)

ពីឆ្នាំ១៩២៣ ដល់ ១៩២៦ វិបត្តិហិរញ្ញវត្ថុមួយយ៉ាងធំបានផ្ទុះនៅប្រទេសបារាំង ។ បារាំងបានសុំខ្ចីប្រាក់ពីបរទេសជាច្រើន ពិសេសពីសហរដ្ឋអាមេរិច ដើម្បីយកមកជួសជុលនិងកសាងជាថ្មីនូវការខូចខាតអន្តរាយទាំងប៉ុន្មាន ដែលបណ្តាលមកពីសង្គ្រាម ។ ប្រទេសបារាំងសង្ឃឹមថានឹងទារប្រាក់សំណងពីប្រទេសអាឡឺម៉ង់ យកទៅសង សហរដ្ឋអាមេរិចវិញ ។ ម្យ៉ាងទៀត រដ្ឋាភិបាលត្រូវបោះក្រដាសប្រាក់ច្រើនលើសប្រមាណ ដើម្បីយកមកប្រើប្រាស់ជាចាំបាច់ ជាហេតុនាំឱ្យប្រាក់ប្រង់បាត់បង់តំលៃ ស្ទើរប្រែក្លាយទៅជាក្រដាសកាសែត ។ ឧទាហរណ៍ នៅឆ្នាំ១៩២៦ ប្រាក់ប្រង់បាត់ ៩/១០ នៃតំលៃរបស់ខ្លួននាឆ្នាំ១៩១៤ ។ ប៉ុន្តែ សកម្មភាពសេដ្ឋកិច្ចមានជីវិតរស់រវើករហូតដល់ឆ្នាំ ១៩៣០ ។

## ២. វិបត្តិសេដ្ឋកិច្ច

ចាប់ពីឆ្នាំ ១៩៣០ មក មហាវិបត្តិពិភពលោកនាឆ្នាំ ១៩២៩ ដែលបានចាប់កំណើតនៅសហរដ្ឋអាមេរិច បានសាយភាយដល់ប្រទេសបារាំង ដែលត្រូវទទួលរងមហាគ្រោះនេះដែរ ។ វិបត្តិនេះបានប៉ះពាល់ដល់វិស័យកសិកម្មជាដំបូង ។ ផលិតផលសំខាន់ៗខាងកសិកម្ម ដូចជាស្រាទំពាំងបាយជូរ ស្រូវសាលី មិនអាចលក់ចេញបាន ។ ស្រូវនិងស្រានេះជាផ្នែកសំខាន់នៃសេដ្ឋកិច្ចបារាំង ហើយប្រជាជនប្រមាណ ៤៥% ត្រូវពឹងផ្អែកជីវិតរបស់ខ្លួនលើសកម្មភាពកសិកម្មនេះ ។ បន្ទាប់មក វិបត្តិបានស៊ីរូងចូលក្នុងវិស័យឧស្សាហកម្មថែមទៀត ។ រោងចក្រជាច្រើនបានត្រូវបញ្ឈប់សកម្មភាពរបស់ខ្លួន ផលិតផលបានធ្លាក់ចុះអស់ ១/៣ ហើយកម្មករចំនួន ៣០០ ០០០ នាក់ ត្រូវគ្មានការធ្វើ ។ ឯចំនួនជាង ១ លាននាក់ទៀតធ្វើការមិនបានពេញពេលវេលា ។

ឈមមុខនឹងស្ថានភាពដ៏ធ្ងន់នេះ រដ្ឋបានធ្វើអន្តរាគមន៍ខ្លះៗ ដើម្បីដឹកនាំសេដ្ឋកិច្ចរដ្ឋឲ្យបានស្របនឹងផលប្រយោជន៍ជាតិ ។ តែនយោបាយនិងវិធានការដែលបានយកមកអនុវត្តដើម្បីដោះស្រាយវិបត្តិទាំងនេះ បានបង្កើតឲ្យមានបរិយាកាសនយោបាយ អាប់អួ ហែកហួរ ចោទប្រកាន់គ្នាទៅវិញទៅមក រកផ្លូវចេញមិនរួច ។

## ៣. វិបត្តិនយោបាយ

នៅប្រទេសបារាំង វិបត្តិនយោបាយមានសភាពស្មុគស្មាញហើយធ្ងន់ណាស់ ។ វិបត្តិនេះជាគ្រោះថ្នាក់មួយយ៉ាងធំដល់របបគ្រប់គ្រងរបស់រដ្ឋ និងដល់ឯកភាពខាងផ្លូវចិត្តរបស់ប្រទេសថែមទៀតផង ។ យ៉ាងណាមិញ ការពុករលួយខាងហិរញ្ញវត្ថុបានផ្ទុះក្នុងឆ្នាំ ១៩៣០ ហើយប៉ះពាល់វរជនជាច្រើនរូប បណ្ដាលឲ្យមតិសាធារណៈមានការរំភើបញាប់ញ័រទូទាំងប្រទេស ។ មតិជាច្រើនបានបន្លឺឡើង ប្រឆាំងនឹងរបបគ្រប់គ្រងដែលអាស្រ័យសភា(១) ។ បក្សសភានិយមនិងបក្សប្រឆាំងនឹងសភាបានចោទគ្នាទៅវិញទៅមកពុំចេះចប់ពុំចេះហើយឡើយ ។ ពីឆ្នាំ ១៩១៩ ដល់ ១៩៣៩ ព្រឹត្តិការណ៍សំខាន់ៗក្នុងវិស័យនយោបាយមានដូចតទៅ :

---

*(១) គេប្រឆាំងនឹងសភាដូចនេះ ពីព្រោះសមាជិកសភាពុំដែលបានសំរេចកិច្ចការណាមួយឲ្យបានទាន់ពេលវេលា ឬពុំដែលបានសំរេចសោះតែម្ដង ។*

### ក. គណបក្សរួបរួមជាតិឬប្លុកជាតិនិយម

ការបោះឆ្នោតឆ្នាំ ១៩១៩ បានប្រគល់អំណាចឲ្យគណបក្សកណ្ដាលនិងគណបក្សខាងស្ដាំរៀបចំគណៈរដ្ឋមន្ត្រីមួយ ដែលមានលោក*ក្លីម៉ង់ស្សូ* (Clemenceau) ជានាយក ។ និន្នាការនយោបាយនៃគណបក្សទាំងពីរពួកខាងលើ បានរួបរួមគ្នាជាគណបក្សមួយឈ្មោះ «*ប្លុកជាតិនិយម*» ហើយបានដឹកនាំនយោបាយរដ្ឋរហូតដល់ឆ្នាំ ១៩២២ ។ ប៉ុន្តែ រដ្ឋាភិបាលទី ១ នៅក្រោយចំបាំង បានពើបប្រទះនឹងការពិបាកជាច្រើន ដូចជាការរស់នៅចង្អៀតចង្អល់ ការប៉ុនប៉ងធ្វើបាតុកម្មជាទូទៅនៅឆ្នាំ ១៩២០ ការលូតលាស់នៃមនោគមវិជ្ជាសង្គមនិយម ការបែកបាក់គណបក្សសង្គមនិយមប្រទេសបារាំងជាពីរពួក និងបញ្ហាដែលបានត្រូវចោទរវាងរដ្ឋនិងវិហារ ។ល។

គ្រប់មធ្យោបាយនិងវិធានការដែលបានអនុវត្ត ពុំអនុញ្ញាតរដ្ឋាភិបាល «*រួបរួមជាតិ*» នេះឲ្យដោះស្រាយគ្រប់ចំណោទ ដែលកំពុងតែត្រូវបានចោទមកលើប្រទេសបានឡើយ ។ វិធានការខាងពន្ធអាករដែលរដ្ឋាភិបាលបានចាត់ឲ្យអនុវត្តមុនពេលបោះឆ្នោតជាសកល បានបង្កើតឲ្យមានការមិនសប្បាយចិត្តពីសំណាក់ភ្នាក់ងាររដ្ឋការតូចតាច និងប្រជាជនជាច្រើន ក្នុងសម័យបោះឆ្នោតខែមីនា ១៩២៤ ប្រជាជនបារាំងបានដកសេចក្ដីទុកចិត្តរបស់ខ្លួនពីគណបក្ស «រួបរួមជាតិ» ដែលត្រូវទទួលបរាជ័យយ៉ាងខ្លាំង ។

### ខ. អំណាចគណបក្សខាងស្ដាំ

បន្ទាប់មក លោក *អ៊ែរ្យ៉ូ* (Herriot) ត្រូវបានជ្រើសតាំងឲ្យរៀបចំគណៈរដ្ឋមន្ត្រីថ្មី ។ លោក អ៊ែរ្យ៉ូ ជាប្រធានគណបក្ស ហើយបានរួបរួមនឹងគណបក្សសង្គមនិយម ក្នុងសម័យបោះឆ្នោតឆ្នាំ ១៩២៤ ។ គណបក្សទាំងពីរនេះមាននិន្នាការនយោបាយខាងឆ្វេងបន្តិច តែរដ្ឋាភិបាលលោក អ៊ែរ្យ៉ូ ត្រូវរលំនៅឆ្នាំ ១៩២៥ ដោយពួកគណបក្សខាងស្ដាំបានប្រឆាំងយ៉ាងខ្លាំងនឹងនយោបាយរបស់លោក ។ បន្ទាប់មក អំណាចបានធ្លាក់ទៅលើគណបក្សខាងស្ដាំ ។ គណបក្សនេះពុំបានដោះស្រាយអ្វីឡើយ ហើយបញ្ហាធំៗ ដូចជាវិបត្តិសេដ្ឋកិច្ច វិបត្តិហិរញ្ញវត្ថុ ភាពគ្មានការធ្វើ បាតុកម្ម ។ល។ រឹតតែចោទមកលើប្រទេសខ្លាំងឡើងៗថែមទៀត ។ មិនតែប៉ុណ្ណោះ គណបក្សនេះបានអនុគ្រោះដល់ពួកក្រុមអ្នកស្នេហ៍

ស្វិទ្ធនឹងអ៊ីទ្ឋៃ  ឡប់ចេញ សកម្មភាពប្រកបដោយគ្រោះថ្នាក់ពេញលើផ្ទៃប្រទេសបារាំងទាំងមូល ។ ពួកក្រុមសំងាត់ផ្សេងៗដែលជាអ្នកប្រឆាំងនឹងរបបសភានិយម បានពីងពាក់ទាក់ទងផ្ទាល់នឹងរដ្ឋទាំងឡាយ ដែលនិយមអំណាចផ្តាច់ការដូចជាអាឡឺម៉ង់និងអ៊ីតាលីជាដើម ។

គ. រណសិរ្សប្រជាមានិតឆ្នាំ ១៩៣៦

ចំពោះគ្រោះថ្នាក់ខាងលើ កំលាំងនយោបាយខាងឆ្វេងទាំងអំបាលម៉ានបានស្រុះស្រួលមូលមតិប្រមូលផ្តុំគ្នា ដើម្បីទប់ទល់នឹងកំលាំងប្រតិកិរិយាខាងស្តាំ ។ នៅឆ្នាំ ១៩៣៥ រណសិរ្សប្រជាមានិតមួយ ដែលមានទិន្នាការនយោបាយជឿនលឿនហើយនិយមការចំរើន ក៏បានត្រូវស្ថាបនា ។ ក្នុងសម័យបោះឆ្នោតឆ្នាំ ១៩៣៦ រណសិរ្សប្រជាមានិតបានទទួលជោគជ័យយ៉ាងធំ ដោយបាន ៣៦៦ កៅអី ក្នុងចំនួនទាំងអស់ ៦០៨ កៅអី ក្នុងរដ្ឋសភា ។

លោក*លេអុងប្លិ៊ម* (Léon Blum) ជាមេគណបក្សសង្គមនិយម ត្រូវទទួលភារៈរៀបចំគណៈរដ្ឋមន្ត្រីដោយមានការគាំទ្រពីគណបក្សកុំមុយនិស ។ គណៈរដ្ឋមន្ត្រីរបស់លោកលេអុងប្លិ៊មបានជួបនឹងឧបសគ្គជាច្រើន ។ វិធានការទាំងឡាយដែលលោកបានចាត់ដើម្បីបំបាត់វិបត្តិសេដ្ឋកិច្ច បន្ថយចំនួនអ្នកគ្មានការធ្វើ និងដើម្បីស្រោចស្រង់រូបិយវត្ថុ បានធ្វើឲ្យវណ្ណៈគហបតីភ័យភ្ញាក់ផ្អើលជ្រុលច្របល់ជាច្រើន ។ ដោយព្រឹទ្ធសភាពុំព្រមអនុវត្តច្បាប់ពិសេស ដែលលោកស្នើដើម្បីទប់ទល់នឹងស្ថានភាពដ៏ធ្ងន់នៃប្រទេស លោកលេអុងប្លិ៊ម ត្រូវលាលែងពីតំណែងនាយករដ្ឋមន្ត្រី នៅខែមិថុនាឆ្នាំ១៩៣៧ ។

ពីរឆ្នាំក្រោយមក គឺរហូតដល់ឆ្នាំ១៩៣៩ នយោបាយរដ្ឋត្រូវបានធ្លាក់ទៅលើគណបក្សកណ្តាល និងគណបក្សខាងស្តាំ ។ ការពិបាកនៅមានសភាពធ្ងន់ដដែល រហូតដល់មហាសង្គ្រាមលោកលើកទី២ ។

## ខ. ប្រទេសអង់គ្លេស

ចក្រភពអង់គ្លេសក៏ដូចជាសាធារណរដ្ឋបារាំងដែរ ជារដ្ឋមានរបៀបគ្រប់គ្រងតាមលទ្ធិប្រជាធិបតេយ្យអាស្រ័យសភាជាអគ្គការធំរបស់ប្រទេស ។ ប៉ុន្តែ ចំបាំងលោកលើកទី ១ បានធ្វើឲ្យរង្គោះរង្គើជីវភាពសេដ្ឋកិច្ច ជីវភាពនយោបាយនិងការរៀបចំរដ្ឋរបស់ខ្លួន ។

## ១. ការលំបាកខាងសេដ្ឋកិច្ច

គេដឹងហើយថា តាំងពីឆ្នាំ ១៩១៩ មកម៉្លេះ ឧស្សាហកម្មអង់គ្លេសមានសភាពទ្រុឌទ្រោមជាខ្លាំង ម្យ៉ាងដោយឧបករណ៍សំរាប់បង្កើតផលមានលក្ខណៈហួសសម័យ ហើយម្យ៉ាងទៀត បៀវត្សកម្មករអង់គ្លេសច្រើនពេក បើប្រៀបធៀបទៅនឹងបៀវត្ស ដែលកម្មករនៅប្រទេសដទៃបានទទួល ដូចជា នៅប្រទេសបារាំង ឬប្រទេសអាល្លឺម៉ង់ជាដើម ។ លក្ខណៈទាំងនេះមិនអនុញ្ញាតឧស្សាហកម្មអង់គ្លេសឲ្យប្រកួតប្រណាំងនឹងផលិតផលនៃបណ្ដាប្រទេសថ្មីៗទាំងឡាយបានឡើយ ដូចជាផលិតផលនៃសហរដ្ឋអាមេរិច អាសង់ទីន កាណាដា អូស្ត្រាលី ជប៉ុន ជាដើម ។ ម្យ៉ាងទៀត យើងដឹងថា ឧត្តមភាពនៃសេដ្ឋកិច្ចអង់គ្លេស គឺឋិតនៅលើថាមពល « ធ្យូងថ្ម » ដែលប្រទេសនេះបានផលិតច្រើនលើសលុបហួសពីការត្រូវការរបស់រដ្ឋទៅទៀត ។ ក្រោយចំបាំង ថាមពលថ្មីៗត្រូវបានយកមកប្រើជំនួស « ធ្យូង » ដូចជាប្រេងកាត អគ្គិសនីជាហេតុនាំឲ្យឧស្សាហកម្មអង់គ្លេសធ្លាក់ចុះមួយកំរិត ។

នៅឆ្នាំ១៩២១ អ្នកគ្មានការធ្វើមានចំនួនដល់ ២ ៥០០ ០០០ នាក់ ចលនាកម្មករមានសភាពកាន់តែខ្លាំងឡើងៗ ។ ក្នុងឆ្នាំ១៩២៦ មហាបាតុកម្មមួយហៀបនឹងផ្ទុះពេញផ្ទៃប្រទេសទាំងមូល តែរាជរដ្ឋាភិបាលរបស់លោក *បលវីន* (Baldwin) បានប្រកាសហាមឃាត់មិនអនុញ្ញាតឲ្យមានចលនាខាងលើ ដោយអះអាងថា គ្រប់បាតុកម្មដែលនឹងប្រព្រឹត្តទៅអនាគតសុទ្ធសឹងតែផ្ទុយនឹងផ្លូវច្បាប់ ហើយនឹងត្រូវបង្ក្រាបដោយឥតត្រាប្រណីឡើយ ។ មិនតែប៉ុណ្ណោះ រាជរដ្ឋាភិបាលបលវីនបានហាមប្រាមភ្នាក់ងាររាជការមិនឲ្យចូលជាសមាជិកសហជីពទៀតផង ។

## ២. វិបត្តិហិរញ្ញវត្ថុ

ក្នុងពេលដែលប្រទេសអង់គ្លេសកំពុងតែប្រទះនឹងការលំបាកផ្នែកសង្គមកិច្ច វិបត្តិហិរញ្ញវត្ថុឆ្នាំ១៩២៩ បានធ្លាក់មកលើខ្លួនថែមទៀត ។ ឈមមុខនឹងមហាព្យុះសង្ឃរាថ្មីនេះ ចក្រភពអង់គ្លេសបានលះបង់មូលភាពនៃសេដ្ឋកិច្ចសេរីរបស់ខ្លួន ដែលខ្លួនបានការពារប្រកាន់យ៉ាងខ្ជាប់ខ្ជួន តាំងពីឆ្នាំ១៩១៤ មកម៉្លេះ ។ រដ្ឋបានធ្វើអន្តរាគមន៍ក្នុងផ្នែកខ្លះៗ នៃសេដ្ឋកិច្ច

ដើម្បីទប់ទល់នឹងមហន្តរាយនេះ ។

នៅឆ្នាំ ១៩៣១ រដ្ឋាភិបាលបានបញ្ចុះតំលៃប្រាក់លីវ (livre) ជាហេតុនាំឲ្យគេអាចដឹកនាំទំនិញចេញទៅបរទេសបានងាយជាងពីដើម ។ ម្យ៉ាងទៀត រដ្ឋាភិបាលបានចាត់វិធានការយ៉ាងតឹងរ៉ឹង ដើម្បីទប់ទល់នឹងការដំឡើងតំលៃទំនិញខាងក្នុងប្រទេស ។

ជាចុងក្រោយបង្អស់ ក្នុងឆ្នាំ ១៩៣១ - ១៩៣២ ចក្រភពអង់គ្លេសបានលះបង់គោលរបប «*ប្តូរដោយសេរី*» របស់ខ្លួន ហើយផលិតផលបរទេស ក្រៅពីទំនិញចូលមកពីសមាគមខំម៉ុនវ៉ាល (Commonwealth) ត្រូវបង់ពន្ធអាករគយយ៉ាងធ្ងន់ (ដល់ ១០០% ក៏មាន) ។ វិធានការលើកស្ទួយស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានហុចលទ្ធផលជាទីគាប់ចិត្ត ។ ឧស្សាហកម្មក្តី កសិកម្មក្តី មានសកម្មភាពរស់រវើកឡើងវិញ ។ ប៉ុន្តែ ចក្រភពអង់គ្លេសពុំអាចចាប់យកឧត្តមភាពរបស់ខ្លួនក្នុងអតីតកាលបានឡើយ ថ្វីបើខ្លួននៅមានឋានៈមួយដ៏ខ្ពង់ខ្ពស់ក្នុងលោក ក្នុងឆ្នាំ ១៩៣៩ ដោយសារពាណិជ្ជកម្ម និងការបង្កើតផលរបស់ខ្លួនក៏ដោយ ។

## ៣. ការលំបាកខាងនយោបាយមានពីរបែប

### ក. នយោបាយក្នុងប្រទេស

គេអាចនិយាយថា ខាងផ្លូវនយោបាយ ចក្រភពអង់គ្លេសបានបង្ហើយវិវត្តន៍ខាងប្រជាធិបតេយ្យរបស់ខ្លួន ។ យ៉ាងណាមិញ គេបានអនុញ្ញាតឲ្យប្រើប្រាស់របៀបបោះឆ្នោតជាសកល ដោយបើកឲ្យស្ត្រីមានសិទ្ធិបោះឆ្នោតតាំងពីមុនពេលសង្គ្រាមមកម្ល៉េះ ។

*គណបក្សនយោបាយធំៗជាងគេ*ក្នុងសម័យនោះមាន :

— *គណបក្សអភិរក្សនិយម* មានអ្នកដឹកនាំសំខាន់ឈ្មោះលោក *បលវិន* លោក *ឆេមប៊ើលិន* (Chamberlain) និងលោក *វិនស្តុន ឆើឈិល* (Winston Churchill) ។

— *គណបក្សការងារនិយម* (Labour Party) ដែលមានលោក *ម៉ាក់ដូណាល់* (MacDonald) ជាអ្នកដឹកនាំ

— *គណបក្សសេរីភាព*.— គណបក្សនេះពុំសូវសំខាន់ទេ ។

គណបក្សការងារនិយមបានដឹកនាំរដ្ឋាភិបាលពីរដង គឺនៅឆ្នាំ ១៩២៤ មួង និងឆ្នាំ

១៩២៩ម្តងទៀត ។ ឯគណបក្សអភិរក្សនិយមដឹកនាំរដ្ឋរហូតដល់សង្គ្រាមលោកលើកទី ២ ។ គេអាចនិយាយជាឱរ៉ាល់បានថា នៅចន្លោះមហាសង្គ្រាមទាំងពីរលើក មានតែគណបក្សអភិរក្សនិយមទេ ដែលជាអ្នកដឹកនាំតំរែតំរង់នយោបាយរដ្ឋ ។

* *វិបត្តិរាជវង្សានុវង្ស*មួយបានកើតឡើងក្នុងឆ្នាំ១៩៣៦ ជាហេតុធ្វើឲ្យសាធារណមតិរំជើបរំជួលជាច្រើន ក្នុងប្រទេសអង់គ្លេសក៏ដូចជានៅក្នុងបណ្តាប្រទេសដែលរួមក្នុងទំមុនវែលដែរ ។ យ៉ាងណាមិញ នៅឆ្នាំ១៩៣៦ មហាក្សត្រ *សក ទី៥* (George V) បានចូលទិវង្គត ហើយតាមរដ្ឋធម្មនុញ្ញ មានតែក្សត្រច្បងទេ បុរសក្តី ស្ត្រីក្តី ដែលមានសិទ្ធិទទួលរាជសម្បត្តិតពីព្រះរាជបិតា ។ រដ្ឋធម្មនុញ្ញបានចែងទៀតថា ក្សត្រឬក្សត្រីស្នងរាជ្យ ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងមេម៉ាយឬពោះម៉ាយ ក្សត្រឬក្សត្រីអង្គនោះ ត្រូវបាត់បង់ជាស្វ័យប្រវត្តនូវសិទ្ធិដើម្បីទទួលរាជសម្បត្តិ ។ ក្នុងពេលនោះ ក្សត្រច្បងនាម *អិដួដទី៨* (Edouard VIII) ដែលត្រូវសោយរាជ្យតពីបិតា បានសព្វព្រះរាជហឫទ័យរៀបអាពាហ៍ពិពាហ៍នឹងស្ត្រីមេម៉ាយអាមេរិកាំងម្នាក់ ដែលបានព្រាត់ប្រាសប្តីប្រពន្ធ ជាពីរដងរួចមកហើយ ។

សាធារណមតិអង់គ្លេសបានបែកចេញជាពីរ ជាបីពួក មានការរំភើបញាប់ញ័រជាច្រើនចំពោះបញ្ហានេះ តែជាចុងក្រោយបង្អស់ វិបត្តិនេះត្រូវបានដោះស្រាយដោយឥតប៉ះពាល់កិត្យានុភាពនៃរាជបល្ល័ង្កឡើយ ហើយរាជសម្បត្តិត្រូវបានប្រគល់ថ្វាយ បុត្រាទី២ គឺ *សកទី២* ដែលត្រូវជាអនុជនៃអិដួដទី ៨ ។

## ១. នយោបាយក្រៅប្រទេស

ចំពោះបញ្ហាក្រៅប្រទេស ចក្រភពអង់គ្លេសត្រូវពើបប្រទះនឹងវិបត្តិធំៗដូចតទៅនេះ :

* *វិបត្តិអៀឡង់.— អៀឡង់*ជាកោះមួយធំនៅខាងលិចប្រទេសអង់គ្លេស ហើយដែលប្រទេសនេះបានភ្ជាប់មកនឹងទឹកដីរបស់ខ្លួន តាំងពីមុនសង្គ្រាមលោកលើកទី១ម៉្លេះ ។ ក្រោយមហាសង្គ្រាម ប្រជាជនអៀឡង់ក្រោមការដឹកនាំនៃគណបក្សជាតិនិយមឈ្មោះ*ស៊ិនផេន* (Sinn Fein) ហើយដែលមានលោក*ដឺវ៉ាឡឺរ៉ា* (De Valera) ជាអ្នកដឹកនាំ បានបះបោរទាមទារឯករាជ្យជូនមាតុប្រទេស ។ រដ្ឋាភិបាលអង់គ្លេសបានបង្ក្រាបចលនានេះយ៉ាងឃោរឃៅបំផុតក្នុងអំឡុងបីឆ្នាំ តែពុំបានលទ្ធផលអ្វីឡើយ ។ ជាចុងក្រោយបំផុត

រាជរដ្ឋាភិបាលអង់គ្លេសត្រូវបង្ខំចិត្តទទួលតាមការទាមទាររបស់អ្នកដឹកនាំអៀរឡង់ ដូចជាចក្រភពអង់គ្លេសសុខចិត្តដកទ័ពថយចេញពីកោះ ហើយនិងបញ្ជូនអ្នកត្រួតត្រាជាតិអង់គ្លេសឲ្យវិលមកក្រុងឡុងវិញ តែចក្រភពអង់គ្លេសមិនអនុញ្ញាតឲ្យរដ្ឋ *អៀ* (Eire) ភ្ជាប់តំបន់ *អ៊ុលស្ទែ* (Ulster) ជាមួយគ្នាឡើយ ។

*កំណត់សំគាល់ .* — ក្នុងកិច្ចព្រមព្រៀងមួយនាឆ្នាំ ១៩២១ កោះអៀរឡង់ត្រូវបែងចែកជាពីរផ្នែក :

— *តំបន់អ៊ុលស្ទែ* ដែលមានជនជាតិកាន់សាសនាគ្រិស្តផ្នែកប្រូតេស្តង់ បានទទួលលក្ខន្តិកៈពិសេសមួយ ។ តំណាងរាស្ត្រនៃតំបន់នោះត្រូវទៅរួមប្រជុំនៅសភាអង់គ្លេស ឯក្រុងឡុង ពោលគឺជាអាណានិគមដ៏បរិសុទ្ធរបស់អង់គ្លេស ។

— *ផ្នែកសល់ពីអ៊ុលស្ទែ* ដែលប្រជារាស្ត្រមានដើមកំណើតជា *សិល* (Celtes) ហើយកាន់សាសនាកាតូលិច ត្រូវបានបង្កើតជារដ្ឋឯករាជ្យមួយ ឲ្យឈ្មោះថា *រដ្ឋសេរីនៃកោះអៀរឡង់* ។ តែអង់គ្លេសនៅតែត្រួតត្រា ព្រមទាំងមានកងទ័ពតាំងក្នុងរដ្ឋនោះទៀតផង ។ ចលនាជាតិនិយមស៊ិនផេន មិនត្រឹមតែទាមទារតំណាងនិងកងទ័ពរបស់អង់គ្លេសឲ្យចេញពីរដ្ឋសេរីនេះឡើយ គឺថែមទាំងទាមទារបញ្ចូលតំបន់អ៊ុលស្ទែ មកក្នុងរដ្ឋនេះទៀតផង ដែលគេឲ្យឈ្មោះហៅថា *អៀ* (Eire) ។

* *បញ្ហាប្រទេសអេស៊ីប .* — ប្រទេសអេស៊ីប ត្រូវធ្លាក់ចូលក្នុងអាណាព្យាបាលអង់គ្លេស តាំងពីឆ្នាំ ១៨៨២ ម៉្លេះ ។ ក្រោយចំបាំងលោកលើកទី ១ អ្នកស្នេហាជាតិអេស៊ីបបានទាមទារឯករាជ្យពីអង់គ្លេស ។ ដោយអង់គ្លេសពុំព្រមទទួលការទាមទារនេះ ប្រជាជនអេស៊ីបបានកាន់អាវុធក្រោកឡើងប្រឆាំងតទល់នឹងអាណានិគមនិយមអង់គ្លេស ។ ចលនានេះមានសកម្មភាពរីកពាសពេញលើផ្ទៃប្រទេស ជាហេតុបង្ខំអ្នកដឹកនាំអង់គ្លេស ឲ្យដកអាណាព្យាបាលរបស់ខ្លួនចេញក្នុងឆ្នាំ ១៩២២ ។ ដល់ឆ្នាំ ១៩៣៦ ចក្រភពអង់គ្លេសបានទទួលស្គាល់ឯករាជ្យអេស៊ីប ដែលជាឯករាជ្យតែរូបភាពខាងក្រៅ ព្រោះចក្រភពអង់គ្លេសនៅត្រួតត្រាលើ *ព្រែកជីកស៊ុយអេ* រហូតដល់ឆ្នាំ ១៩៥៦ ។

* *បញ្ហាប្រទេសឥណ្ឌា .* — ប្រទេសឥណ្ឌាមានបញ្ហាស្មុគស្មាញជាងអេស៊ីបទៅទៀត ។ ក្រោយពេលចំបាំង អ្នកស្នេហាជាតិឥណ្ឌា ក្រោមការដឹកនាំរបស់ *បណ្ឌិត*

គន្ធី បានក្រោកឡើងតស៊ូយ៉ាងស្វិតស្វាញ ដើម្បីទាមទារយកឯករាជ្យ ។ ដើម្បីទប់ទល់នឹងព្រឹត្តិការណ៍ដ៏មានគ្រោះថ្នាក់នេះ រដ្ឋាភិបាលអង់គ្លេសបានសំរេចបញ្ចូលកំណែទំរង់ខ្លះៗក្នុងឆ្នាំ ១៩១៩ តែកំណែទំរង់នេះពុំបានធ្វើឲ្យប្រទេសឥណ្ឌាស្ងប់ស្ងៀមសុខចិត្តឡើយ ។ របះបោរខាងនយោបាយបានផ្ទុះពាសពេញលើផ្ទៃប្រទេស ហើយមានសភាពខ្លាំងឡើងៗ ។ ដើម្បីរំងាប់ចលនានយោបាយខាងលើនេះ គេបានប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញមួយ ក្នុងឆ្នាំ ១៩៣៥ ។ នេះជាជ័យជំនះមួយក៏ពិតមែនហើយ តែការសង្ឃឹមរបស់ប្រជាជនឥណ្ឌាប្រែក្លាយទៅជាការយល់សប្តិទៅវិញ ។ មកទល់នឹងឆ្នាំ ១៩៣៩ បញ្ហាឥណ្ឌាទាំងស្រុងនៅពុំទាន់បានដោះស្រាយនៅឡើយ ។

# សំណួរ

១. ស្ថានភាពនៃប្រទេសបារាំងពេលក្រោយសង្គ្រាម ។

២. វិបត្តិសេដ្ឋកិច្ច និងផលវិបាកនៃប្រទេសបារាំង ។

៣. គណបក្សនយោបាយសំខាន់ៗនៃប្រទេសបារាំងនាសម័យនោះ ។

៤. តើបក្សនយោបាយទាំងនោះអាចដោះស្រាយបញ្ហាប្រទេសបានឬទេ ? ពីព្រោះអ្វី ?

៥. ស្ថានភាពសេដ្ឋកិច្ចនៃប្រទេសអង់គ្លេសក្រោយសង្គ្រាម ។

៦. មហាវិបត្តិឆ្នាំ ១៩២៩ បានជះឥទ្ធិពលលើសេដ្ឋកិច្ចជាតិអង់គ្លេសដូចម្តេចខ្លះ ?

៧. គណបក្សនយោបាយសំខាន់ៗនៃប្រទេសអង់គ្លេស ។ គណបក្សទាំងនេះមានកម្មវិធីនយោបាយប្លែកគ្នាឬទេ ?

៨. វិបត្តិអៀរឡង់ : បុព្វហេតុនិងដំណោះស្រាយ ។

៩. នយោបាយក្រៅប្រទេសរបស់អង់គ្លេសមានពើបប្រទះនឹងការពិបាកអ្វីខ្លះ ?

# ១៥. សហរដ្ឋអាមេរិច
# ពីឆ្នាំ ១៩១៩ ដល់ ១៩៣៩

ចំបាំងលោកលើកទី ១ បានធ្វើឲ្យសហរដ្ឋអាមេរិចស្គាល់ភាពរុងរឿងមួយ ដែលគេពុំបានពើបប្រទះតាំងពីដើមរៀងមក ។ ពីដើម សហរដ្ឋអាមេរិចធ្លាប់ជាកូនបំណុលនៃទ្វីបអឺរ៉ុប តែដល់មកឆ្នាំ ១៩១៩ បានប្រែក្លាយទៅជាមេបំណុលមួយយ៉ាងធំដែលបានផ្ដល់ដល់អឺរ៉ុប អាមេរិចឡាទីននិងកាណាដា នូវមូលធនជាច្រើនមហិមា ។ ពេលក្រោយចំបាំង ដោយសារឧត្ដមភាពនៃសេដ្ឋកិច្ចរបស់ខ្លួន សហរដ្ឋអាមេរិចបានឡើងជាមហាអំណាចមួយធំយ៉ាងខ្លាំងពូកែ ហើយដែលមានជំហររឹងប៉ឹងក្នុងឆាកនយោបាយអន្តរជាតិទៀតផង ។

តែទោះបីយ៉ាងណាក៏ដោយ សហរដ្ឋអាមេរិចបានជួបនឹងការលំបាកជាច្រើន ដូចជាវិបត្តិសេដ្ឋកិច្ច វិបត្តិហិរញ្ញវត្ថុ និងវិបត្តិសង្គមជាដើម ។

## ១. មហាវិបត្តិឆ្នាំ ១៩២៩

ក្រោយពីបានស្គាល់ភាពរុងរឿងសំបូរសប្បាយក្នុងអំឡុង ១០ ឆ្នាំមក សហរដ្ឋអាមេរិចបានប្រទះនឹងមហាវិបត្តិមួយ ។ មហាវិបត្តិនេះមានវិវត្តន៍ជាលំដាប់លំដោយដូចតទៅ :

### ក. វិបត្តិក្នុងវិស័យកសិកម្ម

វិបត្តិនេះមានបាតុភាពចាប់តាំងពីឆ្នាំ ១៩២៥ ម៉្លេះ ព្រោះកសិករអាមេរិកាំងពុំអាចលក់ផលិតផលរបស់ខ្លួនបាន ម្យ៉ាងមកពីផ្សារនៅអឺរ៉ុបត្រូវបិទទ្វារមួយភាគធំ ហើយម្យ៉ាងទៀតតំលៃផលិតផលខាងកសិកម្មចុះយ៉ាងថោកបំផុត ។ ស្ថានភាពកសិកម្មដែលមានសភាពដុនដាបតាំងពីឆ្នាំ ១៩២៥ បានធ្លាក់ចុះដល់កំរិតយ៉ាងទាបក្នុងឆ្នាំ ១៩២០ ។ ឧទាហរណ៍ តំលៃសរុបនៃផលិតផលខាងកសិកម្មមាន ១៧ ពាន់លានដុល្លាក្នុងឆ្នាំ ១៩២០ ។ តំលៃ

នេះបានធ្លាក់ចុះមកត្រឹមតែ ១២ ពាន់លានដុល្លា ក្នុងឆ្នាំ ១៩២៩ ហើយតែ ៥ ពាន់លានដុល្លា ក្នុងឆ្នាំ ១៩៣២ ។ នៅឆ្នាំដដែលនោះ ស្រែចំការ ៤២ % ត្រូវគេរឹបអូសយក ដោយម្ចាស់ដីរកប្រាក់សងពុំបាន ។

ខ. វិបត្តិឧស្សាហកម្ម

រោងចក្រជាច្រើនបានត្រូវបិទទ្វារ សហគ្រាសត្រូវអស់មូលធនបន្តៗគ្នា កម្មករគ្មានការធ្វើមានចំនួន ១៤ លាននាក់ ដោយគេពុំបានបញ្ចូលកសិករចំនួន ១៥ លាននាក់ ដែលមានការរស់នៅខ្វះព្រឹក ខ្វះល្ងាច ត្រដាបត្រដួសជាខ្លាំងនោះផងទេ ។ ឧទាហរណ៍ៈ ក្នុងឧស្សាហកម្មរថយន្តដែលជាឧស្សាហកម្មមួយមានភាពរុងរឿងជាងគេ ចំនួនកម្មករបានធ្លាក់ពី ៥,៥ លាននាក់ក្នុងឆ្នាំ ១៩២៩ មក ៤ លាននាក់ក្នុងឆ្នាំ ១៩៣៣ ហើយក្នុងចំនួនខាងក្រោយនេះ ភាគតិចណាស់ដែលមានការធ្វើពេញពេលវេលា ។




*បរិយាកាសនៃវិបត្តិសេដ្ឋកិច្ចក្នុងឆ្នាំ ១៩២៩ នៅសហរដ្ឋអាមេរិច*

តំលៃសរុបនៃឧស្សាហកម្មរថយន្តទាំងអស់ ដែលបានកំណត់ត្រឹម ៦ ពាន់លានដុល្លា ក្នុងឆ្នាំ ១៩២៩ បានធ្លាក់ចុះមកត្រឹមតែ ១ ពាន់លានដុល្លា ក្នុងឆ្នាំ ១៩៣៣ ។

គ. វិបត្តិហិរញ្ញវត្ថុ

វិបត្តិហិរញ្ញវត្ថុបានផ្ទុះក្នុងឆ្នាំ ១៩២៩ ។ ធនាគារទាំងឡាយត្រូវបិទទ្វារស្ទើរតែទាំងអស់ដោយរកប្រាក់បង្វិលឲ្យឯកជនម្នាក់ៗពុំបានឡើយ ។

តែក្នុងរដ្ឋមីស៊ីខិនមួយប៉ុណ្ណោះ ធនាគារចំនួន ៥៣០ ត្រូវបិទទ្វារ ហើយក្នុងរដ្ឋ ១៧ ដទៃទៀត សកម្មភាពខាងធនាគារបានត្រូវបញ្ឈប់ ។ ការភ័យតក់ស្លុតនៃប្រជាពលរដ្ឋដែលធ្លាប់តែមានសុទិដ្ឋិនិយម បានធ្វើឲ្យគេដណ្ដឹងសួរថា តើបាតុភាពនេះជាបរាជ័យនៃរបបមូលធននិយមឬ ។

## ២. បញ្ហានយោបាយ

តាំងពីឆ្នាំ ១៩១៩ ដល់ឆ្នាំ ១៩៣៣ ប្រធានាធិបតីបីរូបបានគ្រប់គ្រងសហរដ្ឋអាមេរិច គឺលោក *ហាឌិញ* ដែលស្លាប់ក្នុងឆ្នាំ ១៩២៣ លោក *ឃូលីត* ត្រូវបានតែងតាំងជាប្រធានាធិបតីក្នុងឆ្នាំ ១៩២៤ លោក *ហ៊ូវើ* ( Hoover ) ត្រូវជ្រើសតាំងជាប្រធានាធិបតីក្នុងឆ្នាំ ១៩២៨ ។ ប្រធានាធិបតីទាំងបីរូបខាងលើសុទ្ធតែជាអ្នកដឹកនាំនៃគណបក្សសាធារណរដ្ឋនិយម ។ នៅពេលដែលវិបត្តិផ្ទុះក្នុងឆ្នាំ ១៩២៩ គឺសហរដ្ឋអាមេរិចត្រូវបានដឹកនាំដោយលោកហ៊ូវើ ។ ឈមមុខនឹងមហាវិបត្តិខាងលើ ប្រធានាធិបតី ហ៊ូវើ ពុំបានចាត់វិធានការអ្វីដែលមានប្រសិទ្ធភាពឡើយ ។ ដោយមានធម្មជាតិជាសុទិដ្ឋិនិយមស្រាប់ លោក ហ៊ូវើ ពុំព្រមធ្វើអន្តរាគមន៍ចូលក្នុងសកម្មភាពសេដ្ឋកិច្ច ដើម្បីដោះស្រាយវិបត្តិខាងលើ ដែលមានសភាពខ្លាំងឡើងៗជានិរន្តរ៍ ។ ដូចនេះហើយ បានជាក្នុងការបោះឆ្នោត ខែ វិច្ឆិកា ឆ្នាំ ១៩៣២ គណបក្សសាធារណរដ្ឋនិយមត្រូវទទួលបរាជ័យ ហើយលោក *ហ្វ្រាំងគ្លិនរូស្វែល* ( គណបក្សប្រជាធិបតេយ្យ ) បានទទួលជ័យជំនះយ៉ាងសំបើម ។ លុះបានជាម្ចាស់សហរដ្ឋអាមេរិច លោកប្រធានាធិបតីរូស្វែលបានចាត់វិធានការភ្លាម ដើម្បីទប់ទល់នឹងវិបត្តិ ដែលប្រទេសកំពុងឆ្លងកាត់



*លោក ហ្វ្រាំងគ្លិនរូស្វែល*

ច្រកបដោយគ្រោះថ្នាក់នេះ ។ លោកបានប្រមូលមកជុំវិញខ្លួនលោកនូវអ្នកជំនាញៗទៅតាមឯកទេសភាពហើយបានបង្កើតជាគណៈកម្មាធិការផ្សេងៗ ដើម្បីរិះរកមធ្យោបាយមកអនុវត្តក្នុងដំណោះស្រាយវិបត្តិខាងលើ ។

វិធានការដែលលោកដាក់ឱ្យអនុវត្តមានវិធានការជាបន្ទាន់ ដែលអាចទប់ទល់កុំឱ្យស្ថានភាពសេដ្ឋកិច្ចរលំភ្លាមៗ និងវិធានការសំរាប់ធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចមានការលូតលាស់ឡើងវិញជាលំដាប់ ដោយកែសំរួលរចនាបថចាស់ខ្លះៗ ។

ចំពោះវិធានការប្រភេទទី ១ គឺលោកបាន *បញ្ចុះតំលៃប្រាក់ដុល្លាពាក់កណ្តាល* និងបើកការដ្ឋានសាធារណៈធំៗដើម្បីផ្តល់ការងារដល់អ្នកគ្មានការធ្វើ ។

ការបញ្ចុះតំលៃប្រាក់ដុល្លាបានធ្វើឱ្យកូនបំណុលធូរស្រាលបន្តិច ព្រមទាំងបានទាញប្រាក់ដែលកប់ក្នុងថូដែកឯកជនឱ្យមានចលនាឡើងវិញ ។ ការផ្តល់ការងារដល់អ្នកគ្មានការធ្វើញាំងពួកទាំងនេះឱ្យមានប្រាក់កាស ជាហេតុធ្វើឱ្យរោងចក្រមានសកម្មភាពឡើងវិញ ។ វិធានការកំណែទំរង់របៀបរបបសំខាន់ៗមាន :

— វិធានការខាងកសិកម្ម ( ច្បាប់ស្តីពីកំណែទំរង់កសិកម្ម ) ។

— វិធានការខាងឧស្សាហកម្ម ( ច្បាប់ស្តីពីការលើកស្ទួយឧស្សាហកម្មជាតិ ) ។

វិធានការទាំងនេះមានគោលបំណងនឹងផ្តល់ប្រាក់បំណាច់ដល់កសិករ ដែលសុខចិត្តកំណត់ទំហំដីរបស់ខ្លួនព្រមទាំងបានកំណត់តំលៃអប្បបរមានៃផលិតផលខ្លះ ដែលពលរដ្ឋត្រូវធានាអះអាង ។ វិធានការខាងឧស្សាហកម្ម គឺទប់ទល់នឹងការចុះតំលៃទំនិញ ធ្វើឱ្យមានការប្រកួតប្រណាំងក្នុងការលក់ដូរ ព្រមទាំងបានបន្ថយកំណត់ពេលធ្វើការក្នុងមួយសប្តាហ៍ទៀតផង ។ល។ វិធានការសេដ្ឋកិច្ចដែលលោកប្រាំងគ្លីនរ៉ូស្វែល បានចាត់ទាំងអស់ ដើម្បីស្រោចស្រង់ស្ថានភាពសេដ្ឋកិច្ចជាតិ មានឈ្មោះ *ញូឌីល* ( New Deal ) ។ គេអាចសន្និដ្ឋានបានថា ផែនការនេះបានទទួលជោគជ័យជាទីគាប់ចិត្តដែរ ។ លទ្ធផលជាបន្ទាន់គឺលោករ៉ូស្វែលបានស្រោចស្រង់សេដ្ឋកិច្ចជាតិឱ្យចាកផុតពីវិបត្តិដ៏សាហាវក្នុងពេលនោះ ។ ដើម្បីសំដែងនូវកតញ្ញូតាធម៌ចំពោះប្រធានាធិបតីរបស់ខ្លួន ប្រជាពលរដ្ឋអាមេរិកាំងបានបោះឆ្នោតផ្តល់សេចក្តីទុកចិត្តលើរូបលោករ៉ូស្វែល *បួនលើក* ជាប់ៗគ្នា គឺនៅឆ្នាំ ១៩៣២ ឆ្នាំ ១៩៣៦ ឆ្នាំ ១៩៤០ និងឆ្នាំ ១៩៤៤ ។

# សំណួរ

១. ស្ថានការណ៍ទូទៅនៃសហរដ្ឋអាមេរិចក្រោយសង្គ្រាមលោកលើកទី ១ ។

២. មហាវិបត្តិឆ្នាំ ១៩២៩ ខាងកសិកម្ម ឧស្សាហកម្ម និង ហិរញ្ញវត្ថុ ។

៣. សហរដ្ឋអាមេរិចបានធ្វើអ្វីខ្លះ ដើម្បីដោះស្រាយវិបត្តិនេះ ?

# ១៦. ប្រទេសអ៊ីតាលីនិងអាឡឺម៉ង់ ពីឆ្នាំ ១៩១៩ ដល់ ១៩៣៩

ក្រោយពីចំបាំងលោកលើកទី ១ បណ្ដាប្រទេសនៅទ្វីបអឺរ៉ុបជាច្រើនបានជួបវិបត្តិគ្រប់បែបយ៉ាង ដែលជាបច្ច័យនៃសង្គ្រាមខាងលើ ហើយដែលជាហេតុបង្កើតឲ្យមានរបបផាស៊ិស និងរបបផ្ដាច់ការនៅប្រទេសអ៊ីតាលី ប្រទេសអាឡឺម៉ង់ជាដើម ។

## ក. ប្រទេសអ៊ីតាលី

ក្នុងចំណោមប្រទេសដែលរួមក្នុងចំបាំងលោកលើកទី ១ មានតែប្រទេស *អ៊ីតាលី* មួយទេដែលបានទទួលបំលាស់ប្ដូរបំរែបំរួលយ៉ាងទូលំទូលាយជាងប្រទេសនានាទាំងអស់ ។ យ៉ាងណាមិញ ក្រោយពីបានពើបប្រទះការច្របូកច្របល់ អស់មួយរយៈពេលយ៉ាងយូរ ប្រទេសអ៊ីតាលីបានប្រែ*ពីរបបនយោបាយប្រជាធិបតេយ្យ-សេរីភាព* (សភានិយម) ទៅជា*របបផាស៊ិស* ។ វិវត្តន៍ទៅរកផាស៊ិសនិយមនេះជាបច្ច័យនៃសង្គ្រាមផ្ទាល់តែម្ដង ដោយប្រទេសអ៊ីតាលីបានជួបនឹងវិបត្តិជាច្រើន ។

### ១. វិបត្តិសេដ្ឋកិច្ច

ក្រោយចំបាំង ប្រទេសអ៊ីតាលីបានធ្លាក់ខ្លួនចុះទៅជាក្រីក្រដុនដាប ។ ស្ថានភាពសេដ្ឋកិច្ចបានធ្លាក់ចុះយ៉ាងទាបបំផុត ហើយមានសភាពរឹងរឹតតែធ្ងន់ឡើងៗ ។ ក្រៅពីការពិបាកទាំងឡាយ ដូចជាមនុស្សច្រើន ការយឺតយ៉ាវក្នុងការលូតលាស់ខាងសេដ្ឋកិច្ច ប្រទេសអ៊ីតាលីមានការពិបាកជាច្រើនមកគ្របសង្កត់ថែមទៀត :

– ក្នុងពេលចំបាំង ប្រទេសអ៊ីតាលីបានខ្ចីប្រាក់ពីបរទេស ដើម្បីរៀបចំទ័ព និង

ពង្រីកឧស្សាហកម្មសឹករបស់ខ្លួន ជាហេតុនាំឲ្យជំពាក់បំណុលគេជាច្រើន ។ ព្រមជាមួយនោះប្រាក់អ៊ីតាលីត្រូវបញ្ចុះថ្លៃ ។

— ក្រោយចំបាំង សហគ្រាសឧស្សាហកម្មទាំងឡាយត្រូវរលំ ដោយផលិតផលលក់មិនចេញ ឬក៏ដោយសង្គ្រាមបំផ្លិចបំផ្លាញ ។

## ២. វិបត្តិខាងសង្គម

វិបត្តិសេដ្ឋកិច្ចខាងលើជាហេតុនាំឲ្យមានវិបត្តិខាងសង្គមថែមទៀត ។ ស្ថានភាពសង្គមបានធ្លាក់ចុះមួយកំរិតគួរឲ្យភ័យបារម្ភ ។ កសិករត្រូវហិនហោចខូចប្រយោជន៍ ។ អ្នកគ្មានការធ្វើមានចំនួនរឹតតែច្រើនឡើងៗ ។ ចាប់តាំងពីឆ្នាំ ១៩១៩ មក គេសង្កេតឃើញមានបាតុកម្ម មានរបះរបោរ ឆក់ប្លន់រឹតតែច្រើនឡើងៗជាលំដាប់ ។ អសន្តិសុខមានពាសពេញប្រទេស ។ នៅឆ្នាំ ១៩២០ កម្មកររោងចក្រស្លដែកចំនួន ៦០០ ០០០ នាក់បានបះបោរដណ្តើមកាន់កាប់រោងចក្រខ្លួនឯង ។ ចលាចលខាងកសិកម្មមានកើតពាសពេញប្រទេសទាំងអស់ ហើយក្លាយទៅជាចំបាំងក្នុងស្រុកទៀតផង ដូចជានៅកោះស៊ីស៊ីល នៅវាលទំនាបប៉ូជាដើម ។

## ៣. វិបត្តិនយោបាយ

ឈមមុខតទល់នឹងការពិបាកទាំងនោះ មេដឹកនាំពុំបានចាត់វិធានការអ្វីដើម្បីស្រោចស្រង់ប្រទេសឲ្យរួចពីអនាធិបតេយ្យឡើយ ហើយពុំព្រមសំរេចឲ្យមានកំណែទំរង់អ្វីច្បាស់លាស់ដែរ ។ ផ្ទុយទៅវិញ គេច្រើនតែឈ្លោះប្រកែក ប្រកាន់បក្សពួកពុំចេះចប់ពុំចេះហើយក្នុងសភាជាតិ រដ្ឋាភិបាលបាត់បង់អស់អំណាចរកធ្វើការអ្វីមិនកើត ។

មហាសេដ្ឋី ដោយព្រួយបារម្ភខ្លាចបាត់បង់ផលប្រយោជន៍របស់ខ្លួន បណ្តាលមកពីបាតុកម្ម ពីចលាចល ពីរបះរបោរទាំងនោះ បានគាំទ្រយ៉ាងពេញទំហឹងដល់គណបក្សផាស៊ីសរបស់លោកមូសូលីនី ដើម្បីទប់ទល់នឹងអណ្តាតភ្លើងបដិវត្ត ដែលកំពុងតែឆេះរាលដាលលើប្រទេសអ៊ីតាលីទាំងមូល ។ នៅខែតុលា ១៩២២ លោកមូសូលីនីធ្វើរដ្ឋប្រហារដណ្តើមយកអំណាចបាន ហើយកងទ័ពរបស់លោកដែលមានឯកសណ្ឋានជា « អាវសឺមខ្មៅ » បានហែជាព្យូហយាត្រាយ៉ាងឧឡារិក នៅក្រុងរ៉ូម នាថ្ងៃទី ៣០ តុលា ១៩២២ ។